រាជរដ្ឋាភិបាល

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# យុទ្ធសាស្ត្រ
# ស្តីពី
# ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ
# បច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨




អគ្គលេខាធិការដ្ឋាន

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាល

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# យុទ្ធសាស្ត្រ
# ស្តីពី
# ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ
# បច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨

អគ្គលេខាធិការដ្ឋាន

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

# បុព្វកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងឋានៈជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាពេលនោះ និងជា **អគ្គមហាវរដ្ឋបុរសដ៏ឆ្នើមគ្មានពីរ** ក្នុងការបង្រួបបង្រួមទឹកដី និងបានប្រែក្លាយប្រទេសកម្ពុជា មកជាប្រទេសដែលមានសុខសន្តិភាពពេញលេញ, ស្ថិរភាពនយោបាយ, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង ជាពិសេស បានដឹកនាំប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ដោយផ្អែកលើគោលការណ៍ «**បើកែទម្រង់យើងមានសង្ឃឹមរស់ដល់ទៅ៩៩% តែបើមិនកែទម្រង់ មានសង្ឃឹមរស់តែ១% ប៉ុណ្ណោះ**»។ បន្ថែមពីនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានអនុវត្តតាមអភិក្រមជាជំហានៗ តាមដំណាក់កាលចំនួន ៤ គឺ៖ (១) **ភាពជឿទុកចិត្តនៃថវិកា** (២០០៥-២០០៨), (២) **គណនេយ្យភាពហិរញ្ញវត្ថុ** (២០០៩-២០១៥), (៣) **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** (២០១៦-២០២២), និង(៤) **គណនេយ្យភាពសមិទ្ធកម្ម** (២០២៣-២០២៧)។ ក្នុងនោះ, គោលដៅចម្បងនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការផ្លាស់ប្តូរជាបណ្តើរៗនៃប្រព័ន្ធថវិកា និងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ ពី «**ប្រព័ន្ធថវិកាដែលផ្អែកលើធាតុចូល និងមជ្ឈការ**» ឆ្ពោះទៅ «**ប្រព័ន្ធថវិកាដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ**» ស្របតាមបទដ្ឋាន និងឧត្តមានុវត្តន៍ជាអន្តរជាតិ ព្រមទាំងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា។

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេលជាង ២០ ឆ្នាំកន្លងមក សម្រេចបាននូវសមិទ្ធផលជាសារវន្តតាមខឿន និងដំណាក់កាលនីមួយៗ ដែលបានកសាង និងកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យកាន់តែរឹងមាំ និងមានភាពធន់នឹងវិបត្តិ ជាពិសេសបានប្រែក្លាយកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់លឿនជាមួយអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងរង្វង់ ៧% ជារៀងរាល់ឆ្នាំ មុនពេលមានវិបត្តិនៃជំងឺកូវីដ-១៩។ ស្របពេលជាមួយគ្នានេះ, ក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ «**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**» រាជរដ្ឋាភិបាលកម្ពុជា បានអនុម័ត «**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥**» កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ និងបានអនុម័ត «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥**» កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ក៏ដូចជា យុទ្ធសាស្ត្រកែទម្រង់គន្លឹះៗពាក់ព័ន្ធផ្សេងទៀត។ ការអនុវត្ត «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥**» បានជួបប្រទះនូវបញ្ហាប្រឈមចម្បងៗមួយចំនួន រួមមាន៖ ការរីករាលដាលនៃជំងឺកូវីដ-១៩, ការផ្ទុះឡើងនូវសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន, សង្គ្រាមនៅមជ្ឈិមបូព៌ា គួបផ្សំជាមួយនឹងការផ្លាស់ប្តូរយ៉ាងគំហុកនៃគោលនយោបាយរូបិយវត្ថុសកល និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈក្នុងបណ្តាប្រទេសធំៗ ព្រមទាំងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ការគំរាមកំហែងចំពោះអធិបតេយ្យជាតិ និងបូរណភាពទឹកដី, គ្រោះធម្មជាតិផ្សេងៗ, និងតម្រូវការដោះស្រាយសំណូមពររបស់ប្រជាជនគ្រប់ស្រទាប់ ជាពិសេសសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ដែលជាកត្តាចម្បងនាំឱ្យមានការបន្ទុចបង្អាក់ក្នុងការសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០២៥ ពោលគឺ «**បង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ**»។ ជាមួយគ្នានេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវគិតគូរពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ដើម្បីឆ្លើយតបទៅនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាបច្ចុប្បន្នកម្មឆ្នាំ២០២៥-២០២៨, យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០, ព្រមទាំងបន្តដោះស្រាយនូវការងារគន្លឹះៗ

ដែលមិនទាន់សម្រេចបាន និងការងារអាទិភាព ដែលត្រូវគិតគូរបន្ថែមស្របតាមការវិវឌ្ឍនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រនេះ គឺជាការគិតគូរបន្ត និងបន្ថែមការងារអាទិភាពគន្លឹះៗរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ឱ្យកាន់តែស៊ីជម្រៅ ប្រទាក់ក្រឡា គ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពអនុវត្តខ្ពស់ ដោយត្រូវមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។ **ក្នុងដំណាក់កាលទី១ នៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ**, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ និងឈានមុខលើការរៀបចំ បង្កើត និងអនុវត្តការងារគន្លឹះៗ ទាំងលិខិតបទដ្ឋានគតិយុត្ត, គោលការណ៍ណែនាំរួម, នីតិវិធីស្តង់ដាប្រតិបត្តិរួម, ការកសាងស្ថាបនូបនីយកម្ម និងធនធានមនុស្សជាដើម។ **មកដល់ដំណាក់កាលទី២** ឬហៅថា **ដំណាក់កាលនៃយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ក្នុងក្របខ័ណ្ឌឆ្នាំ២០២៥-២០២៨**, ក្រសួង ស្ថាប័ន ត្រូវដើរតួនាទីធំជាងមុន និងសកម្មជាងមុន ក្នុងការរៀបចំកិច្ចសម្របសម្រួលផ្ទៃក្នុង, យន្តការការងារ, ភាពប្រទាក់ក្រឡារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងមន្ទីរជំនាញពាក់ព័ន្ធ, ការរៀបចំគោលការណ៍ និង/ឬ នីតិវិធីស្តង់ដាប្រតិបត្តិលម្អិតតាមវិស័យរបស់ក្រសួង ស្ថាប័ន, និងតាមអង្គភាពរបស់ខ្លួនឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបានប្រកបដោយការទទួលខុសត្រូវ និងម្ចាស់ការ ដោយត្រូវធានាឱ្យបានថា គ្មានការរាំងស្ទះដល់ចលនការអភិវឌ្ឍប្រទេស និយាយជារួម និងការអភិវឌ្ឍវិស័យ និយាយដោយឡែក ដោយការជាប់គាំងនៃគម្រោងវិនិយោគសាធារណៈ នៅដំណាក់កាលណាមួយឡើយ។

ការដាក់ចេញ និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨**» មានគោលបំណងសម្រេចឱ្យបាននូវការបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈដ៏រឹងមាំមួយ ដែលនឹងធ្វើឱ្យមានការប្រែប្រួលសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងអង្គភាពមួយចំនួន, ព្រមទាំងផ្លាស់ប្តូររបៀបរបបបំពេញការងារ ដែលក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធទាំងអស់ចាំបាច់ត្រូវសកម្ម និងម៉ឺងម៉ាត់ជាងមុន ក្នុងគោលដៅបង្កើន និងលើកកម្ពស់ការគ្រប់គ្រងការវិនិយោគសាធារណៈឱ្យកាន់តែឆ្លើយតបនឹងតម្រូវការអាទិភាព, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈប្រកបដោយសមធម៌ និងតម្លាភាព។ ដើម្បីសម្រេចបានគោលបំណង និងគោលដៅខាងលើ, **យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨** បានដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រគន្លឹះៗបន្ទាន់ចំពោះមុខ និងវិធានការជាយុទ្ធសាស្ត្ររយៈពេលមធ្យម ដែលត្រូវមានការចូលរួមអនុវត្តពីគ្រប់តួអង្គពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដូចបានកំណត់នៅក្នុងឯកសារនេះ **ដើម្បីធានាឱ្យបាននូវការកសាងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិនៅមុនដំណាច់ឆ្នាំ២០២៨។**

ជាចុងក្រោយ, ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ព្រមទាំង ឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី និងប្រធានស្ថាប័ន រួមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលបានខិតខំប្រឹងប្រែងយ៉ាងប្តូរផ្តាច់ក្នុងការដឹកនាំ និងសហការអនុវត្តការងារកែទម្រង់គន្លឹះនានារបស់រាជរដ្ឋាភិបាល ជាពិសេស ក្នុងការដ្ឋានកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ប្រកបដោយភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ រហូតទទួលបានសមិទ្ធផលគួរជាទីមោទនៈដូចពេលបច្ចុប្បន្ន។ នាពេលខាងមុខនេះ, ការងារកែទម្រង់ គឺមានលក្ខណៈកាន់តែស៊ីជម្រៅ, ស្មុគស្មាញ, ប្រទាក់ក្រឡា, និងលំបាកជាងមុន ដែលទាមទារឱ្យយើងគ្រប់គ្នា ត្រូវតែបន្តពង្រឹង និងយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងក្លាថែមទៀត ដើម្បីបំពេញសេចក្តីត្រូវការ និងការចង់បានរបស់ប្រជាជន។ ក្នុងន័យនេះ,

ខ្ញុំសូមណែនាំឱ្យក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវតែប្រកាន់យកនូវអភិក្រមអនុវត្តការងារប្រកបដោយគំនិតច្នៃប្រឌិត, ភាពជាអ្នកដឹកនាំ, ឆន្ទៈមោះមុត, ការចូលរួមសហការ និងការសម្របសម្រួលល្អទាំងផ្ទៃក្នុងក្រសួង និងជាមួយតួអង្គពាក់ព័ន្ធនានាឱ្យបានជាប់ជាប្រចាំ។ ទន្ទឹមនេះ, ក្រសួង ស្ថាប័នទាំងអស់ ត្រូវពង្រឹងសមត្ថភាពស្ថាប័ន ដោយបន្តធ្វើវិចារណកម្មមុខងារ និងសម្រិតសម្រាំងមន្ត្រីមានសមត្ថភាព និងគុណវុឌ្ឍិខ្ពស់ ដើម្បីធានាបាននូវប្រសិទ្ធភាពការងារ និងភាពជោគជ័យបន្តទៀត ព្រមទាំងត្រូវប្រកាន់យកនូវគោលការណ៍ និងស្មារតីភ្ញាក់រលឹកខ្ពស់បំផុតក្នុងការកែទម្រង់ជាប្រចាំតាមអភិក្រម **«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»**។

ថ្ងៃ ពុធ ១២កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកានុក្រម

**បញ្ជីអក្សរកាត់**......i
**ជំពូកទី១ សេចក្តីផ្តើម**......១
១.១. សាវតារ......១
១.២. វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥......៣
១.៣. មូលហេតុនាំឱ្យធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ......៣
១.៤. បញ្ហាប្រឈម......៥
**ជំពូកទី២ ចក្ខុវិស័យ**......៦
**ជំពូកទី៣ គោលបំណង និងគោលដៅ**......៧
**ជំពូកទី៤ ក្របខ័ណ្ឌនៃការគ្រប់គ្រងការវិនិយោគសាធារណៈ**......៩
៤.១. បរិការណ៍អន្តរជាតិ......៩
៤.១.១. ក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈ......១០
៤.១.២. ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ......១១
៤.១.៣. និន្នាការសកល......១៤
៤.២. បរិការណ៍កម្ពុជា......១៥
៤.២.១. ក្របខ័ណ្ឌគោលនយោបាយ......១៥
៤.២.២. ក្របខ័ណ្ឌគតិយុត្ត......១៦
៤.២.៣. យន្តការស្ថាប័ន......១៩
៤.២.៤. យន្តការគាំទ្រហិរញ្ញវត្ថុ......២៣
៤.២.៥. គោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ......២៥
៤.៣. បញ្ហាប្រឈម និងកាលានុវត្តភាព......៣០
៤.៣.១. បញ្ហាប្រឈម......៣០
៤.៣.២. កាលានុវត្តភាព......៣៣
**ជំពូកទី៥ វិធានការជាយុទ្ធសាស្ត្រ**......៣៥
៥.១. វិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ (២០២៥-២០២៦)......៣៥
៥.២. វិធានការជាយុទ្ធសាស្ត្ររយៈពេលមធ្យម (២០២៧-២០២៨)......៣៧
**ជំពូកទី៦ ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ**......៣៨
**ជំពូកទី៧ សេចក្តីសន្និដ្ឋាន**......៣៩
**ឧបសម្ព័ន្ធ**......៤០
ឧបសម្ព័ន្ធទី១ សទ្ទានុក្រម......៤១
ឧបសម្ព័ន្ធទី២ ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨......៤៤
ឧបសម្ព័ន្ធទី៣ ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ......១១១

# បញ្ជីអក្សរកាត់

| | |
|---|---|
| MEF | Ministry of Economy and Finance |
| ក.ស.ហ.វ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MPWT | Ministry of Public Works and Transport |
| ក.ស.ក. | ក្រសួងសាធារណការនិងដឹកជញ្ជូន |
| MLMUPC | Ministry of Land Management Urban Planning and Construction |
| ក.ដ.ន.ស. | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MME | Ministry of Mines and Energy |
| ក.រ.ថ. | ក្រសួងរ៉ែនិងថាមពល |
| MRD | Ministry of Rural Development |
| ក.អ.ជ | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MOWRAM | Ministry of Water Resources and Meteorology |
| ក.ធ.ទ.ឧ | ក្រសួងធនធានទឹកនិងឧតុនិយម |
| MOP | Ministry of Planning |
| ក.ផ | ក្រសួងផែនការ |
| MOE | Ministry of Environment |
| ក.ប | ក្រសួងបរិស្ថាន |
| CDC | Council for the Development of Cambodia |
| ក.អ.ក | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| PFMRSC | Public Financial Management Reform Steering Committee |
| គ.ហ.ស. | គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PFMRC | Public Financial Management Reform Commission of the Ministry of Economy and Finance |
| គ.ក.ហ. | គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| GSC | General Secretariat of Public Financial Management Reform Steering Committee |
| អ.គ.ហ. | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| GDICDM | General Department of International Cooperation and Debt Management |
| អ.ស.ប | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល |
| GDP | General Department of Policy |
| អ.គ.ប | អគ្គនាយកដ្ឋានគោលនយោបាយ |
| GDB | General Department of Budget |
| អ.ថ | អគ្គនាយកដ្ឋានថវិកា |
| GDNT | General Department of National Treasury |
| អ.រតនា | អគ្គនាយកដ្ឋានរតនាគារជាតិ |
| GDSNAF | General Department of Sub-National Administration Finance |
| អ.ហ.ក | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ |
| GDPP | General Department of Public Procurement |
| អ.ល.សា | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ |
| GDPPP | General Department of Public-Private Partnerships |
| អ.រ.ជ | អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន |
| GDSPNTR | General Department of State Property and Non-Tax Revenue |
| អ.ទ.ច | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ |

| | |
|---|---|
| GDDE | General Department of Digital Economy |
| អ.ស.ឌ | អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល |
| EFI | Economics and Finance Institute |
| វ.ស.ហ. | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| PAEs | Public Administrative Establishment |
| គ.ស.រ | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| SOEs | State-Owned Enterprise |
| ស.ស.រ | សហគ្រាសសាធារណៈរដ្ឋបាល |
| GDP | Gross Domestic Product |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| CAP | Consolidated Action Plan |
| | ផែនការសកម្មភាពរួម |
| MAP | Ministry Action Plan |
| | ផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន |
| GDAP | General Department Action Plan |
| | ផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| CPAP | Capital and Provincial Action Plan |
| | ផែនការសកម្មភាពលម្អិតរបស់រដ្ឋបាលរាជធានី ខេត្ត |
| ESG | Environmental, Social, and Governance |
| | បរិស្ថាន, សង្គម, និងអភិបាលកិច្ច |
| PIMSRS | The Public Investment Management System Reform Strategy |
| | យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ |

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. សាវតារ

អស់រយៈពេលប្រមាណជាង ២០ ឆ្នាំចុងក្រោយនេះ, រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ ដែលជាកម្មវិធីអាទិភាពមួយក្នុងចំណោមកម្មវិធីកែទម្រង់គន្លឹះៗរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងកែប្រែប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាពី **«ប្រព័ន្ធថវិកាដែលផ្អែកលើធាតុចូល និងមជ្ឈការ»** ឆ្ពោះទៅ **«ប្រព័ន្ធថវិកាដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ»** ព្រមទាំងត្រូវអនុវត្តតាមអភិក្រមជាជំហានៗ តាមដំណាក់កាលចំនួន ៤ គឺៈ (១) **ភាពជឿទុកចិត្តនៃថវិកា** (២០០៥-២០០៨), (២) **គណនេយ្យភាពហិរញ្ញវត្ថុ** (២០០៩-២០១៥), (៣) **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** (២០១៦-២០២២), និង(៤) **គណនេយ្យភាពសមិទ្ធកម្ម** (២០២៣-២០២៧)។ នៅក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សេដ្ឋកិច្ចកម្ពុជារក្សាបាននូវកំណើនក្នុងអត្រាជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ជារៀងរាល់ឆ្នាំ នៅមុនវិបត្តិនៃជំងឺកូវីដ-១៩ ដោយបានប្រែក្លាយកម្ពុជា ពីប្រទេសមានចំណូលទាប មកជាប្រទេសចំណូលមធ្យមកម្រិតទាប នៅក្នុងឆ្នាំ២០១៥ និងកំពុងត្រៀមខ្លួនចាកចេញពីក្រុមប្រទេសដែលមានការអភិវឌ្ឍតិចតួច ព្រមទាំងបន្តដំណើរយ៉ាងសកម្មឥតឈប់ឈរ ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យក្នុងការប្រែក្លាយកម្ពុជា ទៅជា ប្រទេសចំណូលខ្ពស់ នៅឆ្នាំ២០៥០។

ទន្ទឹមនេះ, អំឡុងពេលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលជាសារវន្តតាមខឿន និងដំណាក់កាលនីមួយៗ ដែលបានកសាង និងកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យកាន់តែរឹងមាំ និងមានភាពធន់នឹងវិបត្តិ ដោយក្នុងនោះៈ ដំណាក់កាលទី១ «**ភាពជឿទុកចិត្តនៃថវិកា**» បានដោះស្រាយនូវវិបត្តិបំណុលសាច់ប្រាក់រ៉ាំរ៉ៃ និងបានប្រមូលផ្តុំគណនីទាំងអស់ ទៅជា គណនីតែមួយ ប្រកបដោយភាពជោគជ័យ តាមរយៈការអនុវត្តនូវប្រព័ន្ធគណនីទោលរតនាគារ ព្រមទាំងបានធ្វើទំនើបកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងឆ្នាំ២០០៨ ផងដែរ។ ដំណាក់កាលទី២ «**គណនេយ្យភាពហិរញ្ញវត្ថុ**» សម្រេចបាននូវសមិទ្ធផលគន្លឹះៗមួយចំនួន ដូចជាៈ ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារ, ការពង្រីកអង្គភាពសវនកម្មផ្ទៃក្នុង, ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), និងអនុវត្តសាកល្បងនូវប្រព័ន្ធថវិកាកម្មវិធីនៅតាមក្រសួង ស្ថាប័នមួយចំនួន។ ជាមួយគ្នានេះ, ដំណាក់កាលទី៣ **«ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ»** ត្រូវបានអនុវត្តប្រកបដោយជោគជ័យ និងសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈផងដែរ តាមរយៈកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់អគ្គនាយកដ្ឋាន/អង្គភាពក្រោមចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ព្រមទាំងពង្រីក និងពង្រឹងការអនុវត្តថវិកាកម្មវិធី ក៏ដូចជាការកែលម្អប្រព័ន្ធគណនេយ្យសាធារណៈ និងប្រព័ន្ធសវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុ, ជាពិសេស ការចាប់ផ្តើមដាក់ឱ្យអនុវត្តជាជំហានៗនូវ FMIS។ សមិទ្ធផលនៃដំណាក់កាលទី៣នេះ រាជរដ្ឋាភិបាលបានអនុម័ត «**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥**», «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥**» ព្រមទាំងយុទ្ធសាស្ត្រកែទម្រង់ផ្សេងទៀត ដែលជាមូលដ្ឋានគ្រឹះនៃការកសាង «**ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម**» ផងដែរ។ ទន្ទឹមនឹងការអនុវត្តយុទ្ធសាស្ត្រ

ស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ និងនៅក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ពិភពលោក និងកម្ពុជាបានជួបប្រទះនូវបញ្ហានៃការរីករាលដាលជំងឺកូវីដ-១៩ និងភាពស្មុគស្មាញផ្សេងទៀត ដែលបង្កឡើងដោយសារសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន, សង្គ្រាមនៅមជ្ឈិមបូព៌ា គួបផ្សំជាមួយនឹងការផ្លាស់ប្ដូរយ៉ាងគំហុកនៃគោលនយោបាយរូបិយវត្ថុសកលនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈក្នុងបណ្ដាប្រទេសធំៗ ព្រមទាំងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ការគំរាមកំហែងចំពោះអធិបតេយ្យជាតិ និងបូរណភាពទឹកដី, គ្រោះធម្មជាតិផ្ទួនៗ, និងតម្រូវការដោះស្រាយសំណូមពររបស់ប្រជាជនគ្រប់ស្រទាប់ ជាហេតុនាំឱ្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ត្រូវអនុវត្តរយៈពេលប្រមាណ ៧ ឆ្នាំ គឺយូរជាងរយៈពេលដែលកំណត់ដំបូងចំនួន ២ ឆ្នាំ និងនាំឱ្យមានការរៀបចំ «**ផែនការសកម្មភាពលម្អិតបច្ចុប្បន្នកម្ម ២០២២-២០២៥ សម្រាប់អនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥**» ផងដែរ។ ផែនការសកម្មភាពលម្អិតបច្ចុប្បន្នកម្ម ២០២២-២០២៥ គឺមានការចូលរួមយ៉ាងសកម្មពីអគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធគន្លឹះៗ ស្ថិតក្រោមចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នមួយចំនួន ដើម្បីគាំទ្រការអនុវត្ត «**យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥**» ព្រមទាំងការដាក់ផែនការសកម្មភាពលម្អិតរបស់អគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (GDAP 4) និងផែនការសកម្មភាពលម្អិតរបស់ក្រសួង ស្ថាប័ន (MAP 4) ពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ។ ក្នុងនោះ, ការងារគន្លឹះភាគច្រើនបានផ្ដោតសំខាន់លើការរៀបចំអនុក្រឹត្យ (អនុក្រឹត្យស្ដីពីការគ្រប់គ្រងការវិនិយោគសាធារណៈ និងអនុក្រឹត្យស្ដីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល) និងគោលការណ៍ណែនាំរួមពាក់ព័ន្ធផ្សេងទៀតជាដើម ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ។

ក្នុងដំណាក់កាលបច្ចុប្បន្ននេះ, ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិតនៅក្នុងដំណាក់កាលទី៤ «**គណនេយ្យភាពសមិទ្ធកម្ម**» ដែលជាដំណាក់កាលចុងក្រោយ និងបានសម្រេចនូវសមិទ្ធផលជាបណ្ដើរៗគួរឱ្យកត់សម្គាល់ ដូចជា៖ ១)ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣, ២)ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០២៣, ៣)ច្បាប់ស្ដីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ឆ្នាំ២០២១, ៤)ក្របខ័ណ្ឌគោលនយោបាយស្ដីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣-២០២៨, ៥)យុទ្ធសាស្ត្រស្ដីពីការកៀរគរចំណូល នីតិកាលទី៧ នៃរដ្ឋសភា, ៦)យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤-២០២៨, ៧)យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨, ៨)យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈបច្ចុប្បន្នកម្មឆ្នាំ២០២៥-២០២៨, ៩)ផែនការគោលស្ដីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ២០២៥-២០៣៥, ១០)ផែនទីបង្ហាញផ្លូវស្ដីពីការគ្រប់គ្រងចំណាយកកស្ទះ ២០២៥-២០២៨, ១១)ផែនការយុទ្ធសាស្ត្របច្ចុប្បន្នកម្មស្ដីពីការកសាងសមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤, ១២)ក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចរបស់រាជរដ្ឋាភិបាល ឆ្នាំ២០២៥, និង១៣)ផែនការសកម្មភាពរួមដំណាក់កាលទី៤ បច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៧ ព្រមទាំងការងារពាក់ព័ន្ធគន្លឹះៗផ្សេងទៀត។

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**» ដើម្បីធានាបាននូវ**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** សំដៅបន្តរក្សាឱ្យបានភាពរឹងមាំនៃចលនការដែលបានកំណត់យកអាទិភាពគន្លឹះ ៥ គឺ៖ **មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យា** ជាពិសេស គឺ «**បច្ចេកវិទ្យាឌីជីថល**» សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ព្រមទាំងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និងមធ្យោបាយដ៏សំខាន់ក្នុងការ

សម្រេចនូវ «**ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**»។ ដើម្បីរួមចំណែកក្នុងការគាំទ្រ និងសម្រេចឱ្យបាននូវទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ក្នុងក្របខ័ណ្ឌឆ្នាំ២០២៥-២០២៨ ស្របតាមទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ និង «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**» ដើម្បីឱ្យការកែទម្រង់កាន់តែមានភាពប្រទាក់ក្រឡាគ្នា និងគ្រប់ជ្រុងជ្រោយ។ ការដាក់ចេញ និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨**» មានគោលដៅបង្កើននិងលើកកម្ពស់ការគ្រប់គ្រងការវិនិយោគសាធារណៈឱ្យកាន់តែឆ្លើយតបនឹងតម្រូវការជាអាទិភាព, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈប្រកបដោយសមធម៌ និងតម្លាភាព ជាពិសេស ក្នុងដំណាក់កាលនៃការធ្វើបច្ចុប្បន្នកម្មនេះ ក្រសួង ស្ថាប័ន ត្រូវផ្តោតលើការរៀបចំគោលការណ៍ណែនាំលម្អិត ឬ នីតិវិធីស្តង់ដាប្រតិបត្តិតាមវិស័យ ដើម្បីពង្រឹងប្រសិទ្ធភាព និងគណនេយ្យភាពក្នុងការងារការគ្រប់គ្រងការវិនិយោគសាធារណៈរបស់ខ្លួន។

## ១.២. វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥

អស់រយៈពេលជាង ៦ ឆ្នាំនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ បានឆ្លុះបញ្ចាំងឱ្យឃើញពីសន្ទុះវឌ្ឍនភាពនៃការដ្ឋានកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ដោយនៅក្នុងដំណាក់កាលទី១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត (មានទាំងច្បាប់, អនុក្រឹត្យ, ប្រកាស, និងគោលការណ៍ណែនាំនានា), យុទ្ធសាស្ត្រគន្លឹះៗពាក់ព័ន្ធ, ការកសាងស្ថាបនូបនីយកម្ម, ការកំណត់តួនាទីស្ថាប័ន, យន្តការ និងនីតិវិធីស្តង់ដាប្រតិបត្តិ, ការពង្រឹង ពង្រីក និងកសាងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងការរៀបចំកសាងប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមប្រភពហិរញ្ញប្បទានមួយចំនួនផងដែរ។

ទន្ទឹមនឹងវឌ្ឍនភាពគន្លឹះសម្រេចបានខាងលើ, ក្នុងនោះ ក្រសួង ស្ថាប័នពាក់ព័ន្ធក៏សម្រេចបាននូវសមិទ្ធផលជាមូលដ្ឋានមួយចំនួនដូចជា ការដាក់ចេញនូវក្រមបរិស្ថាន និងធនធានធម្មជាតិ, ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត, ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក, ច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់, អនុក្រឹត្យស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល, គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល, យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន, ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្មជា ព្រមទាំងឯកសារគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នជំនាញ។

## ១.៣. មូលហេតុនាំឱ្យធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ

ការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ គ្រោងបញ្ចប់នៅដំណាច់ឆ្នាំ២០២៥។ ប៉ុន្តែដោយសារតែអំឡុងពេលនៃការអនុវត្តយុទ្ធសាស្ត្រនេះ បានជួបប្រទះនូវបញ្ហាចម្បងៗមួយចំនួនរួមទាំងកត្តាធនធានមនុស្ស កត្តាស្ថាប័ន និងការពន្យារពេលអនុវត្តសកម្មភាពគន្លឹះមួយចំនួននៃផែនការសកម្មភាពនៅក្នុងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ជាកត្តាចម្បងនាំឱ្យមានការបន្ទចបង្អាក់ក្នុងការសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០២៥ ក្នុងការ «**បង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ**»។

ទន្ទឹមនេះ, ដោយមានភាពចាំបាច់ គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានណែនាំឱ្យមានការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ និងផែនការសកម្មភាពលម្អិត សម្រាប់បន្តអនុវត្តការងារកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ ឱ្យស្របតាមទិសដៅនៃ**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ដំណាក់កាលទី៤ «**គណនេយ្យភាពសមិទ្ធកម្ម**» ដែលត្រូវបានពន្យារពេលអនុវត្តរហូតដល់ឆ្នាំ២០២៧, ស្របទៅនឹង «**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨**», ព្រមទាំង «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**» ជាពិសេស ដើម្បីរួមចំណែកក្នុងការសម្រេចបាននូវ «**ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**»។ ការណ៍នេះ ទាមទារឱ្យមានការចូលរួមឱ្យបានសកម្មជាងមុនពីក្រសួង ស្ថាប័នគនីះៗ ព្រមទាំងតួអង្គពាក់ព័ន្ធនានា ដើម្បីជានាបាននូវភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នានៃការអនុវត្តការងាររវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្នុងដំណាក់កាលទី២ នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តគិតគូរ និងជំរុញការងារអាទិភាពគន្លឹះៗឱ្យកាន់តែស៊ីជម្រៅ ប្រទាក់ក្រឡា គ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព ពោលគឺក្នុងដំណាក់កាលថ្មីនេះ ក្រសួង ស្ថាប័ន ត្រូវដើរតួនាទីធំជាងមុន និងសកម្មជាងមុន ក្នុងការរៀបចំកិច្ចសម្របសម្រួលផ្ទៃក្នុង, យន្តការការងារ, ភាពប្រទាក់ក្រឡារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងមន្ទីរជំនាញពាក់ព័ន្ធ, ការរៀបចំគោលការណ៍ ឬ នីតិវិធីស្តង់ដាប្រតិបត្តិលម្អិតតាមវិស័យរបស់ក្រសួង ស្ថាប័ន និងតាមអង្គភាពជំនាញរបស់ខ្លួន ឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបានប្រកបដោយការទទួលខុសត្រូវ និងម្ចាស់ការ ដោយត្រូវធានាឱ្យបានថាគ្មានការរាំងស្ទះដល់ចលនការអភិវឌ្ឍប្រទេស និយាយជារួម និងការអភិវឌ្ឍវិស័យ និយាយដោយឡែក ដោយការជាប់គាំងនៃគម្រោងវិនិយោគសាធារណៈ នៅដំណាក់កាលណាមួយឡើយ។

បន្ថែមពីនេះ, «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨**» ពិតជាមានសារៈសំខាន់ណាស់ក្នុងការបន្តកសាងនូវលិខិតបទដ្ឋានគតិយុត្ត, គោលការណ៍ណែនាំ និងនីតិវិធីស្តង់ដាប្រតិបត្តិលម្អិតតាមវិស័យឱ្យមានលក្ខណៈគ្រប់គ្រាន់, បន្តពង្រឹងស្ថាបនូបនីយកម្ម និងកំណត់តួនាទី និងការទទួលខុសត្រូវរបស់តួអង្គនីមួយៗឱ្យកាន់តែច្បាស់លាស់ជាងមុន ទាំងកម្រិតគោលនយោបាយ យុទ្ធសាស្ត្រ និងកម្រិតប្រតិបត្តិ ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងការគិតគូរពីនិរន្តរភាពបរិស្ថាន ភាពធន់នឹងបម្រែបម្រួលអាកាសធាតុ និងចីរភាពនៃការអភិវឌ្ឍផងដែរ។

ផ្អែកតាមមូលដ្ឋានខាងលើ និងបរិការណ៍អភិវឌ្ឍន៍កម្ពុជានៅក្នុងដំណាក់កាលថ្មី, រាជរដ្ឋាភិបាលពិនិត្យឃើញពីភាពចាំបាច់ ដែលត្រូវតែមាន «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨**» ក្រោមក្របខ័ណ្ឌ «**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ដោយដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រ ក្នុងគោលដៅបន្ត៖

១) គាំទ្រ និងជំរុញចីរភាពនៃកំណើនសេដ្ឋកិច្ច, ពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង។

២) បំពេញតម្រូវការទុនវិនិយោគសាធារណៈ ដែលកាន់តែរីកធំឡើង។

៣) ធានានូវការប្រើប្រាស់ធនធានវិនិយោគចំទិសដៅឆ្លើយតបនឹងតម្រូវការអាទិភាពពិតប្រាកដ។

៤) ឆ្លើយតបនឹងតម្រូវការសេវាសាធារណៈ និងធានាបាននូវសមធម៌សង្គម។

ក្នុងន័យនេះ «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨**» ត្រូវបានរៀបចំឡើងស្របតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងឧត្តមានុវត្តន៍ជាអន្តរជាតិ ដែលនឹងដាក់ចេញនូវ៖

១) វិធានការជាយុទ្ធសាស្ត្រ ដើម្បីសម្រេចឱ្យបាននូវការកសាងក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន, និងយន្តការគាំទ្រហិរញ្ញវត្ថុឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព។
២) ផែនការសកម្មភាពឱ្យកាន់តែស៊ីជម្រៅ, មុតស្រួច, គ្រប់ជ្រុងជ្រោយ, និងប្រទាក់ក្រឡាគ្នា ដោយកំណត់ឱ្យបានច្បាស់លាស់នូវស្ថាប័នដឹកនាំ និងស្ថាប័នទទួលខុសត្រូវ ព្រមទាំងត្រូវមានក្របខ័ណ្ឌពេលវេលាអនុវត្តជាក់លាក់។

យុទ្ធសាស្ត្រនេះ ត្រូវបានចាត់ទុកជា «**ឯកសាររស់**» ដែលអាចនឹងត្រូវកែសម្រួលជាយថាហេតុ ដើម្បីធានាសង្គតិភាពទៅតាមវឌ្ឍនភាពនៃបរិការណ៍ជាក់ស្តែងនៅកម្ពុជា។

## ១.៤. បញ្ហាប្រឈម

អំឡុងពេលនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ មានបញ្ហាប្រឈមមួយចំនួន ដែលបានជួបប្រទះ ហើយនៅសេសសល់ ដែលត្រូវខិតខំបន្តដោះស្រាយ រួមមាន៖

- ប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងការវិនិយោគសាធារណៈ មិនទាន់មានលក្ខណៈប្រមូលផ្តុំរួមនៅឡើយ ទាំងក្រសួងសម្របសម្រួល (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ) និងទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ (ពីគ្រប់ប្រភពហិរញ្ញប្បទាន)
- យន្តការសម្របសម្រួលផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន នៅមានកម្រិត
- ការសម្របសម្រួលរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅមានកម្រិត
- លិខិតបទដ្ឋានគតិយុត្ត, គោលការណ៍ណែនាំ, នីតិវិធីស្តង់ដាប្រតិបត្តិ ឬ យន្តការទាមទារឱ្យមានគិតគូររៀបចំ ពិនិត្យឡើងវិញ ឬ ធ្វើបច្ចុប្បន្នកម្ម (ដូចជាការគិតគូរពីបម្រែបម្រួលអាកាសធាតុ និងលក្ខខណ្ឌតម្រូវនានា ជាដើម)
- ការចូលរួមរបស់ក្រសួង ស្ថាប័ន ក្នុងការដាក់ផែនការសកម្មភាពលម្អិតសម្រាប់គាំទ្រការគ្រប់គ្រងការវិនិយោគសាធារណៈ នៅមានកម្រិតតិចតួច
- ការកសាង និងពង្រឹងសមត្ថភាពតួអង្គ និងការយល់ដឹង នៅមានកម្រិតក្នុងការដ្ឋានកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ។

# ជំពូកទី២
# ចក្ខុវិស័យ

# ជំពូកទី២
# ចក្ខុវិស័យ

នៅមុនដំណាច់ឆ្នាំ២០២៨ រាជរដ្ឋាភិបាលត្រូវបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ ដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

# ជំពូកទី៣
# គោលបំណង និងគោលដៅ

# ជំពូកទី៣
# គោលបំណង និងគោលដៅ

យុទ្ធសាស្ត្របច្ចុប្បន្នកម្មនេះ មានគោលបំណងកំណត់ក្របខ័ណ្ឌទស្សនាទានរួមមួយ ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ដោយរួមបញ្ចូលការគិតគូរពីការវិនិយោគបៃតង និងបម្រែបម្រួលអាកាសធាតុ (ទាំងពីប្រភពថវិកាជាតិ, ហិរញ្ញប្បទានក្រៅប្រទេស, ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈ ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន, ហិរញ្ញប្បទានចម្រុះ, ហិរញ្ញប្បទានដោយការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ, ហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម, និងប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងៗទៀត), និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ, ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ, សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈរដ្ឋបាល, និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសមធម៌សង្គម។

ដើម្បីសម្រេចបាននូវគោលបំណង និងចក្ខុវិស័យខាងលើ យុទ្ធសាស្ត្រនេះមានគោលដៅ៖

១) បន្តពិនិត្យមើលឡើងវិញ និងធ្វើបច្ចុប្បន្នកម្មក្របខ័ណ្ឌគតិយុត្ត សម្រាប់ធ្វើឱ្យមានសង្គតិភាពកម្រិតគោលការណ៍នៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដោយរួមបញ្ចូលការគិតគូរពីការវិនិយោគបៃតង និងបម្រែបម្រួលអាកាសធាតុ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោងពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងពីប្រភពថវិកាជាតិ, ហិរញ្ញប្បទានក្រៅប្រទេស, ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈក្រោមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន, ហិរញ្ញប្បទានចម្រុះ, ហិរញ្ញប្បទានដោយការធ្វើឯកជន-ភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ, ហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម, និងប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងៗទៀត) និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ, ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ, សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈរដ្ឋបាល, និងអង្គភាពសាធារណៈប្រហាក់ប្រហែល)។

២) បន្តពង្រឹងការធ្វើអាទិភាវូបនីយកម្មវិនិយោគសាធារណៈ៣ឆ្នាំរំកិល, ការធ្វើផែនការនីយកម្មនៃការវិនិយោគសាធារណៈ និងការធ្វើសមាហរណកម្មថវិកាវិនិយោគសាធារណៈពីប្រភពថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍន៍ ព្រមទាំងរវាងថវិកាចរន្ត ជាមួយថវិកាមូលធន និងគោលការណ៍ណែនាំសម្រាប់រៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។

៣) បន្តពង្រឹងការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកានៅថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនង ប្រទាក់ក្រឡា និងបំពេញគ្នាទៅវិញទៅមករវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងតម្រឹមជាមួយផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត ដើម្បីសម្រេចគោលបំណងរួម។ ការធ្វើសមាហរណកម្មនៃផែនការនីយកម្ម គឺជាការគ្រោងផែនការសកម្មភាពមានលក្ខណៈប្រមូលផ្តុំ ដើម្បីតម្រង់ទិស បែងចែកមុខងារ និងកំណត់ការទទួលខុសត្រូវឱ្យបានច្បាស់លាស់។

៤) បន្តពង្រឹងគុណភាព ប្រសិទ្ធភាពអនុវត្ត និងភាពផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈ ជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ។

៥) បន្តពង្រឹងយន្តការស្ថាប័ន ជាពិសេស យន្តការសម្របសម្រួលផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន ព្រមទាំងយន្តការសម្របសម្រួលការវិនិយោគសាធារណៈរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់គ្រប់គ្រង

ការវិនិយោគសាធារណៈ ក្នុងដំណាក់កាលអាទិភាវូបនីយកម្ម និងផែនការនីយកម្ម, ការសិក្សាវាយតម្លៃ និងរៀបចំសំណើគម្រោង, ពិនិត្យវាយតម្លៃលើសំណើគម្រោង, ជ្រើសរើសគម្រោង និងថវិកានីយកម្ម គម្រោងវិនិយោគសាធារណៈ, តាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង, និងវាយតម្លៃក្រោយបញ្ចប់ការអនុវត្តគម្រោង ដោយរួមបញ្ចូលការគិតគូរពីការវិនិយោគបៃតង និងបម្រែបម្រួលអាកាសធាតុ។

៦) ធ្វើបច្ចុប្បន្នកម្មឯកសារណែនាំស្ដីពីគោលការណ៍ និងនីតិវិធីស្តង់ដាប្រតិបត្តិនៃគម្រោងវិនិយោគសាធារណៈតាមប្រភពនីមួយៗសម្រាប់គ្រប់ដំណាក់កាលនៃវដ្តគម្រោង ដោយរួមបញ្ចូលការគិតគូរពីការវិនិយោគបៃតង និងបម្រែបម្រួលអាកាសធាតុ។

# ជំពូកទី៤
# ក្របខ័ណ្ឌនៃការគ្រប់គ្រង
# ការវិនិយោគសាធារណៈ

# ជំពូកទី៤
# ក្របខ័ណ្ឌនៃការគ្រប់គ្រងការវិនិយោគសាធារណៈ

ការវិនិយោគសាធារណៈ សំដៅដល់ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាសាធារណៈ សម្រាប់គម្រោងនីមួយៗ ទាំងក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានចែកចេញជា ២ ប្រភេទគឺ៖ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចដូចជា ផ្លូវថ្នល់, ប្រព័ន្ធធារាសាស្ត្រ, ស្ពាន, អាកាសយានដ្ឋាន, កំពង់ផែ។ល។ និងហេដ្ឋារចនាសម្ព័ន្ធសង្គមដូចជា សាលារៀន, មន្ទីរពេទ្យ, មណ្ឌលសុខភាព ជាដើម។ ការវិនិយោគសាធារណៈ អាចត្រូវបានហិរញ្ញប្បទានដោយ៖ ១)គម្រោងហិរញ្ញប្បទានដោយថវិកាជាតិ, ២)គម្រោងហិរញ្ញប្បទានក្រៅប្រទេស, ៣)គម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន, ៤)គម្រោងវិនិយោគសាធារណៈដោយប្រភពហិរញ្ញប្បទានចម្រុះ, ៥)គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយការធ្វើឯកជន-ភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ, ៦)គម្រោងវិនិយោគសាធារណៈដោយសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលដទៃទៀត, ៧)គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម, និង៨)គម្រោងវិនិយោគសាធារណៈដោយប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងៗទៀត។ ការវិនិយោគសាធារណៈ ដែលតម្រូវឱ្យមានការសាងសង់ ការធ្វើទំនើបកម្ម ឬ ការស្តារនីតិសម្បទាហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានហិរញ្ញប្បទានដោយថវិកាមូលធនក្នុងដំណាក់កាលសាងសង់ និងហិរញ្ញប្បទានដោយថវិកាចរន្តក្នុងដំណាក់កាលប្រតិបត្តិការ និងថែទាំ ដោយកិច្ចវិនិយោគនឹងត្រូវអនុវត្តដោយរួមបញ្ចូលការគិតគូរទៅលើបរិស្ថានដែលពាក់ព័ន្ធនឹងយន្តការបៃតង និងបម្រែបម្រួលអាកាសធាតុ សង្គម និងអភិបាលកិច្ច (ESG)។

ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ សំដៅដល់ប្រព័ន្ធគ្រប់គ្រងចំណាយលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងប្រើប្រាស់ធនធានប្រកបដោយភាពប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមករវាង៖

១) **ការរៀបចំ និងគ្រប់គ្រងផែនការវិនិយោគសាធារណៈ** ឆ្លើយតបនឹងតម្រូវការអាទិភាព សម្រាប់ការអភិវឌ្ឍជាតិរយៈពេលមធ្យម។

២) **ការគ្រប់គ្រងថវិកា** សំដៅធានាឱ្យការវិភាជថវិកាវិនិយោគ ត្រូវបានធ្វើឡើងដោយឆ្លើយតប និងអនុលោមតាមក្របខ័ណ្ឌថវិការយៈពេលមធ្យម និងត្រូវបានគិតគូរជាមួយនឹងការរៀបចំថវិកាចរន្តសម្រាប់ចំណាយប្រតិបត្តិការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

៣) **ការរៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង** សំដៅធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

## ៤.១. បរិការណ៍អន្តរជាតិ

តាមការអនុវត្តជាសកល, វដ្តនៃគម្រោងវិនិយោគសាធារណៈ ត្រូវបានបែងចែកជា ៨ ដំណាក់កាល រួមមាន៖ ១)ការធ្វើអត្តសញ្ញាណកម្ម និងរៀបចំសំណើគម្រោងបឋម, ២)ការសិក្សាសមិទ្ធិលទ្ធភាព វាយតម្លៃ និងរៀបចំសំណើគម្រោងផ្លូវការ, ៣)ការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង, ៤)ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម, ៥)ការគ្រប់គ្រង និងអនុវត្តគម្រោង, ៦)ការកែសម្រួលគម្រោង, ៧)ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមក្របខ័ណ្ឌគម្រោង, និង៨)ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង។ ទន្ទឹមនេះ, ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈត្រូវមានសមាសធាតុជាសារវន្តចំនួន ៦ រួមមាន៖ ក្របខ័ណ្ឌគោលនយោបាយ, ក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន, គោលការណ៍ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, យន្តការគាំទ្រហិរញ្ញវត្ថុ, និងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន។

ការរៀនសូត្រដកពិសោធន៍ និងវិភាគលើបរិការណ៍សកល នឹងផ្តល់ជាមូលដ្ឋានសម្រាប់ការគិតគូរ និងរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់កម្ពុជា។ ក្នុងន័យនេះ, ផ្នែកបទពិសោធជាអន្តរជាតិនឹងផ្តោតជាសំខាន់លើ៖ ១)ក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈ, ២)ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ, និង៣)និន្នាការសកល។

## ៤.១.១. ក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈ

ជាសត្យានុម័ត, ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ និងបណ្តាប្រទេសជាច្រើនលើពិភពលោកបានអនុវត្ត និងទទួលស្គាល់ថា ដើម្បីកសាងឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ដែលមានភាពពេញលេញ, គ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពនៅក្នុងប្រទេសមួយ ចាំបាច់ត្រូវបង្កើតឡើងដោយសមាសធាតុគន្លឹះ ជាអាទិ៍៖

- **ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត**

ក្របខ័ណ្ឌគោលនយោបាយ គឺជាឯកសារគោលនយោបាយជាតិ ដែលដាក់ចេញនូវចក្ខុវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលមធ្យម និង/ឬ វែងរបស់រាជរដ្ឋាភិបាល ដោយបានកំណត់នូវ៖ គោលដៅគោលនយោបាយ, វិស័យអាទិភាពសំខាន់ៗ, និងតម្រូវការវិនិយោគសាធារណៈសរុប។ ក្របខ័ណ្ឌគោលនយោបាយ គឺជាមូលដ្ឋានសម្រាប់រៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ, ក្របខ័ណ្ឌថវិកា, និងផែនការ ឬ កម្មវិធីវិនិយោគសាធារណៈរយៈពេលមធ្យមរបស់ប្រទេស។ ក្របខ័ណ្ឌគោលនយោបាយត្រូវបានរៀបចំឡើង ដើម្បីតម្រង់ទិសយុទ្ធសាស្ត្រ និងសកម្មភាពតាមវិស័យនៃក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នានៃការវិនិយោគសាធារណៈតាមវិស័យ ដើម្បីសម្រេចគោលបំណងរួមរបស់រដ្ឋាភិបាល ព្រមទាំងផ្តល់នូវភាពអាចប៉ាន់ប្រមាណបាននៃតម្រូវការទុន និងលទ្ធភាពធនធានវិនិយោគសាធារណៈ ដែលត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការរៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន។

ក្របខ័ណ្ឌគតិយុត្ត ត្រូវបានបញ្ញត្តនូវវិធានជាសារវន្តសម្រាប់ការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ ដោយកំណត់នូវយន្តការស្ថាប័ន, នីតិវិធីគ្រប់គ្រងប្រតិបត្តិ, និងគោលការណ៍ណែនាំលម្អិត សម្រាប់ធានាបាននូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈក្នុងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

ប្រទេសមួយចំនួនបានអនុម័ត និងដាក់ឱ្យប្រើជាច្បាប់ស្តីពីការវិនិយោគសាធារណៈតែម្តង ប៉ុន្តែក៏មានប្រទេសមួយចំនួនទៀតដាក់ឱ្យប្រើត្រឹមកម្រិតលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមទាបជាងច្បាប់ ដើម្បីរក្សាបាននូវភាពទន់ភ្លន់ បត់បែន និងសមស្របទៅនឹងបរិការណ៍ជាក់ស្តែងនៃការអនុវត្តគម្រោងវិនិយោគសាធារណៈនៅក្នុងប្រទេសរៀងៗខ្លួន។

- **យន្តការស្ថាប័ន**

តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងវដ្តរបស់គម្រោង គិតចាប់ពីដំណាក់កាលធ្វើអត្តសញ្ញាណកម្មគម្រោង រហូតដល់ដំណាក់កាលវាយតម្លៃបញ្ចប់គម្រោង ចាំបាច់ត្រូវកំណត់ និងបែងចែកឱ្យបានច្បាស់លាស់រវាងមុខងារធំៗចំនួន ៧ រួមមាន៖

១) **មុខងារធ្វើអត្តសញ្ញាណកម្ម, រៀបចំ, និងគ្រប់គ្រងការអនុវត្តគម្រោង៖** ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នជំនាញតាមវិស័យ ក្នុងការកំណត់អត្តសញ្ញាណគម្រោងដែលត្រូវវិនិយោគ និងរៀបចំគម្រោងឱ្យឆ្លើយតបនឹងក្របខ័ណ្ឌគោលនយោបាយ, គោលបំណងរួមនៃផែនការអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។ ការធ្វើអត្តសញ្ញាណកម្ម និងរៀបចំគម្រោង ត្រូវធ្វើឡើងដោយផ្អែកតាម «**គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណកម្ម និងរៀបចំគម្រោង**» ដែលត្រូវបានដាក់ឱ្យអនុវត្តដោយរដ្ឋាភិបាល។

២) **មុខងាររៀបចំបញ្ជីគម្រោងអាទិភាព៖** ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ដែលទទួលបន្ទុកលើកិច្ចការរៀបចំផែនការសេដ្ឋកិច្ច និង/ឬ វិនិយោគ ដោយត្រូវដឹកនាំការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការដាក់បញ្ចូលគម្រោងវិនិយោគសាធារណៈ ដែលមានសក្តានុពលទៅក្នុងបញ្ជីគម្រោងអាទិភាពរបស់រដ្ឋាភិបាល។

៣) **មុខងារពិនិត្យ និងអនុម័តលើបញ្ជីគម្រោងអាទិភាព៖** ជាសមត្ថកិច្ចរបស់ប្រមុខរដ្ឋាភិបាល ដែលជាទូទៅត្រូវប្រើប្រាស់យន្តការកិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រី។

៤) **មុខងារពិនិត្យ និងវាយតម្លៃលើសំណើគម្រោង៖** ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ក្នុងការពិនិត្យមើលឡើងវិញ ដើម្បីធានាអនុលោមភាពនៃសំណើគម្រោងទៅនឹង **«គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណកម្ម និងរៀបចំគម្រោង»**, ការពិនិត្យលើថ្លៃ និងហានិភ័យគម្រោង, យន្តការគ្រប់គ្រង និងអនុវត្តគម្រោង ព្រមទាំងកំណត់នូវវិធានការចាំបាច់នានា ដើម្បីកែតម្រូវ និងគ្រប់គ្រងហានិភ័យគម្រោង។

៥) **មុខងារជ្រើសរើសគម្រោង និងថវិកានីយកម្ម៖** ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ក្នុងការជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាព ដើម្បីធ្វើថវិកានីយកម្ម ក្នុងគោលដៅធានានូវភាពឆ្លើយតបនឹងតម្រូវការជាអាទិភាព, ប្រសិទ្ធភាពសេដ្ឋកិច្ច, សមធម៌សង្គម, លទ្ធភាពនៃថវិកា, ភាពរួចរាល់នៃការចាប់ផ្តើមអនុវត្ត, និងភាពដែលអាចអនុវត្តបាន។

៦) **មុខងារតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង៖** ជាទូទៅជាសមត្ថកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ក្នុងការតាមដានត្រួតពិនិត្យលើការគ្រប់គ្រងនិងអនុវត្តគម្រោង និងវាយតម្លៃអនុលោមភាពតាមវិធាន, គោលការណ៍, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិ ក្នុងគោលដៅធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការប្រើប្រាស់ធនធានសាធារណៈ។

៧) **មុខងារវាយតម្លៃក្រោយបញ្ចប់គម្រោង៖** ជាទូទៅសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នគ្រប់គ្រងការអនុវត្តគម្រោង ឬ ភាគីទី៣ ដែលជាស្ថាប័នឯករាជ្យ ក្នុងគោលដៅដកស្រង់មេរៀន និងបទពិសោធ ព្រមទាំងផ្តល់នូវអនុសាសន៍សំខាន់ៗ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការរៀបចំ និងការអនុវត្តគម្រោងវិនិយោគសាធារណៈនាពេលអនាគត។

- **យន្តការគាំទ្រហិរញ្ញវត្ថុ**

យន្តការគាំទ្រហិរញ្ញវត្ថុនៃការវិនិយោគសាធារណៈ មានគោលបំណងផ្តល់ការគាំទ្រហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នជំនាញ ដែលអាចមានចាប់ពីដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាព រហូតដល់ការប្រគល់កិច្ចសន្យា ប៉ុន្តែការរៀបចំយន្តការនេះអាស្រ័យលើសមត្ថភាពស្ថាប័ន, លទ្ធភាពនៃថវិកា, និងបរិការណ៍ជាក់ស្តែងរបស់ប្រទេសនីមួយៗ។ ប្រទេសមួយចំនួន ជាពិសេស ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន អាចមានលទ្ធភាពវិភាជថវិកាជូនក្រសួង ស្ថាប័នជំនាញ ឬ រៀបចំឱ្យមានស្ថាប័នជំនាញមួយផ្សេងតែម្តង ក្នុងការសិក្សាសមិទ្ធិលទ្ធភាពគម្រោងវិនិយោគសាធារណៈ ជាពិសេស សម្រាប់គម្រោងដែលមានទុនវិនិយោគធំ និងមានភាពស្មុគស្មាញ។ ដោយឡែក, ចំពោះប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ពុំទាន់មានលទ្ធភាពផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់ជូនក្រសួង ស្ថាប័នជំនាញ ធ្វើការសិក្សា និងរៀបចំគម្រោងបានពេញលេញនៅឡើយទេ។

### ៤.១.២. ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ

ប្រទេសមួយចំនួនបានអនុវត្តការបែងចែកដំណាក់កាលនៃវដ្តគម្រោងជា ៦ ឬ ៨ ដំណាក់កាល ដោយអាស្រ័យទៅនឹងបរិការណ៍នៃនីតិវិធីគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅក្នុងប្រទេសរបស់ខ្លួន។ ដោយឡែក, ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ បានពិនិត្យឃើញថា ប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬ ជឿនលឿន ជាទូទៅបានបែងចែកវដ្តគម្រោងជា ៨ ដំណាក់កាល ដូចខាងក្រោម៖

**ដំណាក់កាលទី១ - ការធ្វើអត្តសញ្ញាណកម្ម និងការរៀបចំសំណើគម្រោងបឋម៖** ក្រសួង ស្ថាប័នជំនាញ ត្រូវកំណត់អត្តសញ្ញាណគម្រោង, រៀបចំសំណើគម្រោងបឋម ឬ ឯកសារទស្សនាទានគម្រោង ដោយពិនិត្យពីទំនាក់ទំនងទៅនឹងអាទិភាពគោលនយោបាយជាតិ, គោលនយោបាយតាមវិស័យ, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, និងក្របខ័ណ្ឌថវិការយៈពេលមធ្យមជាដើម។ ការធ្វើអត្តសញ្ញាណកម្ម និងរៀបចំគម្រោង ត្រូវធ្វើឡើងដោយផ្អែកលើ «**គោលការណ៍ស្ដីពីការកំណត់អត្តសញ្ញាណកម្ម និងរៀបចំគម្រោង**» ដែលត្រូវដាក់ឱ្យអនុវត្តដោយរដ្ឋាភិបាល។ គោលបំណងសំខាន់នៃឯកសារណែនាំជាយុទ្ធសាស្ត្រនេះ គឺដើម្បីបន្សី និងតម្រឹមសំណើគម្រោងជាក់លាក់នីមួយៗទៅតាមគោលបំណង និងគោលដៅរួមនៃផែនការអភិវឌ្ឍន៍ជាតិ និងគោលនយោបាយ ឬយុទ្ធសាស្ត្រតាមវិស័យ តាមរយៈការកំណត់ច្បាស់លាស់នូវគោលបំណង, គោលដៅ, លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ ជាមួយនឹងកាលវេលានៃបង្គោលចរច្បាស់លាស់។

បន្ទាប់ពីនេះ, ក្រសួងផែនការ ឬ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលទទួលបន្ទុកលើកិច្ចការរៀបចំផែនការសេដ្ឋកិច្ច និង/ឬ វិនិយោគ នឹងសម្របសម្រួលធ្វើអាទិភាវូបនីយកម្មសំណើគម្រោងវិនិយោគ ដែលទទួលបានពីក្រសួង ស្ថាប័នជំនាញ ដាក់បញ្ចូលទៅក្នុងផែនការ ឬ កម្មវិធីវិនិយោគសាធារណៈ។

**ដំណាក់កាលទី២ - ការសិក្សាសមិទ្ធិលទ្ធភាព វាយតម្លៃ និងរៀបចំសំណើគម្រោងផ្លូវការ៖** ជាដំណាក់កាលដែលក្រសួង ស្ថាប័នជំនាញ ត្រូវធ្វើការសិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃគម្រោងលើទិដ្ឋភាពពាក់ព័ន្ធ រួមមាន៖ បច្ចេកទេស, តម្លៃ, ហានិភ័យ, សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ច្បាប់, ផលប៉ះពាល់សង្គមនិងបរិស្ថាន, យន្តការស្ថាប័នគ្រប់គ្រង និងអនុវត្តគម្រោងជាដើម ដោយត្រូវគោរពគោលការណ៍ណែនាំលម្អិត និងនីតិវិធីគ្រប់គ្រងប្រតិបត្តិ ជាធរមាន ព្រមទាំងរៀបចំជាសំណើគម្រោងផ្លូវការ ដើម្បីដាក់សុំការអនុម័តពីស្ថាប័នមានសមត្ថកិច្ច។

**ដំណាក់កាលទី៣ - ការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង៖** ជាដំណាក់កាលដែលត្រូវពិនិត្យផ្ទៀងផ្ទាត់ឡើងវិញលើការវាយតម្លៃសំណើគម្រោង ដោយស្ថាប័នមានសមត្ថកិច្ចផ្សេងដាច់ពីក្រសួង ស្ថាប័នម្ចាស់សំណើគម្រោង។ ជាទូទៅ, តួនាទីនៃការពិនិត្យឡើងវិញលើការវាយតម្លៃសំណើគម្រោង គឺជាសមត្ថកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ ឬ នៅប្រទេសមួយចំនួនទៀត រដ្ឋាភិបាលបង្កើតស្ថាប័នឯករាជ្យ ដើម្បីត្រួតពិនិត្យ និងផ្ដល់យោបល់លើសំណើគម្រោងរបស់ក្រសួង ស្ថាប័នម្ចាស់សំណើគម្រោង។

**ដំណាក់កាលទី៤ - ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម៖** ជាដំណាក់កាលដែលក្រសួងហិរញ្ញវត្ថុត្រូវជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាពដែលបានឆ្លងកាត់ដំណាក់កាលទី៣ ដើម្បីកំណត់ប្រភពហិរញ្ញប្បទាន និងធ្វើថវិកានីយកម្ម ក្នុងគោលដៅធានាប្រសិទ្ធភាពសេដ្ឋកិច្ច, សមធម៌សង្គម, និងលទ្ធភាពនៃថវិកាក្នុងដំណាក់កាលវិនិយោគ និងប្រតិបត្តិការ។ មានតែគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អនុលោមតាមលក្ខណៈវិនិច្ឆ័យ និងវិធានជាធរមានប៉ុណ្ណោះ នឹងត្រូវបានជ្រើសរើសចេញពីបញ្ជីគម្រោងអាទិភាព សម្រាប់ការធ្វើថវិកានីយកម្ម។ ប្រទេសមួយចំនួនបានប្រកាន់យកគោលការណ៍រៀបចំកញ្ចប់ថវិកាវិនិយោគសាធារណៈរយៈពេលមធ្យម ដើម្បីធានាការចំណាយ និងការវិភាជធនធានដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធពហុឆ្នាំតែម្ដង និងលើសពីនេះ ក៏មានប្រទេសមួយចំនួនទៀត បានគិតគូរពេញលេញរហូតដល់ដំណាក់កាលថែទាំហេដ្ឋារចនាសម្ព័ន្ធផងដែរ។

**ដំណាក់កាលទី៥ - ការគ្រប់គ្រង និងការអនុវត្តគម្រោង៖** ក្រសួង ស្ថាប័នជំនាញ ដែលជាម្ចាស់គម្រោងសហការជាមួយក្រសួងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ចាប់ផ្ដើមអនុវត្តកិច្ចលទ្ធកម្ម រាប់ទាំងការរៀបចំផែនការលទ្ធកម្ម, ការអនុវត្តនីតិវិធីលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា។ ចំពោះករណីគម្រោងវិនិយោគដែលមានទំហំមធ្យម, ធំ, ឬ មានលក្ខណៈស្មុគស្មាញ តម្រូវឱ្យមានការរៀបចំក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិកាពហុឆ្នាំ, រចនាសម្ព័ន្ធគ្រប់គ្រង, និងរយៈពេលអនុវត្តច្បាស់លាស់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគម្រោង និងចៀសវាង ឬ កាត់បន្ថយហានិភ័យពាក់ព័ន្ធដែលអាចនឹងកើតឡើង ជាពិសេស ក្នុងដំណាក់កាលនៃការអនុវត្តកិច្ចលទ្ធកម្ម។

**ដំណាក់កាលទី៦ - ការកែសម្រួលគម្រោង៖** ក្រសួង ស្ថាប័នជំនាញ និងក្រសួងហិរញ្ញវត្ថុ ឬ ក្រសួង ស្ថាប័នមានសមត្ថកិច្ច មានភារកិច្ចតាមដានការអនុវត្តគម្រោង ដោយផ្ទៀងផ្ទាត់វឌ្ឍនភាពនៃការអនុវត្តគម្រោងទៅនឹងផែនការអនុវត្តគម្រោងដែលបានអនុម័តរួច ហើយក្នុងករណីចាំបាច់ អាចឈានទៅដល់ការកែសម្រួលគម្រោង ដូចជាការពន្យារពេល ឬ ការចំណាយលើសផែនការជាដើម។ ក្នុងករណីដែលមានការចំណាយខ្ពស់លើសពីដានកំណត់, ក្រសួងហិរញ្ញវត្ថុ ឬ ក្រសួង ស្ថាប័នមានសមត្ថកិច្ច មានសិទ្ធិស្នើឱ្យក្រសួង ស្ថាប័នជំនាញពិនិត្យលទ្ធភាពវាយតម្លៃគម្រោងឡើងវិញ ដើម្បីកែសម្រួលសមាសភាគ/សកម្មភាព ឬ វិសាលភាពនៃគម្រោង ឬ បញ្ឈប់ការផ្តល់ហិរញ្ញប្បទានលើគម្រោងតែម្តង។ ក្នុងករណីចាំបាច់, អាចរៀបចំគម្រោងបន្ថែមថ្មី ដើម្បីអនុវត្តបញ្ចប់ និងសម្រេចតាមគោលដៅគម្រោង។

**ដំណាក់កាលទី៧ - ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមគម្រោង៖** ក្រសួង ស្ថាប័នជំនាញ មានភារកិច្ចត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីអនុវត្តការប្រគល់-ទទួល និងចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋស្របតាមនីតិវិធីជាធរមាន។ ទន្ទឹមនេះ, ត្រូវកំណត់ដែនសមត្ថកិច្ចគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ និងគ្រោងឥណទានថវិការបស់ក្រសួង ស្ថាប័នជំនាញ សម្រាប់ធានាដល់ប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងដំណាក់កាលប្រើប្រាស់ និងផ្តល់សេវាសាធារណៈ។

**ដំណាក់កាលទី៨ - ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង៖** ក្រសួង ស្ថាប័នគ្រប់គ្រងការអនុវត្តគម្រោង ឬ ភាគីទី៣ ដែលជាស្ថាប័នមានសមត្ថកិច្ចផ្សេងពីក្រសួង ស្ថាប័នម្ចាស់គម្រោង ត្រូវប្រមូលទិន្នន័យនៃការចំណាយសរុប, លទ្ធផលសម្រេចបាន និងក្របខ័ណ្ឌពេលវេលា ធៀបនឹងផែនការដើម, លទ្ធផលរំពឹងទុក, និងគោលដៅរបស់គម្រោង។ ជាទូទៅ, ការវាយតម្លៃបញ្ចប់គម្រោង ត្រូវធ្វើឡើងភ្លាមបន្ទាប់ពីបានបញ្ចប់ការអនុវត្តគម្រោង ឬ នៅក្នុងរយៈពេលមិនលើសពី ពីរ ឬ បីឆ្នាំ បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ ដើម្បីរៀបចំចងក្រងជារបាយការណ៍ស្តីពីលទ្ធផលសម្រេចបានទាំងលទ្ធផលសម្រេចបានក្នុងរយៈពេលអនុវត្តគម្រោង និងទាំងលទ្ធផលចុងក្រោយ ព្រមទាំងបញ្ហាប្រឈមនៃការអនុវត្តគម្រោង សម្រាប់ជាបទពិសោធក្នុងការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈក្រោយៗទៀត។

**ដំណាក់កាលនៃវដ្តគម្រោងវិនិយោគសាធារណៈ**




**ប្រភព៖ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ**

តាមការវាយតម្លៃរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗលើកម្រិតសមត្ថភាពនៃប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ, ជាទូទៅ មានក្រុមប្រទេសចំនួន ២ ធំៗ ដូចខាងក្រោម៖

១) **ក្រុមប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬ ជឿនលឿន៖** ដែលជារួម ដោយសារមានកត្តាកំណត់ដ៏រឹងមាំ ជាអាទិ៍ដូចខាងក្រោម៖

- ឯកសារក្របខ័ណ្ឌគោលនយោបាយគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ ដែលផ្តល់ជាមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ, ក្របខ័ណ្ឌថវិកា, និងផែនការ ឬ កម្មវិធីវិនិយោគសាធារណៈរយៈពេលមធ្យម
- ក្របខ័ណ្ឌគតិយុត្ត, នីតិវិធីគ្រប់គ្រងប្រតិបត្តិ, យន្តការស្ថាប័ន, និងសមត្ថភាពធនធានមនុស្ស ដើម្បីគាំទ្រដល់ការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ
- យន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការសិក្សាសមិទ្ធិលទ្ធភាព និងការរៀបចំសំណើគម្រោងវិនិយោគសាធារណៈ
- យន្តការ និងនីតិវិធីត្រួតពិនិត្យលើការវាយតម្លៃសំណើគម្រោងដោយឯករាជ្យ
- ការរៀបចំកញ្ចប់ថវិកាពហុឆ្នាំ សម្រាប់ការអនុវត្តគម្រោង
- ការយកចិត្តទុកដាក់លើការគ្រប់គ្រងចំណាយសរុប (វិនិយោគ ប្រតិបត្តិការ និងថែទាំ) និងមានការកំណត់តួនាទី និងភារកិច្ចនៃក្រសួង ស្ថាប័ននីមួយៗ ដែលទទួលបន្ទុកអនុវត្តគម្រោងវិនិយោគសាធារណៈ
- យន្តការ និងនីតិវិធីច្បាស់លាស់ក្នុងការពិនិត្យ និងកែសម្រួលគម្រោងឡើងវិញ
- នីតិវិធីច្បាស់លាស់ក្នុងការកត់ត្រាចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋ និងយន្តការគ្រប់គ្រង ប្រើប្រាស់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធបានច្បាស់លាស់
- ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់គម្រោង
- អង្គភាពថ្នាក់កណ្តាល ឬ លេខាធិការដ្ឋានមួយទទួលបន្ទុកប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈទាំងអស់ ដើម្បីតាមដានវឌ្ឍនភាព និងវាយតម្លៃប្រសិទ្ធភាពនៃការរៀបចំ និងអនុវត្តគម្រោង។

២) ក្រុមប្រទេសដែលមិនទាន់មានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬ ស្ថិតក្នុងដំណាក់កាលនៃការពង្រឹងបន្ថែម និងដំណាក់កាលនៃការកែទម្រង់៖ ជាទូទៅ នៅមានភាពខ្វះចន្លោះមួយចំនួនតាមដំណាក់កាលនីមួយៗនៃវដ្តគម្រោង រួមមាន៖

- ការផ្សារភ្ជាប់ការធ្វើផែនការ ឬ កម្មវិធីវិនិយោគសាធារណៈជាមួយនឹងក្របខ័ណ្ឌគោលនយោបាយ និងថវិកា
- ក្របខ័ណ្ឌគតិយុត្ត, គោលការណ៍ណែនាំ, នីតិវិធីគ្រប់គ្រងប្រតិបត្តិ, យន្តការស្ថាប័ន, និងការកសាង និងអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស ដើម្បីគាំទ្រដល់ការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ
- គុណភាពនៃការធ្វើអត្តសញ្ញាណកម្មគម្រោង ការរៀបចំគម្រោង និងការវាយតម្លៃសំណើគម្រោង
- ប្រសិទ្ធភាព និងអនុលោមភាពនៃការអនុវត្តកិច្ចលទ្ធកម្ម និងគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ
- ប្រសិទ្ធភាព និងចីរភាពនៃការគ្រប់គ្រង ប្រើប្រាស់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធ
- កិច្ចសម្របសម្រួលអន្តរស្ថាប័នជាមួយនឹងតួអង្គពាក់ព័ន្ធសំខាន់ៗ ជាដើម។

### ៤.១.៣. និន្នាការសកល

បច្ចុប្បន្ន, បទពិសោធនៃការអនុវត្តជាសកលខាងលើបានបង្ហាញថា ត្បិតមានក្រុមប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬ ជឿនលឿនក្តី, តែក្រុមប្រទេសទាំងនោះក៏ពុំទាន់គោរពតាមនីតិវិធី

ដែលមានជាធរមានបានពេញលេញនៅឡើយ។ ដូច្នេះហើយ, ក្រុមប្រទេសទាំងនេះ នៅតែបន្តពង្រឹងកែលម្អ ឬ កែសម្រួលសមាសធាតុពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់មួយកម្រិតទៀត ស្របតាមបរិការណ៍ជាក់ស្តែងនៃប្រទេសរៀងៗខ្លួន។ ចំណែកឯបណ្តាប្រទេសដែលមិនទាន់មានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬ ស្ថិតក្នុងដំណាក់កាលនៃការពង្រឹងបន្ថែម និងការកែទម្រង់, ការបង្កើត ឬ ការពង្រឹងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរបស់ខ្លួន គឺដើម្បីបម្រើឱ្យគោលដៅចម្បងចំនួន ៣ រួមមាន៖ ១)ការឆ្លើយតបទៅនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ, ២)ការគ្រប់គ្រងសម្ពាធនៃកំណើនបំណុលសាធារណៈ, និង៣)ការលើកកម្ពស់ប្រសិទ្ធភាព និងចីរភាពនៃការវិនិយោគសាធារណៈ សំដៅរួមចំណែកក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង។

ជាមួយគ្នានេះ, ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ជាច្រើន បន្តជ្រោមជ្រែងជួយប្រទេសសមាជិកក្នុងការបង្កើត ឬ ពង្រឹងក្របខ័ណ្ឌរួម សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈបន្ថែមទៀត ដែលអាចផ្តល់នូវទិដ្ឋភាពគ្រប់ជ្រុងជ្រោយ, ប្រទាក់ក្រឡា, និងជាប្រព័ន្ធក្នុងដំណាក់កាលនីមួយៗនៃវដ្តគម្រោង សំដៅធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និងចីរភាពនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈប្រកបដោយសមធម៌សង្គម។

ជារួម, ការបង្កើត ឬ ការពង្រឹងក្របខ័ណ្ឌរួម ដើម្បីគ្រប់គ្រងការវិនិយោគសាធារណៈ គឺតម្រូវឱ្យប្រទេសដែលមិនទាន់មានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ចាប់ផ្តើមពីការកែលម្អ និងពង្រឹងក្របខ័ណ្ឌគោល-នយោបាយ, ក្របខ័ណ្ឌគតិយុត្ត, គោលការណ៍ណែនាំ, នីតិវិធីគ្រប់គ្រងប្រតិបត្តិ, យន្តការស្ថាប័ន, សមត្ថភាពធនធានមនុស្ស, និងយន្តការគាំទ្រហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ឈានទៅដល់កម្រិតនៃការអភិវឌ្ឍដូចប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរឹងមាំ ឬ ជឿនលឿន។

## ៤.២. បរិការណ៍កម្ពុជា

រយៈពេលជាង ៣ ទសវត្សរ៍ចុងក្រោយនេះ, រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់លើការងារការគ្រប់គ្រងការវិនិយោគសាធារណៈ ដោយបានដាក់ចេញនូវយុទ្ធសាស្ត្រត្រីកោណ, យុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល, បន្ទាប់មក យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក៏ដូចជាក្របខ័ណ្ឌច្បាប់, គោលនយោបាយ, យុទ្ធសាស្ត្រ, និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ជាពិសេស ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលជាត្រីវិស័យចង្អុលបង្ហាញអំពីតម្រូវការជាយុទ្ធសាស្ត្រនៃចំណាយវិនិយោគសាធារណៈ ដើម្បីជំរុញទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ក៏ដូចជាការអភិវឌ្ឍសង្គមផងដែរ។ ក្រោមក្របខ័ណ្ឌនេះ, មុខសញ្ញាចំណាយវិនិយោគសាធារណៈត្រូវបានផ្តល់អាទិភាពជាចម្បងលើការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលគាំទ្រដល់វិស័យសេដ្ឋកិច្ច និងសង្គម រួមមាន៖ ១)ការបន្តស្តារ កសាង និងកែលម្អប្រព័ន្ធឡូជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវគោក, ផ្លូវដែក, ផ្លូវទឹក, និងផ្លូវអាកាស), ២)ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ, ៣)ការអភិវឌ្ឍវិស័យថាមពល, ៤)ការអភិវឌ្ឍវិស័យទឹកស្អាត, ៥)ការអភិវឌ្ឍ និងកែលម្អប្រព័ន្ធទឹកកខ្វក់, ៦)ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ និងឌីជីថល, និង៧)ការរៀបចំខ្លួនសម្រាប់ប្រព័ន្ធសេដ្ឋកិច្ចឌីជីថល និងសម្រាប់ឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤។ គ្រង់ចំណុចដូចបានរៀបរាប់ខាងលើ នឹងត្រូវបានលើកយកមកបង្ហាញនៅក្នុងចំណុច ៤.២.១ និងចំណុច ៤.២.២ ខាងក្រោមនេះ។

### ៤.២.១. ក្របខ័ណ្ឌគោលនយោបាយ

រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក៏ដូចជាគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធចាំបាច់នានា ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈនៅកម្ពុជា ដោយរួមបញ្ចូលការគិតគូរពីការវិនិយោគបៃតង និងបម្រែបម្រួលអាកាសធាតុ ដូចខាងក្រោម៖

- **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»** ត្រូវបានអនុម័តនៅខែសីហា ឆ្នាំ២០២៣។ យុទ្ធសាស្ត្រនេះបានកំណត់គោលដៅយុទ្ធសាស្ត្រទី១ គឺធានាឱ្យមានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់ ៧% ប្រកបដោយភាពធន់នឹងវិបត្តិនានា តាមរយៈការជំរុញសម្ទុះនៃការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ដើម្បីបង្កើតចន្ទល់ថ្មីៗនៃកំណើន, ការលើកកម្ពស់ភាពប្រកួតប្រជែង, និងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប, ធានាស្ថិរភាពអត្រាប្តូរប្រាក់, ខិតខំបង្កើនទុនបម្រុងជាប្រចាំ, និងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរួមបញ្ចូលផងដែរនូវការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងបំណុលសាធារណៈឱ្យប្រកបដោយចីរភាព និងគោលដៅយុទ្ធសាស្ត្រទី៥ គឺធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុដោយធ្វើបរមភាវូបនីយកម្ម (Optimization) ផលលាភប្រជាសាស្ត្រ និងពង្រឹងភាពធន់នៃប្រជាសាស្ត្រ, លើកកម្ពស់សមភាពយេនឌ័រ, គ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព, បង្កើនហិរញ្ញប្បទានចីរភាព និងបៃតង នៅក្នុងបណ្តុំកម្មវិធីសរុប ដើម្បីបង្កើនលំហូរហិរញ្ញវត្ថុឆ្ពោះទៅរកការវិនិយោគបៃតង និងសេដ្ឋកិច្ចបៃតង, ជំរុញការវិនិយោគសាធារណៈ ដែលមានភាពធន់នឹងអាកាសធាតុ និងមានការបញ្ច្រាបកាបូនទាប, និងធានាចីរភាពបរិស្ថាន ព្រមទាំងត្រៀមខ្លួនជាស្រេច ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

- **«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា»** ត្រូវបានអនុម័តនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភាជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ ផែនការយុទ្ធសាស្ត្រនេះ កំណត់អំពីតម្រូវការជាយុទ្ធសាស្ត្រនៃចំណាយវិនិយោគសាធារណៈសំដៅជំរុញនិងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ក៏ដូចជា ការអភិវឌ្ឍសង្គមជារួម។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តផងដែរនូវកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដើម្បីបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ន ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងជាមូលដ្ឋានក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

ដោយឡែក, ក្រៅពីក្របខ័ណ្ឌគោលនយោបាយដូចបានរៀបរាប់ខាងលើ ក៏មានក្របខ័ណ្ឌគោលនយោបាយតាមវិស័យ ដែលរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័នផងដែរ។

### ៤.២.២. ក្របខ័ណ្ឌគតិយុត្ត

តាមរយៈកិច្ចខិតខំប្រឹងប្រែងកន្លងមក, រាជរដ្ឋាភិបាលបានកសាងនូវក្របខ័ណ្ឌគតិយុត្តសំខាន់ៗមួយចំនួនដែលជាមូលដ្ឋានគ្រឹះក្នុងការគ្រប់គ្រងការវិនិយោគសាធារណៈប្រកបដោយចីរភាព ព្រមទាំងដើម្បីគាំទ្រ និងរួមចំណែកដល់ការជំរុញការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈនៅកម្ពុជា ឱ្យមានភាពឆ្លើយតបខ្ពស់, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និងសម្រេចបានបរមភាវូបនីយកម្មផលសេដ្ឋកិច្ច។ ក្របខ័ណ្ឌគតិយុត្តសំខាន់ៗ រួមមាន៖

- **«ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ»** ត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដើម្បីជំនួសច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨។ ច្បាប់នេះ គឺជាច្បាប់គោលដែលកំណត់អំពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់-ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ព្រមទាំងចំពោះទំនាក់ទំនងនិងអន្តរសកម្មរវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុសាធារណៈឯកជនអន្តរជាតិ។ បន្ថែមពីនេះ, បានបញ្ញត្តិថា បន្ទុកថវិការបស់រដ្ឋ រួមមាន ចំណាយចរន្តនិងចំណាយមូលធន ដែលត្រូវបានបែងចែកជា ៦ ប្រភេទ រួមមាន៖ ១)បន្ទុកបុគ្គលិក, ២)ចំណាយប្រតិបត្តិការ, ៣)បន្ទុកហិរញ្ញវត្ថុ, ៤)ចំណាយវិនិយោគ, ៥)ការផ្ទេរ, និង

៦)ចំណាយផ្សេងៗ។ ចំណាយវិនិយោគ គឺជាប្រភេទចំណាយស្ថិតក្នុងចំណាយចរន្តនិងចំណាយមូលធន ដោយក្នុងនោះរួមមាន ចំណាយលើការទទួលបាននូវទ្រព្យសកម្មរយៈពេលវែងទាំងរូបី និងអរូបី ព្រមទាំងទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង។ ឥណទានវិនិយោគ កំណត់លើគម្រោង ឬ កម្មវិធីវិនិយោគទាំងឡាយដែលរដ្ឋបានផ្តួចផ្តើមនៅក្នុងឆ្នាំ និងគណនាតម្រូវការចំណាយសរុប ដោយមានសង្គតិភាពទៅនឹងផែនការគម្រោងវិនិយោគរយៈពេលមធ្យម។ បន្ថែមពីនេះ, គម្រោង ឬ កម្មវិធីវិនិយោគរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ដែលមិនទាន់បញ្ចប់នៅឆ្នាំអនុវត្តឥណទានទូទាត់នៃចំណាយមូលធនដែលមិនទាន់បានប្រើប្រាស់នៅពេលបិទការគ្រប់គ្រង (បញ្ចប់ឆ្នាំ) អាចអនុញ្ញាតឱ្យយោងជាឥណទានទូទាត់ទៅឆ្នាំបន្ទាប់បាន សម្រាប់បញ្ចប់គម្រោង ឬ កម្មវិធីវិនិយោគចាំបាច់។ ការគ្រោងចំណាយចរន្តនិងចំណាយវិនិយោគ ត្រូវរៀបចំឡើងដោយរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តកម្មវិធីនិងសកម្មភាពការងារទាំងមូល។ ការគ្រោងចំណាយវិនិយោគត្រូវរៀបចំផ្អែកលើគម្រោង ឬ កម្មវិធីវិនិយោគដោយឡែកៗ ដែលមានការយល់ព្រមជាមុន ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងវិនិយោគសាធារណៈ និងដែលត្រូវបានរៀបចំឡើងសំដៅសម្រេចឱ្យបាននូវគោលបំណង ដែលបានកំណត់ក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។ គម្រោង ឬ កម្មវិធីវិនិយោគទាំងអស់ គឺជាមូលដ្ឋានសម្រាប់វាយតម្លៃចំណាយវិនិយោគសរុបរបស់គម្រោង ឬ កម្មវិធី និងសម្រាប់កំណត់រយៈពេលនៃឥណទានភ្ជាប់សន្យានិងឥណទានទូទាត់ សម្រាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ។

ទន្ទឹមនឹងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលជាច្បាប់គោល ក្នុងនោះច្បាប់ពាក់ព័ន្ធសំខាន់ៗរួមមាន៖

- «**ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ**» ត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០។
- «**ច្បាប់ស្តីពីមូលបត្ររដ្ឋ**» ត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដើម្បីជំនួសច្បាប់ស្តីពីមូលបត្ររដ្ឋ ឆ្នាំ២០០៧។
- «**ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន**» ត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដើម្បីជំនួសច្បាប់ស្តីពីសម្បទាន ឆ្នាំ២០០៧។
- «**ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ**» ត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដើម្បីជំនួសច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០១២។

ទន្ទឹមនឹងច្បាប់ពាក់ព័ន្ធខាងលើនេះ ក្នុងនោះលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងការវិនិយោគសាធារណៈ មានដូចខាងក្រោម៖

- «**អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ**» ត្រូវបានអនុម័តកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ មានគោលបំណងធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងការវិនិយោគសាធារណៈ នៅតាមដំណាក់កាលនៃវដ្តគម្រោង ពីគ្រប់ប្រភពហិរញ្ញប្បទាន និងនៅគ្រប់កម្រិតរដ្ឋបាល សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសមធម៌សង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹត្យនេះ គឺជាអនុក្រឹត្យគោល មានគោលដៅកំណត់គោលការណ៍ជាសារវន្ត និងប្រព័ន្ធនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន និងនៅគ្រប់កម្រិតរដ្ឋបាល ជាអាទិ៍ រួមមាន៖ គោលការណ៍ និងលក្ខខណ្ឌតម្រូវសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, ដំណាក់កាលរួមនៃវដ្តគម្រោងវិនិយោគសាធារណៈ, តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង, ការផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈ ជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ, នីតិវិធីប្រតិបត្តិការនៃការរៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង, និងកាតព្វកិច្ចរបាយការណ៍។ អនុក្រឹត្យនេះ នឹងត្រូវធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ដោយរួមបញ្ចូលការគិតគូរការវិនិយោគបៃតង និងបម្រែបម្រួលអាកាសធាតុផងដែរ។

- «**អនុក្រឹត្យស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល**» ត្រូវបានអនុម័តកាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៤ មានវិសាលភាពអនុវត្តចំពោះកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលមានប្រភពហិរញ្ញប្បទានដូចជា៖ ១)គម្រោងហិរញ្ញប្បទានដោយថវិកាជាតិ, ២)គម្រោងហិរញ្ញប្បទានក្រៅប្រទេស, ៣)គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន, ៤)គម្រោងវិនិយោគសាធារណៈ ដោយប្រភពហិរញ្ញប្បទានចម្រុះ, ៥)គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយការផ្ទេរឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ, ៦)គម្រោងវិនិយោគសាធារណៈដោយសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលដទៃទៀត, ៧)គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម, និង៨)គម្រោងវិនិយោគសាធារណៈដោយប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងៗទៀត។

- «**អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍**» ត្រូវបានអនុម័តកាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ។

- «**អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍**» ត្រូវបានអនុម័តកាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២។

- «**អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន**»ត្រូវបានអនុម័តកាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

- «**អនុក្រឹត្យស្តីពីការគ្រប់គ្រងមូលនិធិបំពេញផលហិរញ្ញវត្ថុសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន**» ត្រូវបានអនុម័តកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤។

- «**អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដានីតិវិធីប្រតិបត្តិសម្រាប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ក្នុងព្រះរាជាណាចក្រកម្ពុជា**» ត្រូវបានអនុម័តកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨។

- «**ប្រកាសស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់)**» ត្រូវបានអនុម័តកាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។

- «**ប្រកាសស្តីពីការគ្រប់គ្រងនិងអនុវត្តថវិកាសម្រាប់ការសិក្សាគម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ**» ត្រូវបានអនុម័តកាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣។

- «**ប្រកាសស្តីពីការដាក់ឱ្យប្រើគោលការណ៍ណែនាំសម្រាប់គាំទ្រដល់ការអនុវត្តអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន**» ត្រូវបានដាក់ឱ្យប្រើកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២។

- «**ប្រកាសស្តីពីការដាក់ឱ្យប្រើគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជនសម្រាប់គាំទ្រដល់ការអនុវត្តអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន**» ត្រូវបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០២៣។

- «**ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**» ត្រូវបានអនុម័តកាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣។

- «**ប្រកាសស្តីពីគោលការណ៍ប្រើប្រាស់ថវិកាគាំទ្ររៀបចំគម្រោង និងសិក្សាប្លង់សំណង់វិស្វកម្ម និងថវិកាចំណាយបុរេសកម្មភាព ក្រោមក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ឬ ទុនទទួលបានពីការបោះផ្សាយមូលបត្ររដ្ឋ**» ត្រូវបានអនុម័តកាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤។

- «**ប្រកាសស្តីពីការដាក់ឱ្យអនុវត្តក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ**» ត្រូវបានអនុម័តកាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥។

ក្រៅពីក្របខ័ណ្ឌគតិយុត្តដូចបានរៀបរាប់ខាងលើ ក៏មានក្របខ័ណ្ឌគតិយុត្តតាមវិស័យផ្សេងទៀត ដែលត្រូវបានរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័នផងដែរ។ ទន្ទឹមនេះ, លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំសំខាន់ៗត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍សេដ្ឋកិច្ចសង្គមកម្ពុជា ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្មនេះ។

## ៤.២.៣. យន្តការស្ថាប័ន

### ៤.២.៣.១. តួនាទីនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន

#### ក. តួនាទីនិងការទទួលខុសត្រូវរបស់ក្រសួងផែនការ

**ក្រសួងផែនការ** ត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល និងរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដោយមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន
- រៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល និងលក្ខណៈវិនិច្ឆ័យដែលត្រូវប្រើក្នុងការកំណត់អាទិភាពគម្រោង ពិន្ទុ និងមេគុណ ដែលត្រូវផ្តល់ក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗ ពិន្ទុមធ្យមសរុបរបស់គម្រោងនីមួយៗ ចំណាត់ថ្នាក់អាទិភាពតាមពិន្ទុមធ្យមសរុបរបស់គម្រោងនីមួយៗ
- ជូនដំណឹងដល់បណ្តាក្រសួង ស្ថាប័ន ដើម្បីរៀបចំកម្មវិធីវិនិយោគសាធារណៈសម្រាប់វិស័យរបស់ខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់
- យកគម្រោងវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលរៀបចំដោយក្រសួង ស្ថាប័ន ចងក្រងជាសេចក្តីព្រាង និងរៀបចំបញ្ជីសង្ខេបស្តីពីគម្រោងកំពុងដំណើរការ បេក្ខភាពគម្រោងដែលមានប្រភពហិរញ្ញប្បទានសន្យាផ្តល់ និងបេក្ខភាពគម្រោងដែលស្វែងរកប្រភពហិរញ្ញប្បទាន
- ដឹកនាំរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យរួមគ្នាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល រួចផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យផ្ទៀងផ្ទាត់បញ្ជីគម្រោងមុននឹងដាក់ស្នើសេចក្តីព្រាងនេះទៅគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេច
- វាយតម្លៃសមិទ្ធកម្មនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលទៅលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម-កិច្ច និងការកែលម្អការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

#### ខ. តួនាទីនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

**ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ** ដែលជាម្ចាស់គម្រោងត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធ្វើអត្តសញ្ញាណកម្ម និងរៀបចំឯកសារទស្សនាទានគម្រោង
- ធ្វើអាទិភាវូបនីយកម្ម
- ផែនការនីយកម្មការវិនិយោគសាធារណៈ
- រៀបចំឯកសារសំណើគម្រោង ដោយត្រូវភ្ជាប់ជាមួយនូវរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព និងរបាយការណ៍វាយតម្លៃសំណើគម្រោង
- គ្រប់គ្រងការអនុវត្តគម្រោង

- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង របាយការណ៍ក្រោយបញ្ចប់ការអនុវត្តគម្រោង និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀត
- ព្រមទាំងបំពេញតួនាទី និងភារកិច្ចពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។

**គ. តួនាទីនិងការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ត្រូវប្រើប្រាស់កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលទទួលបានការសម្រេចពីគណៈរដ្ឋមន្ត្រីសម្រាប់ជាធាតុចូល ដើម្បីរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ក្របខ័ណ្ឌថវិការយៈពេលមធ្យម និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ត្រូវប្រើប្រាស់គម្រោងដែលមាននៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល និងគម្រោងផ្សេងៗទៀត ដែលទទួលបានការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ជាមូលដ្ឋានក្នុងការពិនិត្យ វាយតម្លៃ ជ្រើសរើស និងធ្វើថវិកានីយកម្ម
- **ពិនិត្យ និងវាយតម្លៃលើសំណើគម្រោង៖** ត្រូវពិនិត្យលើលក្ខណៈសម្បត្តិគ្រប់គ្រាន់ តម្លៃនិងហានិភ័យគម្រោង ផលប៉ះពាល់សេដ្ឋកិច្ច សង្គម និងបរិស្ថាន ផលចំណេញផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃគម្រោង យន្តការគ្រប់គ្រង និងអនុវត្តគម្រោង ព្រមទាំងកំណត់នូវវិធានការចាំបាច់នានា ដើម្បីកែតម្រូវ និងគ្រប់គ្រងហានិភ័យគម្រោង
- **ជ្រើសរើសគម្រោង និងថវិកានីយកម្ម៖** ត្រូវជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាព ដើម្បីធ្វើថវិកានីយកម្មក្នុងគោលដៅធានានូវភាពឆ្លើយតបនឹងតម្រូវការជាអាទិភាព ប្រសិទ្ធភាពសេដ្ឋកិច្ច សមធម៌សង្គម លទ្ធភាពនៃថវិកា ភាពរួចរាល់នៃការចាប់ផ្តើមអនុវត្ត និងភាពដែលអាចអនុវត្តបាន
- **តាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង៖** ត្រូវតាមដាន និងត្រួតពិនិត្យលើការគ្រប់គ្រង និងអនុវត្តគម្រោង និងវាយតម្លៃអនុលោមភាពតាមវិធាន គោលការណ៍ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិ ខ និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា
- ព្រមទាំងបំពេញតួនាទី និងភារកិច្ចពាក់ព័ន្ធផ្សេងទៀត។

**ឃ.តួនាទីនិងការទទួលខុសត្រូវរបស់គណៈរដ្ឋមន្ត្រី**

**គណៈរដ្ឋមន្ត្រី** មានតួនាទី និងភារកិច្ចក្នុងពិនិត្យនិងសម្រេចលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល មុនការអនុម័តលើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ។

**ង. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** មានតួនាទី និងភារកិច្ចក្នុងការយកកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលគណៈរដ្ឋមន្ត្រីបានសម្រេចទៅធ្វើការអំពាវនាវ កៀរគររកជំនួយមកគាំទ្រដល់ការអនុវត្តរាល់គម្រោងវិនិយោគសាធារណៈដែលមិនទាន់មានទុនអនុវត្ត និងផ្តល់ព័ត៌មានអំពីលទ្ធផលនៃការកៀរគររកជំនួយមកគាំទ្រដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ។

### ៤.២.៣.២. ដំណើរការរៀបចំគម្រោងវិនិយោគសាធារណៈ

នៅក្នុងក្របខ័ណ្ឌគម្រោងវិនិយោគសាធារណៈ ការសិក្សាបឋម (ធ្វើអត្តសញ្ញាណកម្ម និងឯកសារទស្សនាទានគម្រោង), ការសិក្សាសមិទ្ធិលទ្ធភាព, និងការរៀបចំ ត្រូវទទួលបន្ទុកដោយក្រសួង ស្ថាប័នសាមី ដែលជាម្ចាស់សំណើគម្រោង ហើយការរៀបចំនេះ នឹងក្លាយជាកម្មវត្ថុនៃការពិនិត្យ និងវាយតម្លៃរបស់ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមដំណាក់កាលផ្សេងៗគ្នា ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល ដូចខាងក្រោម៖

### ក. ដំណាក់កាលរៀបចំផែនការតាមវិស័យ

នៅក្នុងដំណាក់កាលនេះ ក្រសួងផែនការដឹកនាំរៀបចំផែនការ និងកម្មវិធីជាតិសម្រាប់កិច្ចអភិវឌ្ឍរយៈពេលវែង មធ្យម និងខ្លី ដោយសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាថា ផែនការ និងកម្មវិធីជាតិទាំងនោះមានសង្គតិភាពជាមួយគ្នា រវាងបណ្តាវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងកំណត់អាទិភាពក្នុងការវិនិយោគទាំងឯកជន និងសាធារណៈ ដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពនូវសក្តានុពលនៃធនធានទាំងក្នុង និងក្រៅប្រទេស។ លទ្ធផលនៃការរៀបចំនេះ នឹងត្រូវបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល។

ទន្ទឹមនេះ, ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល គឺក្នុងខែវិច្ឆិកា ដោយក្រសួងផែនការ ត្រូវជូនដំណឹងដើម្បីណែនាំបណ្តាក្រសួង ស្ថាប័នឱ្យរៀបចំគម្រោងវិនិយោគសាធារណៈក្នុងវិស័យរបស់ខ្លួន។ បន្ទាប់មក នៅក្នុងខែមករា បណ្តាក្រសួង ស្ថាប័ន ត្រូវផ្ញើគម្រោងកម្មវិធីវិនិយោគសាធារណៈទាំងអស់ក្នុងវិស័យរបស់ខ្លួនទៅក្រសួងផែនការ។ ម្យ៉ាងទៀត, ការរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈក្នុងវិស័យរបស់ក្រសួង ស្ថាប័ន ត្រូវផ្អែកលើមូលដ្ឋាននៃការវាយតម្លៃពីលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលក្នុងឆ្នាំកន្លងមក និងដោយមានការចូលរួមពីក្រុមការងារថវិកា ហើយផ្ញើជូនទៅក្រសួងផែនការ ព្រមទាំងមានការចុះហត្ថលេខាបញ្ជាក់របស់រដ្ឋមន្ត្រីសាមីក្រសួង ឬ ប្រធានស្ថាប័ន។ ក្នុងខែកុម្ភៈ ក្រសួងផែនការ ត្រូវរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងដើម្បីពិនិត្យរួមគ្នាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល រួចផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យផ្ទៀងផ្ទាត់បញ្ជីគម្រោង និងបញ្ជូនសេចក្តីព្រាងដែលបានកែសម្រួលរួចជូនគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសម្រេច។ បន្ថែមពីនេះ, នៅក្នុងខែមីនា គណៈរដ្ឋមន្ត្រីធ្វើការពិនិត្យនិងសម្រេចលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។ ហើយក្នុងខែមេសា បន្ទាប់ពីទទួលបានការសម្រេចពីគណៈរដ្ឋមន្ត្រី ក្រសួងផែនការត្រូវបន្តនីតិវិធីក្នុងការបោះពុម្ព និងផ្សព្វផ្សាយឯកសារកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។

បន្ទាប់ពីទទួលបានបញ្ជីគម្រោងដែលសម្រេចដោយគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នសាមី ត្រូវដាក់បញ្ចូលគម្រោងថវិការបស់គម្រោងវិនិយោគសាធារណៈ ទៅក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយផ្អែកតាមសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។ ជាទូទៅ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ នៅដើមខែឧសភា។ ផ្អែកតាមសារាចរណែនាំនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញសារាចរណែនាំមួយទៀត ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំថវិកាប្រចាំឆ្នាំរបស់ខ្លួន។

### ខ. ដំណាក់កាលរៀបចំផែនការថវិកាកម្រិតយុទ្ធសាស្ត្រ

បន្ទាប់ពីការរៀបចំផែនការតាមវិស័យ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដឹកនាំការរៀបចំក្របខ័ណ្ឌថវិកា ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, ក្របខ័ណ្ឌថវិការយៈពេលមធ្យម, និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីផ្តល់ព័ត៌មានដល់ក្រសួង ស្ថាប័ន អំពីលទ្ធភាព និងអាទិភាពចំណាយ និងសក្តានុពលចំណូលនៃឆ្នាំថវិកា និងពីរឆ្នាំទៅមុខ។ គ្រប់ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការយៈពេលមធ្យម។ ក្របខ័ណ្ឌ និងផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ដោយបង្ហាញពីបុរេនិទស្សន៍រយៈពេល៣ឆ្នាំរំកិលទៅមុខ។

ចំពោះគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយឥណទានសម្បទាន, ដៃគូអភិវឌ្ឍន៍គម្រោងនីមួយៗ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នជំនាញ,

រៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការភាពជាដៃគូរយៈពេលមធ្យម ដោយកំណត់អំពីកម្មវិធី/គម្រោង និងវិស័យអាទិភាព ដែលដៃគូអភិវឌ្ឍន៍នីមួយៗនឹងរួមចំណែកជួយគាំទ្រដល់កិច្ចអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិ-ការភាពជាដៃគូនេះ ត្រូវបានរៀបចំដោយផ្អែកលើរបៀបវារៈអភិវឌ្ឍន៍របស់ដៃគូនីមួយៗ និងឆ្លើយតបតាមតម្រូវការអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល អនុលោមតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។

ទន្ទឹមនេះ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចូលរួមរៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការកៀរគរ និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍, និងកៀរគរ និងវិភាជហិរញ្ញប្បទានឥតសំណង សម្រាប់អនុវត្តបណ្តាគោលដៅអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ, ព្រមទាំងសម្របសម្រួលកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគម្រោងវិនិយោគក្នុងការទទួលហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំផងដែរ។

**គ. ដំណាក់កាលរៀបចំ និងអនុម័តថវិកា**

ដំណើរការនៃការរៀបចំ និងអនុម័តថវិកាប្រចាំឆ្នាំ ត្រូវបានអនុវត្តតាមប្រតិទិន ដែលបានដាក់ចេញដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ការរៀបចំកញ្ចប់ថវិការបស់ក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី ខេត្ត គឺផ្អែកលើសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។ ចំណែកឯ ការរៀបចំថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺផ្អែកលើសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានរយៈពេលជាងប្រាំមួយសប្តាហ៍ ក្នុងការរៀបចំថវិការបស់ខ្លួន។ ក្រោយពីទទួលបានការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ត្រូវបានបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីពិនិត្យ និងសម្រេច។

ចំពោះការរៀបចំថវិកា សម្រាប់គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ តំណាងស្របច្បាប់របស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំកិច្ចប្រជុំចរចាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ស្ថាប័នដៃគូអភិវឌ្ឍន៍ ព្រមទាំងដាក់ឱ្យចាប់ផ្តើមដំណើការអនុវត្តគម្រោងតាមនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា នៅដំណាក់កាលអនុវត្តគម្រោងតែម្តង។

**ឃ. ដំណាក់កាលអនុវត្ត និងត្រួតពិនិត្យការអនុវត្តថវិកា**

បន្ទាប់ពីច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ឬ ហៅថា ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានអនុម័តរួច, ក្រសួង ស្ថាប័ន ដែលជាអាណាប័កដើមខ្សែ តម្រូវឱ្យស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាចំណាយ។ ក្នុងដំណាក់កាលធានាចំណាយ, កិច្ចលទ្ធកម្ម, អាណត្តិកិច្ច, និងការទូទាត់ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត និងយន្តការដែលមានជាធរមាន។

**ង. ដំណាក់កាលតាមដាន និងវាយតម្លៃការអនុវត្តថវិកា**

ក្នុងការអនុវត្តថវិកា ក្រសួង ស្ថាប័ន ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុ ស្របតាមគោលការណ៍គណនេយ្យទូទៅរបស់រដ្ឋ និងរបាយការណ៍សមិទ្ធកម្ម តាមកម្មវិធីប្រចាំឆមាស និងប្រចាំឆ្នាំ ដោយផ្អែកលើទម្រង់នៃរបាយការណ៍ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ, ក្រសួង ស្ថាប័នទាំងអស់ ត្រូវមានក្រុមការងារវាយតម្លៃសមិទ្ធកម្មប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីធ្វើការពិនិត្យនិងវាយតម្លៃលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្ត

កម្មវិធីវិនិយោគសាធារណៈក្នុងវិស័យរបស់ខ្លួន។ ហើយក្រសួង ស្ថាប័នទាំងអស់ដែលជាម្ចាស់គម្រោងវិនិយោគសាធារណៈ ត្រូវរៀបចំរបាយការណ៍សមិទ្ធកម្មតាមរបបរបាយការណ៍នៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលក្នុង វិស័យរបស់ខ្លួនត្រូវជូនក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ បន្ថែមពីនេះ, ក្រសួង ស្ថាប័នទាំងអស់ដែលជាម្ចាស់គម្រោងវិនិយោគសាធារណៈ ត្រូវបង្កលក្ខណៈងាយស្រួលឱ្យក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលក្នុងវិស័យរបស់ខ្លួន។ ក្នុងករណីចាំបាច់ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី ត្រូវសហការពិគ្រោះយោបល់ ដើម្បីស្នើកែតម្រូវកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។

**តារាងសង្ខេបអំពីយន្តការស្ថាប័ន**




## ៤.២.៤. យន្តការគាំទ្រហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានតួនាទីរៀបចំគោលការណ៍ណែនាំរួមស្ដីពីយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់ការសិក្សាសមិទ្ធលទ្ធភាពនិងរៀបចំគម្រោង ដែលកំណត់ច្បាស់លាស់អំពីយន្តការគាំទ្រហិរញ្ញវត្ថុរួម និងតាមប្រភពហិរញ្ញប្បទាននីមួយៗ។ ជារួម, យន្តការគាំទ្រហិរញ្ញវត្ថុត្រូវអនុវត្តទៅតាមបង្គុចហិរញ្ញប្បទាននីមួយៗ ដូចខាងក្រោម៖

**ក. យន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ**

+ **<u>ថ្នាក់ជាតិ</u>**

បច្ចុប្បន្ន, គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ មានទំហំរីកធំឡើងជាលំដាប់ និងបានធ្វើឱ្យសមាមាត្រ មានចំនួនរហូតដល់ប្រមាណ ១ ភាគ ៣ ធៀបនឹងទំហំគម្រោងវិនិយោគហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍បានថយចុះមកសល់ត្រឹមប្រមាណ ២ ភាគ ៣ នៃទំហំវិនិយោគសាធារណៈសរុប។ ហេតុដូច្នេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានថវិកាជាសេនាធិការ បានកំណត់អំពីវិធាន និងនីតិវិធីសម្រាប់ការគ្រប់គ្រង និងអនុវត្តថវិកាសិក្សាគម្រោង ដើម្បីធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងតម្លាភាពនៃគម្រោងវិនិយោគផ្ទាល់ក្នុងក្របខ័ណ្ឌគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ។ ម្យ៉ាងទៀត, ថវិកាសិក្សាគម្រោង

វិនិយោគផ្ទាល់នេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ហើយការសិក្សាគម្រោង សំដៅដល់ការសិក្សាលើទិដ្ឋភាពពាក់ព័ន្ធ រួមមាន៖ បច្ចេកទេស តម្លៃ ហានិភ័យ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ច្បាប់ ហេតុប៉ះពាល់បរិស្ថាននិងសង្គម ស្របតាមតម្រូវការជាក់ស្តែងនៃការសិក្សាគម្រោង ដោយអនុលោមតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគផ្ទាល់ហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ។ ចំណែកឯ, ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈម្ចាស់គម្រោង ត្រូវបានអនុញ្ញាតឱ្យគ្រោងថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ ដែលជាកម្មវត្ថុនៃការពិនិត្យសម្រេចទៅតាមលទ្ធភាពនៃថវិកាប្រចាំឆ្នាំ។ ចំពោះការបង្កើត និងគ្រោងថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ គឺត្រូវស្របតាមចំណាត់ថ្នាក់នៃមាតិកាថវិកា ក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវគោរពតាមលក្ខខណ្ឌតម្រូវមួយចំនួន ដូចបានកំណត់នៅក្នុងនីតិវិធីប្រតិបត្តិនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់)។ ហើយនីតិវិធីនៃការអនុវត្តចំណាយថវិកាសិក្សាគម្រោងវិនិយោគផ្ទាល់ មានចំនួន ៤ ដំណាក់កាល រួមមាន៖ ការធានាចំណាយ, ការអនុវត្តកិច្ចលទ្ធកម្ម, ការអនុវត្តការសិក្សាគម្រោង, និងការទូទាត់។

បន្ថែមពីនេះ, យន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ នឹងមានការកែសម្រួល តាមការចាំបាច់ ដោយរួមបញ្ចូលការគិតគូរការវិនិយោគបៃតង បម្រែបម្រួលអាកាសធាតុ និងលក្ខខណ្ឌតម្រូវចាំបាច់នានា ដើម្បីធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, និងចីរភាពនៃការអនុវត្តគម្រោងវិនិយោគសាធារណៈ។

\+ **ថ្នាក់ក្រោមជាតិ**

គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្តទៅតាមទំហំថវិកា និងប្រភេទនៃគម្រោងនីមួយៗ ដោយផ្អែលើលទ្ធភាពថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ បច្ចុប្បន្ន, គម្រោងវិនិយោគសាធារណៈត្រូវបានបែងចែកជា ២ ប្រភេទគឺ៖ គម្រោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងគម្រោងសេវាកម្ម ប៉ុន្តែមិនទាន់មានយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងនៅឡើយទេ។ ហេតុដូច្នេះ, ទាមទារឱ្យមានការគិតគូររៀបចំយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់ការសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង ដោយរួមបញ្ចូលការគិតគូរការវិនិយោគបៃតង បម្រែបម្រួលអាកាសធាតុ និងលក្ខខណ្ឌតម្រូវចាំបាច់នានា ដើម្បីធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, និងចីរភាពនៃការអនុវត្តគម្រោងវិនិយោគសាធារណៈ។

**ខ. យន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីក្រៅប្រទេស**

ជាមួយនឹងការសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប កាលពីឆ្នាំ២០១៥ និងការបោះជំហានយ៉ាងស្វាហាប់ឈានឡើងក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ កម្ពុជាប្រឈមនឹងការបាត់បង់លក្ខខណ្ឌអនុគ្រោះពីប្រភពហិរញ្ញប្បទានប្រពៃណី និងត្រូវអនុវត្តតាមលក្ខខណ្ឌហិរញ្ញប្បទានថ្មី ដែលផ្អែកតាមធម្មនុញ្ញនៃដៃគូអភិវឌ្ឍន៍ ប្រភពហិរញ្ញប្បទានឥតសំណងកាន់តែរឹងស្ងួត និងកម្រិតសម្បទាននៃឥណទានកាន់តែទាបជាងមុន។

ក្នុងគោលដៅជំរុញល្បឿន និងប្រសិទ្ធភាពនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលជាសេនាធិការ បានបង្កើត «**ថវិកាសម្រាប់គាំទ្រការរៀបចំគម្រោង និងសិក្សាប្លង់សំណង់វិស្វកម្ម និងថវិកាសម្រាប់ចំណាយបុរេសកម្មភាពក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍**» ដែលត្រូវអនុវត្តក្នុងទម្រង់ជាមូលនិធិបង្វិល ដោយចំណាយនឹងត្រូវបានបង្វែរសងត្រឡប់មកវិញពី «**ហិរញ្ញប្បទានប្រតិសកម្ម**» របស់គម្រោង បន្ទាប់ពីគម្រោងបានចូលជាធរមាន។

**គ. យន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន**

យន្តការគាំទ្រហិរញ្ញវត្ថុ ត្រូវបានកំណត់ក្នុងជំពូកទី៥ នៃច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ក្នុងនោះ, សម្រាប់គាំទ្រដល់ការរៀបចំអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន, មូលនិធិចំនួន ២ ត្រូវបានបង្កើតរួមមាន៖ មូលនិធិអភិវឌ្ឍន៍គម្រោង សម្រាប់ភាពជាដៃគូរវាងរដ្ឋនិងឯកជន និងមូលនិធិបំពេញផលហិរញ្ញវត្ថុសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន។ មូលនិធិអភិវឌ្ឍន៍គម្រោងសម្រាប់ភាពជាដៃគូរវាងរដ្ឋនិងឯកជន ត្រូវបានបង្កើត ដើម្បីគាំទ្រលើការងាររៀបចំការសិក្សា និងអភិវឌ្ឍន៍គម្រោង រួមមាន៖ (ក) ការសិក្សាសមិទ្ធិលទ្ធភាពគម្រោង, (ខ) ការត្រួតពិនិត្យ និងវាយតម្លៃឡើងវិញលើការសិក្សាសមិទ្ធិលទ្ធភាពគម្រោង, (គ) ការសិក្សាទៅលើផ្នែកណាមួយនៃរបាយការណ៍សមិទ្ធិលទ្ធភាពគម្រោងពេញលេញ មានជាអាទិ៍៖ ការសិក្សាទៅលើតម្រូវការគម្រោង, ការវាយតម្លៃលើផលប៉ះពាល់បរិស្ថាន និងការសិក្សាលើសមិទ្ធិលទ្ធភាពផ្នែកហិរញ្ញវត្ថុ, (ឃ) ការគាំទ្រទៅដល់ការអនុវត្តកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជនសម្រាប់គម្រោង, និង (ង) ការរៀបចំកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន និងផែនការតាមដានការអនុវត្តគម្រោង។ល។ មូលនិធិនេះត្រូវបានប្រើប្រាស់ជាចាំបាច់សម្រាប់ការជួលសេវាទីប្រឹក្សាប្រតិបត្តិការសម្រាប់ការរៀបចំគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលផ្តួចផ្តើមដោយរដ្ឋ។ ក្នុងករណីដែលគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន, រាល់ចំណាយលើការរៀបចំអភិវឌ្ឍន៍គម្រោងដែលរួមមាន៖ ការត្រួតពិនិត្យ និងវាយតម្លៃឡើងវិញលើការសិក្សាសមិទ្ធិលទ្ធភាពគម្រោង, និងការរៀបចំកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន នឹងត្រូវរ៉ាប់រងដោយដៃគូឯកជន ផ្អែកតាមការចុះកិច្ចព្រមព្រៀងក្របខ័ណ្ឌសម្រាប់ការរៀបចំអភិវឌ្ឍន៍គម្រោង។ ប៉ុន្តែក្នុងករណីចាំបាច់, មូលនិធិអភិវឌ្ឍន៍គម្រោងសម្រាប់ភាពជាដៃគូរវាងរដ្ឋនិងឯកជន នឹងអាចប្រើប្រាស់សម្រាប់គម្រោងផ្តួចផ្តើមដោយឯកជន ហើយដៃគូឯកជននឹងត្រូវបង្វិលសងនូវចំណាយខាងលើមកបំពេញថវិកាក្នុងមូលនិធិអភិវឌ្ឍន៍គម្រោងសម្រាប់ភាពជាដៃគូរវាងរដ្ឋនិងឯកជនវិញ ផ្អែកតាមការព្រមព្រៀងណាមួយ។

ចំណែកមូលនិធិបំពេញផលហិរញ្ញវត្ថុសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ត្រូវបានប្រើប្រាស់ក្នុងសកម្មភាពផ្តល់ការបំពេញផលហិរញ្ញវត្ថុក្នុងទម្រង់ជាការឧបត្ថម្ភធនដោយផ្ទាល់ដល់ការចំណាយមូលធន ក្រោមក្របខ័ណ្ឌគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ដើម្បីបង្កើនផលចំណេញផ្នែកហិរញ្ញវត្ថុរបស់គម្រោងនោះ ចំពោះដៃគូឯកជន និងផ្តល់ការគាំទ្រផ្នែកវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈគាំទ្រសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ឬ គម្រោងអាទិភាពរបស់រាជរដ្ឋាភិបាលដែលមានការចូលរួមពីវិស័យឯកជន។ ដើម្បីទទួលបានការបំពេញផលហិរញ្ញវត្ថុគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ត្រូវបំពេញតាមលក្ខណវិនិច្ឆ័យទាំងអស់ ស្របតាមមាត្រា១០ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងមូលនិធិបំពេញផលហិរញ្ញវត្ថុសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន។

### ៤.២.៥. គោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ

បច្ចុប្បន្ន, គម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងពីថវិកាជាតិ ហិរញ្ញប្បទានក្រៅប្រទេស ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈក្រោមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ហិរញ្ញប្បទានចម្រុះ ហិរញ្ញប្បទានដោយការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម និងប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងទៀត) និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ត្រូវបានរៀបចំ និងអនុវត្តទៅតាមគោលការណ៍ និងអភិក្រមផ្សេងៗគ្នា ប៉ុន្តែមិនទាន់អាចធានាបាននូវប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមកនៅឡើយ។

**ក. គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ**

គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ ត្រូវបានបែងចែកជា ២ គឺ៖ ១)ថវិកាថ្នាក់ជាតិ និង២)ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

**+ ថ្នាក់ជាតិ**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ សហគ្រាសសាធារណៈ ដែលជាម្ចាស់គម្រោងត្រូវធ្វើការកំណត់អត្តសញ្ញាណគម្រោង ដោយអនុលោមតាមគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយតាមវិស័យ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម។ ម្យ៉ាងទៀត, គម្រោងត្រូវតែមានភាពចាំបាច់ចំពោះសេដ្ឋកិច្ច សង្គម បរិស្ថាន និងមានការគិតគូរពីបម្រែបម្រួលអាកាសធាតុ ព្រមទាំងឆ្លើយតបនឹងតម្រូវការអាទិភាពនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់-កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ, ផែនការមេតាមវិស័យ, ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀតរបស់រាជរដ្ឋាភិបាល។ ក្រសួង ស្ថាប័នម្ចាស់គម្រោងត្រូវរៀបចំឱ្យមានការសិក្សាអំពីគម្រោង ដោយផ្អែកតាមលក្ខខណ្ឌតម្រូវស្របតាមប្រភេទគម្រោងនីមួយៗ ក្នុងគោលបំណងសម្រិតសម្រាំង និងធ្វើអាទិភាវូបនីយកម្មសំណើគម្រោង ដើម្បីឈានទៅដល់ការជ្រើសរើសសំណើគម្រោង និងការធ្វើថវិកានីយកម្ម។

ចំណែក, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចក្នុងការវាយតម្លៃ និងពិនិត្យផ្ទៀងផ្ទាត់ឡើងវិញលើការវាយតម្លៃសំណើគម្រោងរបស់ក្រសួង ស្ថាប័នម្ចាស់គម្រោង។ ហើយការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្មគម្រោង ជាដំណាក់កាលដែលអគ្គនាយកដ្ឋានថវិកា (នាយកដ្ឋានវិនិយោគ) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំបញ្ជីគម្រោងអាទិភាព ដើម្បីគោរពស្នើសុំការពិនិត្យសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ រីឯ, គម្រោងទំហំធំ ដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ ជះឥទ្ធិពលដល់ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ និងមានភាពប្រទាក់ក្រឡាជាអន្តរវិស័យ គឺជាកម្មវត្ថុនៃការជ្រើសរើស ដោយគណៈកម្មការវិនិយោគសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ថែមពីនេះ, ក្រសួង ស្ថាប័នម្ចាស់គម្រោង និងភាគីពាក់ព័ន្ធ សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញតួនាទីនិងភារកិច្ចក្នុងការអនុវត្តនីតិវិធីចំណាយថវិកា ការអនុវត្តកិច្ចលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ ក្រសួង ស្ថាប័នម្ចាស់គម្រោង និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចតាមដានការអនុវត្តគម្រោង ដោយត្រូវផ្ទៀងផ្ទាត់វឌ្ឍនភាពនៃការអនុវត្តគម្រោងទៅនឹងផែនការអនុវត្តគម្រោង។ ជាគោលការណ៍, ក្រសួង ស្ថាប័នម្ចាស់គម្រោង អាចស្នើសុំកែសម្រួលគម្រោងបានក្នុងករណីចាំបាច់ និងពិតជាផ្តល់អត្ថប្រយោជន៍ដល់ការអនុវត្តគម្រោង។ ក្រសួង ស្ថាប័នម្ចាស់គម្រោង ត្រូវរៀបចំនិងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍វាយតម្លៃបញ្ចប់គម្រោងរាល់ពេលគម្រោងបានអនុវត្តចប់សព្វគ្រប់។

**+ ថ្នាក់ក្រោមជាតិ**

រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការឧបត្ថម្ភធន ឬ ការផ្ទេរធនធានថវិកាពីថ្នាក់ជាតិ និងចំណូលផ្ទាល់នៅមូលដ្ឋានសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋាន។ ក្រៅពីនេះ, រាជរដ្ឋាភិបាល ក៏បានដាក់ឱ្យអនុវត្តមូលនិធិមានភ្ជាប់លក្ខខណ្ឌ សម្រាប់ផ្តល់ហិរញ្ញប្បទានលើគម្រោងវិនិយោគសាធារណៈ ដែលមានចរិតលក្ខណៈជាយុទ្ធសាស្ត្រ ក្នុងគោលដៅជំរុញ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ផ្អែកលើកម្មវិធី និងអាទិភាព ដែលបានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ បានធ្វើការកំណត់អត្តសញ្ញាណគម្រោងដើម្បីរៀបចំ «**បញ្ជីគម្រោងវិនិយោគបឋម**» សម្រាប់ធ្វើការវាយតម្លៃ និងជ្រើសរើសគម្រោងអាទិភាព។ ក្នុងការជ្រើសរើសគម្រោងអាទិភាពចេញពីបញ្ជីគម្រោងវិនិយោគបឋម រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវផ្តោតជាសំខាន់លើទិដ្ឋភាពបច្ចេកទេស, សេដ្ឋកិច្ចនិងសង្គម រួមមាន៖ បច្ចេកទេសនៃការកសាងគម្រោង, តម្លៃ, សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ច្បាប់, ហានិភ័យ, ហេតុប៉ះពាល់សង្គម និងបរិស្ថាន ព្រមទាំង យន្តការគ្រប់គ្រង និងអនុវត្តគម្រោង។ គម្រោងអាទិភាពត្រូវដាក់ជូន

ក្រុមប្រឹក្សានៃរដ្ឋបាលសាមីពិនិត្យ និងអនុម័ត រួចបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីធ្វើសមាហរណកម្មទៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានតួនាទីផ្តល់យោបល់ និងធ្វើការសម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ លើបញ្ហាទាក់ទងនឹងការស្នើគម្រោងវិនិយោគសាធារណៈ ក្នុងគោលដៅដើម្បីធ្វើសមាហរណកម្មគម្រោងអាទិភាពទៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ការធ្វើសមាហរណកម្មគម្រោងអាទិភាព គឺការធានាឱ្យមានការផ្សារភ្ជាប់គ្នាប្រកបដោយប្រសិទ្ធភាពរវាងផែនការ/កម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីប្រើប្រាស់ធនធានដែលមានកម្រិតក្នុងការសម្រេចឱ្យបានសមិទ្ធផលជាអតិបរមា។

ការជ្រើសរើសការស្នើគម្រោង និងការធ្វើថវិកានីយកម្មគម្រោង គឺជាដំណាក់កាលដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ធ្វើការកំណត់ប្រភពហិរញ្ញប្បទាន ដើម្បីរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ការជ្រើសរើសគម្រោងអាទិភាពសម្រាប់ធ្វើថវិកានីយកម្ម ត្រូវធានាថាគម្រោងអាទិភាពទាំងនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយផ្អែកតាមគោលការណ៍គន្លឹះចំនួន ៧ នៃការធ្វើថវិកានីយកម្មគម្រោង ពោលគឺ៖ គោលការណ៍សនិទានកម្ម, គោលការណ៍ផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, គោលការណ៍ជម្រើសប្រសើរបំផុត, គោលការណ៍ភាពអាចទ្រទ្រង់បាននៃថវិកា, គោលការណ៍អភិវឌ្ឍន៍បៃតង, គោលការណ៍ភាពអាចអនុវត្តបាន, និងគោលការណ៍ភាពរួចរាល់សម្រាប់ការចាប់ផ្តើមអនុវត្តគម្រោង។

រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនៃគម្រោងវិនិយោគ ត្រូវប្រើប្រាស់សិទ្ធិ និងតួនាទី ដើម្បីអនុវត្តគម្រោងវិនិយោគសាធារណៈ ស្របទៅតាមគោលការណ៍ណែនាំ, វិធានបទដ្ឋានបច្ចេកទេស, កិច្ចសន្យា, លក្ខខណ្ឌនៃកិច្ចសន្យា និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ គម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រប់គ្រង និងអនុវត្តក្នុងក្របខ័ណ្ឌនៃការអនុវត្តប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងត្រូវគោរពតាមគោលការណ៍សំខាន់ៗ ដូចបានកំណត់នៅក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចតាមដានការអនុវត្តគម្រោង ដោយត្រូវផ្ទៀងផ្ទាត់វឌ្ឍនភាពនៃការអនុវត្តគម្រោងទៅនឹងផែនការអនុវត្តគម្រោង។

### ខ. គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានក្រៅប្រទេស

ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ក្រសួងផែនការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើអាទិភាវូបនីយកម្មលើសំណើគម្រោងវិនិយោគសាធារណៈ ដែលបានស្នើឡើងដោយក្រសួង ស្ថាប័នសាមី ដើម្បីរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល និងត្រូវដាក់ស្នើសុំការអនុម័តពីគណៈរដ្ឋមន្ត្រី។ ទន្ទឹមគ្នានេះ, ដៃគូអភិវឌ្ឍន៍នីមួយៗសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នជំនាញ, រៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការភាពជាដៃគូរយៈពេលមធ្យម ដោយកំណត់អំពីកម្មវិធី/គម្រោង និងវិស័យអាទិភាពដែលដៃគូអភិវឌ្ឍន៍នីមួយៗនឹងរួមចំណែកជួយគាំទ្រដល់កិច្ចអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការភាពជាដៃគូនេះ ត្រូវបានរៀបចំដោយផ្អែកលើរបៀបវារៈអភិវឌ្ឍន៍របស់ដៃគូនីមួយៗ និងឆ្លើយតបតាមតម្រូវការអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល អនុលោមតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់ស្ថាប័ន ដែលត្រូវបំពេញមុខងារជាភ្នាក់ងារប្រតិបត្តិ និងអនុវត្តគម្រោង ដោយផ្អែកលើសមត្ថកិច្ច និងអាណត្តិកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ ព្រមទាំងដឹកនាំការចរចាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍។ បន្ទាប់ពីគម្រោងត្រូវបានប្រកាសចូលជាធរមាន ក្រសួង ស្ថាប័នជាភ្នាក់ងារអនុវត្តគម្រោង ត្រូវដឹកនាំគ្រប់គ្រងការអនុវត្ត ដោយអនុលោមតាមខ្លឹមសារនៃកិច្ចព្រមព្រៀងហិរញ្ញប្បទាន និងនីតិវិធីរួម សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍។

### គ. គម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន

គម្រោងវិនិយោគសាធារណៈ អាចធ្វើការរៀបចំអភិវឌ្ឍន៍តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន បាន លុះត្រាតែគម្រោងនោះ ជាគម្រោងដែលត្រូវបានបញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល និង/ឬ ផែនការមេតាមវិស័យ ដោយបំពេញនូវលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងមាត្រា៩ នៃច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងដំណាក់កាលធ្វើអត្តសញ្ញាណកម្មគម្រោង។ បន្ទាប់ពីធ្វើអត្តសញ្ញាណកម្មរួច, ក្រសួង ស្ថាប័នសាមី ត្រូវរៀបចំសំណើមកកាន់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ចូលគម្រោងនោះ ក្នុងបញ្ជីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជនសក្តានុពល។ ជានីតិវិធីបន្ទាប់, អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន នឹងពិនិត្យទៅលើសំណើនោះជាមុនសិន ទើបដាក់ឆ្លងគណៈកម្មការវិនិយោគសាធារណៈ ដើម្បីពិនិត្យ និងវាយតម្លៃលើភាពចាំបាច់នៃការរៀបចំអភិវឌ្ឍន៍គម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន រួចទើបដាក់ស្នើការអនុម័តពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លុះត្រាតែគម្រោងនោះទទួលបានការអនុម័តដាក់បញ្ចូលក្នុងបញ្ជីគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជនអាទិភាព ទើបគម្រោងនោះមានសិទ្ធិរៀបចំអភិវឌ្ឍន៍តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។

ជាទូទៅ, គម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ត្រូវបានបែងចែកជា ២ គឺ៖ ១)គម្រោងផ្តួចផ្តើមដោយរដ្ឋ និង២)គម្រោងផ្តួចផ្តើមដោយឯកជន។ គម្រោងផ្តួចផ្តើមដោយរដ្ឋ សំដៅដល់គម្រោងដែលត្រូវបានស្នើឡើងរៀបចំដោយស្ថាប័នសាមី និងមានសក្តានុពលអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ចំណែកឯ, គម្រោងផ្តួចផ្តើមដោយឯកជន សំដៅដល់គម្រោងដែលមានសក្តានុពលអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលត្រូវបានស្នើឡើងដោយវិស័យឯកជន តាមរយៈស្ថាប័នសាមី។

ផ្អែកតាមមាត្រា៨ នៃច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន, វិស័យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និង/ឬ ការផ្គត់ផ្គង់សេវាសាធារណៈ ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន រួមមាន៖ វិស័យដឹកជញ្ជូន, វិស័យភស្តុភារកម្ម, វិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល, វិស័យថាមពល និងវិស័យសេវាសាធារណៈ មានជាអាទិ៍ ការផ្គត់ផ្គង់ទឹកស្អាត, ការគ្រប់គ្រងសំណល់រឹង និងការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់, វិស័យសុខាភិបាល, វិស័យអប់រំ, វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, វិស័យទេសចរណ៍, វិស័យវប្បធម៌និងសិល្បៈ, វិស័យកីឡា និងលំនៅឋានសង្គម, វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា, វិស័យកសិកម្ម និងប្រព័ន្ធធារាសាស្ត្រ, និងវិស័យផ្សេងៗទៀត ដែលច្បាប់ដោយឡែកអនុញ្ញាត។

បន្ថែមពីនេះ, ការជ្រើសរើសដៃគូឯកជន សម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋ និងគម្រោងផ្តួចផ្តើមដោយឯកជន នឹងត្រូវប្រព្រឹត្តទៅតាមវិធីសាស្ត្រ ដូចតទៅ៖

+ **គម្រោងផ្តួចផ្តើមដោយរដ្ឋ**

ការជ្រើសរើសដៃគូឯកជនសម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋអាចអនុវត្តតាមវិធីសាស្ត្រដេញថ្លៃ ដោយប្រកួតប្រជែង ឬ តាមវិធីសាស្ត្រការចុះកិច្ចសន្យាផ្ទាល់។ ចំពោះការជ្រើសរើសដេញថ្លៃដោយប្រកួតប្រជែង, អ្នកដេញថ្លៃជាប់លំដាប់លេខរៀងទី១ ត្រូវបានអញ្ជើញមកចរចាលើសេចក្តីព្រាងកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន ជាមួយក្រុមការងាររបស់រាជរដ្ឋាភិបាល អនុលោមតាមនីតិវិធី ដែលមានកំណត់ក្នុងច្បាប់ និងនីតិវិធីប្រតិបត្តិការរួម សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ក្នុងករណីដែលអ្នកដេញថ្លៃជាប់លំដាប់លេខរៀងទី១ នោះខកខានក្នុងការចូលរួមការចរចាតាមការអញ្ជើញ។ ស្ថាប័នសាមីអាចអញ្ជើញអ្នកដេញថ្លៃជាប់លំដាប់លេខរៀងបន្ទាប់ មកចរចាលើសេចក្តីព្រាងកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន រហូតដល់ការចុះហត្ថលេខា លើកិច្ចសន្យានោះជាមួយដៃគូឯកជន។ ដោយឡែក, វិធីសាស្ត្រចុះកិច្ចសន្យាផ្ទាល់សម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការសម្រេចពីរាជរដ្ឋាភិបាល តាមសំណើរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នសាមី។

+ **គម្រោងផ្តួចផ្តើមដោយឯកជន**

ស្ថាប័នសាមីអាចទទួលសំណើគម្រោងផ្តួចផ្តើមដោយឯកជន លុះត្រាតែគម្រោងនោះជាគម្រោងដែលមានទស្សនាទានថ្មី បច្ចេកវិទ្យាថ្មី ឬ នវានុវត្តន៍ដែលអាចមានប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា និងទទួលបានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល។

**ឃ.គម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយការធ្វើការឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ**

កន្លងមកនេះ, គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈមួយចំនួន ត្រូវបានហិរញ្ញប្បទានដោយថវិកាបានពីការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ តាមរយៈការលក់ ជួល ឬ ដោះដូរទ្រព្យសម្បត្តិរដ្ឋ។ ជាគោល-ការណ៍, ថវិកាដែលទទួលបានពីការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ត្រូវបានជាគុណប្រយោជន៍នៃថវិកាជាតិ ហើយរាជរដ្ឋាភិបាលចាត់ចែងប្រើប្រាស់សម្រាប់មុខចំណាយអាទិភាព និងចំណាយវិនិយោគសាធារណៈទៅតាមនីតិវិធីគ្រប់គ្រងតាមប្រភេទចំណាយជាធរមាន។ បើទោះបីជាយ៉ាងនេះក្តី, ក្នុងការអនុវត្តកន្លងមក មានករណីដោយឡែកមួយចំនួន ដែលការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ត្រូវបានផ្តល់ជាថ្នូរមកវិញដោយវិស័យឯកជនចាត់ចែងអនុវត្តគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ តាមអភិក្រម «**ប្រគល់សោរដល់ដៃគូ-Turnkey Contract**» ជូនភាគីរាជរដ្ឋាភិបាលតែម្តង ដោយនីតិវិធី និងយន្តការគ្រប់គ្រងការអនុវត្តគម្រោងរបស់ក្រសួងជំនាញ និងមុខងារជាទ្វារបាលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនត្រូវបានប្រើប្រាស់ពេញលេញ សម្រាប់គោលដៅនៃការធានាប្រសិទ្ធភាពសេដ្ឋកិច្ចនៃការវិនិយោគសាធារណៈបែបនេះទេ។ ការណ៍នេះ, តម្រូវឱ្យរាជរដ្ឋាភិបាលត្រូវដាក់ចេញនូវវិធាន និងនីតិវិធីគ្រប់គ្រងច្បាស់លាស់ សម្រាប់គ្រប់គ្រងគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈប្រភេទនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

**ង. គម្រោងវិនិយោគសាធារណៈ ដោយគ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែលដទៃទៀត**

+ **គ្រឹះស្ថានសាធារណៈរដ្ឋបាល**

គម្រោងវិនិយោគសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានរៀបចំ និងសម្រេចដោយក្រុមប្រឹក្សា-ភិបាល ដែលជាអង្គការដឹកនាំខ្ពស់បំផុតរបស់គ្រឹះស្ថាន ដោយផ្អែកលើផែនការអភិវឌ្ឍន៍របស់គ្រឹះស្ថាន សម្រាប់រយៈពេលមធ្យម និងវែង។ គម្រោងថវិការបស់គ្រឹះស្ថាន ត្រូវបានរៀបចំដោយនាយកគ្រឹះស្ថាន ដើម្បីដាក់ជូនក្រុម-ប្រឹក្សាភិបាល ពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ពិនិត្យ និងសម្រេចមុននឹងបញ្ជូនបន្តទៅក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច ដោយអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

+ **សហគ្រាសសាធារណៈ**

ស្រដៀងគ្នាទៅនឹងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែរ, គម្រោងវិនិយោគសាធារណៈរបស់សហគ្រាសសាធារណៈត្រូវបានរៀបចំ និងសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាល សម្រេចគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគដោយផ្អែកតាមផែនការអភិវឌ្ឍន៍សហគ្រាស ដែលឯកសារទាំងនេះ ត្រូវដាក់សុំការអនុម័តយល់ព្រមពីក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ។

**ច. គម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម**

បច្ចុប្បន្ន, កម្ពុជាបានបោះផ្សាយមូលបត្ររដ្ឋ ដែលជាការខ្ចីក្នុងប្រទេស មានលក្ខខណ្ឌជាឥណទានពាណិជ្ជកម្មសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ ដោយគិតចាប់ពីការបោះផ្សាយលើកដំបូងនៅ ឆ្នាំ២០២២ រហូតដល់បច្ចុប្បន្ន។ ទោះជាយ៉ាងនេះក្តី, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាលតែមួយគត់

ដែលទទួលបានសិទ្ធិស្របតាមច្បាប់ក្នុងការបំពេញមុខងារជាអ្នកបោះផ្សាយលក់មូលបត្ររដ្ឋ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល ជាអង្គភាពទទួលបន្ទុកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនិងបំណុលសាធារណៈ ដោយរួមទាំងមូលបត្ររដ្ឋ។ ចំពោះការបោះផ្សាយលក់មូលបត្ររដ្ឋ, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល មានតួនាទីជំរុញការអភិវឌ្ឍ និងគ្រប់គ្រងការបោះផ្សាយលក់មូលបត្ររដ្ឋ ដោយបំពេញភារកិច្ចចម្បងៗ ដូចជា៖ រៀបចំសម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍមូលបត្ររដ្ឋ, សម្របសម្រួលលើរាល់កិច្ចការបច្ចេកទេសពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ជាមួយអាណត្តិគាហក និងតួអង្គពាក់ព័ន្ធផ្សេងទៀត, រៀបចំ និងផ្សព្វផ្សាយផែនការបោះផ្សាយលក់មូលបត្ររដ្ឋ, ពិគ្រោះយោបល់ជាមួយអ្នកចូលរួមក្នុងទីផ្សារ, គ្រប់គ្រងត្រួតពិនិត្យតាមដាន និងសម្របសម្រួលការអនុវត្ត គម្រោង/កម្មវិធីហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការឱ្យខ្ចីផ្ទាល់, និងពីមូលបត្ររដ្ឋ។

បច្ចុប្បន្ន, មូលបត្ររដ្ឋដែលត្រូវបានបោះផ្សាយកន្លងមក អាចត្រូវបានជួញដូរតែក្នុងចំណោមគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលជាសមាជិកនៃផ្លែតហ្វមធនាគារជាតិនៃកម្ពុជា ប៉ុណ្ណោះ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលបាននិងកំពុងបន្តជំរុញការរៀបចំទីផ្សារបន្ទាប់ឱ្យបានឆាប់ និងពេញលេញ ឬ គ្រប់ជ្រុងជ្រោយ តាមរយៈការពន្លឿនការដាក់ចេញនូវលិខិតបទដ្ឋានគតិតយុត្ត និងការរៀបចំប្រព័ន្ធគាំទ្រទីផ្សារហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ដំណើរការការជួញដូរមូលបត្ររដ្ឋ។

**ធ. គម្រោងវិនិយោគសាធារណៈ ដោយប្រភពហិរញ្ញប្បទានចម្រុះ**

ការវិនិយោគសាធារណៈដោយប្រភពហិរញ្ញប្បទានចម្រុះ ត្រូវបានប្រើប្រាស់ភាគច្រើនសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងនោះ មានការប្រើប្រាស់ហិរញ្ញប្បទានដោយទុនវិនិយោគសាធារណៈ ជាយុទ្ធសាស្ត្រសម្រាប់ទាក់ទាញទុនវិនិយោគបន្ថែមពីវិស័យឯកជន សំដៅឆ្ពោះទៅសម្រេចគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព និងជំរុញការហក់ឡើងនៃកំណើនសេដ្ឋកិច្ច។ ទុនវិនិយោគសាធារណៈ ដែលផ្តល់ជូននេះ អាចមានទម្រង់ជាការផ្តល់មូលនិធិបំពេញផលហិរញ្ញវត្ថុ ក្នុងការបំពេញបន្ថែមលើចំណាយមូលធនរបស់ដៃគូឯកជន ឬ ការផ្តល់ជាមូលនិធិអភិវឌ្ឍន៍គម្រោង ក្នុងការគាំទ្រដល់ការសិក្សាសមិទ្ធិលទ្ធភាពគម្រោង ក្នុងគោលដៅសម្រាលបន្ទុកចំណាយ និងបង្កើនទំនុកចិត្តសម្រាប់ដៃគូឯកជនចូលរួមផ្តល់ទុនវិនិយោគរៀបចំអភិវឌ្ឍន៍គម្រោងនោះ។ ជាទូទៅ, គម្រោងវិនិយោគប្រភេទនេះ ត្រូវបានផ្តោតលើវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ថាមពល ការផ្គត់ផ្គង់ទឹកស្អាត ផ្លូវថ្នល់ និងលំនៅឋានមានតម្លៃសមរម្យ ជាដើម។

ក្នុងន័យនេះ, ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការប្រើប្រាស់ហិរញ្ញប្បទានចម្រុះ រាជរដ្ឋាភិបាលគួរជំរុញ និងលើកទឹកចិត្តឱ្យមានការរៀបចំអភិវឌ្ឍន៍គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ទន្ទឹមនឹងការដាក់ចេញនូវគោលការណ៍ណែនាំច្បាស់លាស់ និងមានភាពទន់ភ្លន់សម្រាប់ការប្រើប្រាស់ហិរញ្ញប្បទានប្រភេទនេះសំដៅចូលរួមសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

## ៤.៣. បញ្ហាប្រឈម និងកាលានុវត្តភាព

### ៤.៣.១. បញ្ហាប្រឈម

រហូតមកដល់ពេលនេះ, ទោះបីលិខិតបទដ្ឋានគតិយុត្ត, គោលការណ៍, អភិក្រម, យន្តការស្ថាប័ន, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ ត្រូវបានរៀបចំ និងកំពុងបន្តរៀបចំជាបណ្តើរៗក៏ដោយ ក៏ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅកម្ពុជា បាននិងកំពុងប្រឈមនឹងបញ្ហាមួយចំនួន ដូចខាងក្រោម៖

- **ក្របខ័ណ្ឌគតិយុត្ត**

នៅក្នុងដំណាក់កាលបន្ទាប់នេះ ទាមទារឱ្យមានការពិនិត្យឡើងវិញ ឬ ធ្វើបច្ចុប្បន្នកម្មលិខិតបដ្ឋានគតិយុត្តគោលមួយចំនួន ដើម្បីកំណត់អំពីអភិក្រម គោលការណ៍ និងសមត្ថកិច្ចស្ថាប័នក្នុងការកំណត់អត្តសញ្ញាណកម្ម, រៀបចំ, គ្រប់គ្រង, និងអនុវត្តគម្រោងវិនិយោគសាធារណៈ ឱ្យបានច្បាស់លាស់ និងពេញលេញ។

- **ការធ្វើអត្តសញ្ញាណកម្ម និងការរៀបចំសំណើគម្រោងបឋម**
- ផែនការវិនិយោគសាធារណៈរយៈពេលមធ្យម៖ ផែនការវិនិយោគសាធារណៈ ត្រូវបានរៀបចំសម្រាប់តែគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ប៉ុណ្ណោះ ក្នុងទម្រង់ជាកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។ ដោយឡែក, ផែនការសម្រាប់គម្រោងពីប្រភពហិរញ្ញប្បទានផ្សេងៗ នៅពុំទាន់រៀបចំបានពេញលេញនៅឡើយ
- កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលមិនទាន់ឆ្លើយតបបានពេញលេញទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយសារ «**គោលការណ៍ណែនាំសម្រាប់រៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល**» នៅពុំទាន់រៀបចំដាក់ឱ្យអនុវត្តពេញលេញ និងគ្រប់ជ្រុងជ្រោយនៅឡើយ សម្រាប់ជាមូលដ្ឋានឱ្យក្រសួង ស្ថាប័នជំនាញ អាចកំណត់អត្តសញ្ញាណគម្រោងបានត្រឹមត្រូវ ព្រមទាំងបន្សុី និងតម្រឹមសំណើគម្រោងដាក់លាក់នីមួយៗ ទៅតាមគោលបំណង និងគោលដៅនៃផែនការអភិវឌ្ឍន៍ជាតិ
- ការសម្របសម្រួលផ្ទៃក្នុងនៅកម្រិតក្រសួង ស្ថាប័នជំនាញ ក្នុងការកំណត់អត្តសញ្ញាណកម្មនិងរៀបចំសំណើគម្រោងវិនិយោគសាធារណៈ និងរៀបចំផែនការគម្រោងវិនិយោគសាធារណៈ នៅមានកម្រិត
- មិនទាន់មានយន្តការសម្របសម្រួលច្បាស់លាស់ នៅដំណាក់កាលសមាហរណកម្មផែនការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន និងពីគ្រប់កម្រិតរដ្ឋបាល ដើម្បីកសាងនូវផែនការវិនិយោគសាធារណៈ ដែលមានភាពគ្រប់ជ្រុងជ្រោយ ជានាឱ្យគម្រោងទាំងអស់ប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមក ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច និងឆ្លើយតបនឹងគោលបំណងរួមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- យន្តការសម្របសម្រួលនៅដំណាក់កាលរៀបចំផែនការវិនិយោគសាធារណៈ មិនទាន់ពេញលេញ
- វិស័យមួយចំនួនមិនទាន់មានផែនការមេ ឬ ផែនការអភិវឌ្ឍន៍តាមវិស័យ
- ការគ្រប់គ្រងគម្រោងវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានលក្ខណៈដាច់ពីគ្នាទៅតាមប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមិនមានការផ្សារភ្ជាប់គ្នាបានល្អទៅនឹងគម្រោងវិនិយោគដែលអនុវត្តដោយក្រសួង ស្ថាប័នថ្នាក់ជាតិ។
- **ការសិក្សាសមិទ្ធិលទ្ធភាព ការវាយតម្លៃ និងការរៀបចំសំណើគម្រោងផ្លូវការ**
- យន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់ការសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង កំពុងត្រូវបានរៀបចំគោល-ការណ៍ណែនាំរួមស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់ការសិក្សាសមិទ្ធិលទ្ធភាព ខណៈដែលគោលការណ៍ណែនាំស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុតាមប្រភពហិរញ្ញប្បទានមួយចំនួនត្រូវបានរៀបចំដូចជា ប្រភពហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ, ប្រភពហិរញ្ញប្បទានតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន, និងប្រភពហិរញ្ញប្បទានពីក្រៅប្រទេស លើកលែងតែប្រភពហិរញ្ញប្បទានថវិកាថ្នាក់ក្រោមជាតិ
- សម្រាប់គម្រោងវិនិយោគសាធារណៈតាមប្រភពហិរញ្ញប្បទានមួយចំនួន ពុំទាន់មានការសិក្សាឱ្យបានពេញលេញនូវការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន ក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង។ ដោយហេតុថាផ្អែកតាមនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ផលប៉ះពាល់បរិស្ថាន និងសង្គម គឺត្រូវបានធ្វើការសិក្សា និងកំណត់នៅក្នុងរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគម្រោងដែលកិច្ចការងារនេះក៏បានអនុវត្តនៅក្នុងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជននីមួយៗ។

- **ការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង**
  - មុខងារទ្វារបាលកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងដំណាក់កាលបុរេថវិកានីយកម្មគម្រោងវិនិយោគសាធារណៈ នៅមានភាពចាំបាច់ត្រូវបន្តពង្រឹងបន្ថែម
  - រៀបចំ និងបន្តពង្រឹងយន្តការគ្រប់គ្រងនៅដំណាក់កាលបុរេថវិកានីយកម្មការវិនិយោគសាធារណៈ ដើម្បី៖ ១)ពិនិត្យ និងវាយតម្លៃលើសំណើគម្រោងរបស់ក្រសួង ស្ថាប័ន, និង២)ជ្រើសរើសគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមិនប៉ះពាល់ធ្ងន់ធ្ងរដល់កញ្ចប់ថវិកាជាតិ សម្រាប់ការងារដោះស្រាយផលប៉ះពាល់, កំណត់ប្រភពហិរញ្ញប្បទានសមស្រប, និងដាក់ចូលក្នុងដំណាក់កាលថវិកានីយកម្ម។
- **ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម**
  - ពុំទាន់មានប្រព័ន្ធពេញលេញ សម្រាប់ធ្វើសមាហរណកម្មថវិកាវិនិយោគសាធារណៈជាមួយនឹងថវិកាចរន្តសម្រាប់គម្រោងវិនិយោគសាធារណៈ ជាពិសេស គឺថវិកាប្រតិបត្តិការ និងថែទាំ។ បច្ចុប្បន្ន, ទោះបីផែនការយុទ្ធសាស្ត្រថវិកាត្រូវបានប្រើប្រាស់ជាឧបករណ៍ សម្រាប់ការធ្វើសមាហរណកម្មថវិកាវិនិយោគ ជាមួយនឹងថវិកាចរន្តក្តី ប៉ុន្តែជាក់ស្តែង ការវិភាជថវិកាចរន្ត សម្រាប់ទ្រទ្រង់ចំណាយប្រតិបត្តិការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវបានសាងសង់រួច មិនទាន់ត្រូវបានគ្រោងឱ្យបានគ្រប់ជ្រុងជ្រោយ និងឆ្លើយតបតម្រូវការចាំបាច់ទាំងស្រុងនៅឡើយ។ ការណ៍នេះ ទាមទារឱ្យមានការបន្តគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយបន្ថែមទៀត។
- **ការគ្រប់គ្រង និងការអនុវត្តគម្រោង**

ចំពោះគម្រោងវិនិយោគសាធារណៈដោយថវិកាជាតិ មាននីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់), នីតិវិធីរួមសម្រាប់ការគ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំណត់អំពីគោលការណ៍ អភិក្រម នីតិវិធី និងយន្តការក្នុងការរៀបចំគម្រោង, ការពិនិត្យ និងវាយតម្លៃសំណើគម្រោង, ការជ្រើសរើស, ការធ្វើថវិកានីយកម្ម, និងការគ្រប់គ្រងនិងអនុវត្តគម្រោងទៅតាមដំណាក់កាលនីមួយៗ នៃវដ្តគម្រោង។ ក្នុងករណីចាំបាច់, នីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់) នីតិវិធីរួមសម្រាប់ការគ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវធ្វើបច្ចុប្បន្នកម្ម ដោយរួមបញ្ចូលការគិតគូរបម្រែបម្រួលអាកាសធាតុ និងលក្ខខណ្ឌតម្រូវចាំបាច់នានា។ ចំពោះគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន, ការគ្រប់គ្រងកិច្ចសន្យា នឹងត្រូវអនុវត្តស្របតាមនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ភាគទី២៖ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន សម្រាប់ការតាមដាន និងគ្រប់គ្រងកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន និងអាចធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់។

- **ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមគម្រោង**

នៅមានភាពចាំបាច់ត្រូវបន្តពង្រឹងបន្ថែម និងធ្វើស្ថាបនូបនីយកម្មនូវយន្តការ, គោលការណ៍, និងនីតិវិធីគ្រប់គ្រងលើការប្រើប្រាស់និងថែទាំហេដ្ឋារចនាសម្ព័ន្ធក្រោយបញ្ចប់ការសាងសង់ ដើម្បីធានាប្រសិទ្ធភាព និងចីរភាពនៃហេដ្ឋារចនាសម្ព័ន្ធ។ ទន្ទឹមនេះ, ទ្រព្យសម្បត្តិគម្រោងមិនទាន់ត្រូវបានចុះបញ្ជីឱ្យបានពេញលេញនោះទេ។

- **ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង**

សម្រាប់គម្រោងវិនិយោគសាធារណៈដោយប្រើប្រាស់ប្រភពហិរញ្ញប្បទានមួយចំនួន នៅមិនទាន់មានយន្តការវាយតម្លៃពេញលេញក្រោយបញ្ចប់ការអនុវត្តគម្រោងសម្រាប់វាយតម្លៃប្រសិទ្ធភាពនៃគម្រោង ដែលជាមូលដ្ឋានក្នុងការរៀនសូត្រដកពិសោធន៍សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំ និងអនុវត្តគម្រោងវិនិយោគក្រោយៗទៀត។ ដោយឡែក, សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន, យន្តការនៃការបញ្ចប់ការអនុវត្តគម្រោងនឹងត្រូវរៀបចំដោយអនុលោមតាមនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ភាគទី២៖ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលចែងអំពីកាតព្វកិច្ចរបស់ភាគីរដ្ឋនិងដៃគូឯកជន ដែលត្រូវបំពេញនៅដំណាក់កាលបញ្ចប់កិច្ចសន្យាគម្រោង សំដៅធានាបាននូវប្រសិទ្ធភាព និងគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ មុននឹងធ្វើការប្រគល់មកភាគីរដ្ឋវិញ។

- **បញ្ហាប្រឈមផ្សេងៗ**

- ប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងវិនិយោគសាធារណៈនៅតាមក្រសួង ស្ថាប័នមានដាច់ដោយឡែកពីគ្នា និងខ្លះមិនទាន់ធ្វើបច្ចុប្បន្នកម្ម ឬ ទំនើបកម្មនៅឡើយ
- មិនទាន់បានកសាងនិម្មាបនកម្មនៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ
- ធនធានមនុស្ស នៅមានកម្រិត ក្នុងការសិក្សាសមិទ្ធិលទ្ធភាពរបស់ក្រសួង ស្ថាប័នជាម្ចាស់គម្រោង, ពិនិត្យវាយតម្លៃឯកសារសមិទ្ធិលទ្ធភាពនៃគម្រោង និងការពិនិត្យបញ្ជីប៉ាន់តម្លៃ និងប្លង់បច្ចេកទេសគ្រប់ជ្រុងជ្រោយ
- កង្វះប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដែលជាមូលដ្ឋានក្នុងការពង្រឹងប្រសិទ្ធភាពសម្រាប់រៀបចំផែនការគម្រោងវិនិយោគ ក៏ដូចជាការត្រួតពិនិត្យតម្លៃនៃគម្រោង
- រដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់មានប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរួមទេ។

## ៤.៣.២. ការលានុវត្តភាព

ទន្ទឹមនឹងបញ្ហាប្រឈមខាងលើ ក្នុងបរិការណ៍នៃដំណាក់កាលអភិវឌ្ឍន៍ថ្មីរបស់កម្ពុជា, រាជរដ្ឋាភិបាលនឹងបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ ដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព ប្រកបដោយបរិយាប័ន្ន ដោយឈរលើមូលដ្ឋាននៃកាលានុវត្តភាពមួយចំនួន ដូចខាងក្រោម៖

- ឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាល ក្នុងការឈានឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់
- ការដាក់ចេញ និងអនុវត្តយ៉ាងសកម្មនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីជំរុញ និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការវិនិយោគសាធារណៈ
- កំណើននៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាសាធារណៈ ទាំងបរិមាណ និងគុណភាពនៅតែបន្ត
- កំណើននៃចំណូលថវិកាជាតិ ដែលនឹងជួយបង្កើនលទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការពង្រីកទំហំនៃការវិនិយោគសាធារណៈ
- ដៃគូអភិវឌ្ឍន៍ប្រពៃណី និងដៃគូអភិវឌ្ឍន៍ថ្មីៗ កំពុងនៅបន្តពង្រីកទំហំហិរញ្ញប្បទានសហប្រតិបត្តិការ
- ដៃគូអភិវឌ្ឍន៍ធំៗមួយចំនួន បាននិងកំពុងផ្តល់ការគាំទ្រជាអាទិភាពលើការពង្រឹងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា

- ការបន្តអនុវត្តដោយជោគជ័យលើការដ្ឋានកែទម្រង់សំខាន់ៗទាំងបី រួមមាន៖ ១)កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២)កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, និង៣)កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- ការដាក់ចេញនូវវិស័យអាទិភាពសម្រាប់អនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងរយៈពេល ១០ ឆ្នាំ (២០២៥-២០៣៥) ទៅលើវិស័យដឹកជញ្ជូន និងភស្តុភារកម្ម, វិស័យថាមពល, និងវិស័យសេវាសាធារណៈ (ការផ្គត់ផ្គង់ទឹកស្អាត និងការគ្រប់គ្រងសំណល់) តាមរយៈសេចក្តីសម្រេចលេខ ២៣០ សសរ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ដោយរាជរដ្ឋាភិបាល
- ការដាក់ចេញ និងការអនុវត្តយ៉ាងសកម្មនូវយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាបច្ចុប្បន្នកម្មឆ្នាំ២០២៥-២០២៨, យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា, យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤-២០២៨, យុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត នឹងរួមចំណែកបន្តលើកកម្ពស់ប្រសិទ្ធភាព និងភាពជោគជ័យបន្ថែមទៀតលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងពង្រឹងប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ។

# ជំពូកទី៥
# វិធានការជាយុទ្ធសាស្ត្រ

# ជំពូកទី៥
# វិធានការជាយុទ្ធសាស្ត្រ

ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល គឺការរៀបចំ និងដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រ សំដៅបង្កើតប្រព័ន្ធរួមមួយរបស់ជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន គ្រប់កម្រិតរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នាជាជំហានៗ ដែលរួមមាន៖

- បន្តរៀបចំ ពិនិត្យ កែសម្រួល ឬ ធ្វើបច្ចុប្បន្នកម្មលិខិតបទដ្ឋានគតិយុត្ត តាមការចាំបាច់
- កំណត់សមត្ថកិច្ចស្ថាប័ន និងពង្រឹងយន្តការស្ថាប័ននៅតាមដំណាក់កាលនីមួយៗ នៃវដ្តគម្រោង
- ដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំរួមស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់ការសិក្សាសមិទ្ធិលទ្ធភាពនិងរៀបចំគម្រោង
- បន្តរៀបចំ និងពង្រឹងប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងការធ្វើនិម្មាបនកម្មនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ
- ពិនិត្យឡើងវិញលើការរៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុតាមប្រភពហិរញ្ញប្បទាននីមួយៗឱ្យមានប្រសិទ្ធភាព
- ពិនិត្យឡើងវិញលើការរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីស្តង់ដាប្រតិបត្តិនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដោយរួមបញ្ចូលបម្រែបម្រួលអាកាសធាតុ។

ការឈានទៅបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ នឹងធ្វើឱ្យមានការប្រែប្រួលសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមួយចំនួន, ផ្លាស់ប្តូររបៀបរបបបំពេញការងារ, ព្រមទាំងត្រូវការបំពេញលក្ខខណ្ឌជាច្រើនថែមទៀត ដើម្បីឱ្យសំណើគម្រោងវិនិយោគសាធារណៈមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលចាំបាច់ទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធ ជាពិសេស ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវតែបុរេសកម្ម, សកម្ម, អន្តរសកម្ម និងម៉ឺងម៉ាត់ជាងមុន ដើម្បីមិនត្រឹមតែធានាថា គ្មានការរាំងស្ទះដល់ចលនាការអភិវឌ្ឍប្រទេសដោយសារតែការជាប់គាំងនៃគម្រោងវិនិយោគសាធារណៈនៅដំណាក់កាលណាមួយនោះទេ, តែថែមទាំងជួយលើកកម្ពស់ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការវិនិយោគសាធារណៈឱ្យកាន់តែប្រសើរជាងមុនទៀតផង។ ក្នុងស្មារតីនេះ, អភិក្រមនៃការអនុវត្ត ត្រូវតែធ្វើដោយប្រយ័ត្នប្រយែង, សន្សឹមៗ, ឈរលើគោលការណ៍ប្រាកដនិយម, ទន់ភ្លន់, និង «**រៀនផង-ធ្វើផង**»។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ និងវិធានការជាយុទ្ធសាស្ត្ររយៈពេលមធ្យម ដូចខាងក្រោម៖

## ៥.១. វិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ (២០២៥-២០២៦)

ផ្អែកតាមនិន្នាការ និងការអនុវត្តជាសកល ព្រមទាំងបរិការណ៍ជាក់ស្តែងកម្ពុជា ដូចបានវិភាគខាងលើ រាជ-រដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខមួយចំនួន ដូចខាងក្រោម៖

១)ពិនិត្យឡើងវិញ ឬ ធ្វើបច្ចុប្បន្នកម្ម និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈជាអនុក្រឹត្យគោល

២) អនុម័តគោលការណ៍ណែនាំរួមស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់ការសិក្សាសមិទ្ធិលទ្ធភាពនិងរៀបចំ

គម្រោង (Overall PDF Guidelines) និងការពិនិត្យឡើងវិញ និងរៀបចំនូវគោលការណ៍ណែនាំស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់ការសិក្សាសមិទ្ធិលទ្ធភាពនិងរៀបចំគម្រោង សម្រាប់ទ្វារបាលនីមួយៗ (PDF for Each Window) តាមការចាំបាច់។

៣) លេខាធិការដ្ឋាននៃគណៈកម្មការវិនិយោគសាធារណៈ ត្រូវរៀបចំកសាងប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ( PIM database/ PIM system) ដោយបញ្ចូលពីគ្រប់ប្រភពហិរញ្ញប្បទាន។

៤) រៀបចំបញ្ចប់នីតិវិធី និងរំហូរការងារនៃគណៈកម្មការវិនិយោគសាធារណៈ។

៥) រៀបចំរបាយការណ៍សិក្សាស្តីពីការរៀបចំនិម្មាបនកម្មនៃប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ( PIM architecture) ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៦) បញ្ចប់គោលការណ៍ណែនាំសម្រាប់រៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល។

៧) ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ( PIP database) ដោយគិតគូរការប្រែប្រួលអាកាសធាតុ។

៨) បន្តរៀបចំ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ។

៩) បន្តពង្រឹងគុណភាព, ប្រសិទ្ធភាពអនុវត្ត និងភាពផ្សារភ្ជាប់ផែនការវិនិយោគ ជាមួយនឹងថវិកានីយកម្មការវិនិយោគៈ

- ពង្រឹងគុណភាពនៃការធ្វើអាទិភាវូបនីយកម្មការវិនិយោគសាធារណៈ តាមរយៈការដាក់ឱ្យអនុវត្ត «**គោល-ការណ៍ណែនាំសម្រាប់រៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល**»
- ពង្រឹងការធ្វើសមាហរណកម្មកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយនឹងតម្រឹមជាមួយផែនការវិនិយោគសាធារណៈរបស់ជាតិ។

១០) បន្តធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើការតម្រឹមផែនការ/កម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងផែនការ/កម្មវិធីរបស់រដ្ឋបាលថ្នាក់ជាតិ។

១១) បន្តធ្វើសមាហរណកម្មកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាមូលដ្ឋានរៀបចំផែនការយុទ្ធសាស្ត្របីឆ្នាំរំកិល (BSP) របស់រដ្ឋបាលរាជធានី ខេត្ត។

១២) រៀបចំយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ផ្លូវលំ និងប្រព័ន្ធធារាសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីដាក់ឱ្យអនុវត្ត។

១៣) រៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យារួម សម្រាប់គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងធារាសាស្ត្រ។

១៤) ជំរុញ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំគោលការណ៍ណែនាំ និងបទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធ។

១៥) ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យគម្រោង និងបន្តពង្រឹងយន្តការត្រួតពិនិត្យគម្រោងឱ្យមានប្រសិទ្ធភាព។

១៦) រៀបចំឱ្យមានយន្តការមួយច្បាស់លាស់នៅក្នុងដំណាក់កាលនៃការធ្វើថវិកានីយកម្មសម្រាប់គម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រាល់ការអនុម័តគម្រោងវិនិយោគសាធារណៈ ត្រូវតែធានាថាជាគម្រោងដែលមាននៅក្នុងបញ្ជីគម្រោងអាទិភាព។

១៧) គិតគូររៀបចំឱ្យមានថវិកាចំណាយប្រតិបត្តិការ និងថែទាំ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៥.២. វិធានការជាយុទ្ធសាស្ត្ររយៈពេលមធ្យម (២០២៧-២០២៨)

ឈរលើមូលដ្ឋាននៃការអនុវត្តវិធានការជាយុទ្ធសាស្ត្របន្ទាន់ចំពោះមុខ បន្ទាប់ពីការធ្វើបច្ចុប្បន្នកម្មអនុក្រឹត្យស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ត្រូវបានអនុម័ត, ក្នុងរយៈពេលមធ្យមរាជរដ្ឋាភិបាលនឹង៖

១) ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មលិខិតបទដ្ឋានគតិយុត្តសម្រាប់បន្តពង្រឹងប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និងចីរភាព នៃការអនុវត្តគម្រោងវិនិយោគសាធារណៈ។

២) សិក្សាស្រាវជ្រាវ និងពិនិត្យឡើងវិញក្នុងការដំឡើង «**អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ**» ទៅជា «**ច្បាប់ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ**»។

៣) ធ្វើបច្ចុប្បន្នកម្ម និងទំនើបកម្មប្រព័ន្ធទិន្នន័យគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ។

៤) រៀបចំគោលនយោបាយ ឬ យុទ្ធសាស្ត្រពាក់ព័ន្ធនឹងការរៀបចំផែនការវិនិយោគសាធារណៈ (Public Investment Planning)។

៥) ពិនិត្យឡើងវិញ ឬ ធ្វើបច្ចុប្បន្នកម្មនីតិវិធីស្តង់ដាប្រតិបត្តិនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ (SOPs) ពាក់ព័ន្ធតាមការចាំបាច់ ដោយរួមបញ្ចូលបម្រែបម្រួលអាកាសធាតុ និងលក្ខខណ្ឌតម្រូវការចាំបាច់នានា។

៦) ពិនិត្យឡើងវិញ ឬ ធ្វើបច្ចុប្បន្នកម្មប្រកាសស្តីពីគណៈកម្មការវិនិយោគសាធារណៈ ក្នុងករណីចាំបាច់។

# ជំពូកទី៦
# ការត្រួតពិនិត្យ តាមដាន
# និងវាយតម្លៃ

# ជំពូកទី៦
# ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលការអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រ ដូចខាងក្រោម៖

**ប្រព័ន្ធរបាយការណ៍៖** ផែនការសកម្មភាពដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរួម និងផែនការសកម្មភាពលម្អិតនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (CAP, GDAP, MAP, CPAP) ដែលជាកម្មវត្ថុនៃការរៀបចំអនុវត្តរបស់អគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ក្រោមចំណុះ **ក.ស.ហ.វ.**, ក្រសួង ស្ថាប័នពាក់ព័ន្ធ, និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ, អគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ក្រោមចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ស្តីពីការរៀបចំ និងការអនុវត្តផែនការសកម្មភាព សម្រាប់អនុវត្តវិធានការជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ជូនអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដើម្បីបូកសរុប និងរាយការណ៍ជូនគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**គ.ក.ហ.**) និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**)។

**យន្តការដោះស្រាយបញ្ហាប្រឈម៖** គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានភារកិច្ចពិនិត្យ និងសម្រេចដាក់ចេញនូវវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានកើតឡើងក្នុងពេលអនុវត្តវិធានការជាយុទ្ធសាស្ត្រ។ ក្នុងករណីមានវិវាទយិតភាពត្រូវស្នើសុំការសម្រេចពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាយករដ្ឋមន្ត្រី។

**យន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាពជាប្រចាំ៖** អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) មានភារកិច្ចតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃ លើវឌ្ឍនភាពនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រ និងវិធានការដោះស្រាយបញ្ហាប្រឈម ដែលបានដាក់ចេញ និងរាយការណ៍ជូនគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

# ជំពូកទី៧
# សេចក្តីសន្និដ្ឋាន

# ជំពូកទី៧
# សេចក្តីសន្និដ្ឋាន

ជារួម, ទន្ទឹមនឹងវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងការអនុវត្តការដ្ឋានកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ នាពេលកន្លងមក រហូតមកដល់ពេលនេះ បញ្ហាប្រឈមដែលនៅសេសសល់ក៏នឹងត្រូវបន្តគិតគូរដោះស្រាយបន្ថែមទៀតឱ្យបានសកម្មខ្លាំងក្លាផងដែរ។ ដោយក្នុងនោះ, រាជរដ្ឋាភិបាលយល់ឃើញថា ការបន្តរៀបចំ និងអនុវត្តឱ្យបានពេញលេញប្រកបដោយប្រសិទ្ធភាព និងភាពប្រទាក់ក្រឡាគ្នានូវប្រព័ន្ធរួមមួយសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ គឺជាមូលដ្ឋានគ្រឹះសំខាន់ក្នុងចលនការនៃការបន្តជំរុញគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្នុងល្បឿនលឿន ជាពិសេសការឆ្លើយតបឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាជន។

ជាការពិត, យុទ្ធសាស្ត្របច្ចុប្បន្នកម្មនេះ គឺជាផែនទីបង្ហាញផ្លូវ សម្រាប់អភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជាសេចក្តីសម្រេចជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើការកំណត់អំពីវិស័យអាទិភាព សម្រាប់គម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន។ ដូច្នេះ, ដើម្បីឈានដល់ការអនុវត្តពេញលេញនូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ នៅមុនដំណាច់ឆ្នាំ២០២៨ រាជរដ្ឋាភិបាលត្រូវបន្តខិតខំពិនិត្យរៀបចំ កែសម្រួល ឬ ធ្វើបច្ចុប្បន្នកម្មលិខិតបទដ្ឋានគតិយុត្ត, នីតិវិធីស្តង់ដាប្រតិបត្តិ, ពង្រឹងយន្តការស្ថាប័នទាំងអន្តរក្រសួង និងយន្តការសម្របសម្រួលផ្ទៃក្នុង, បង្កើតនិងពង្រឹងយន្តការគាំទ្រហិរញ្ញវត្ថុ, និងអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សតាមការចាំបាច់ ដូចដែលបានណែនាំ និងដាក់ចេញក្នុងវិធានការជាយុទ្ធសាស្ត្រនៃឯកសារយុទ្ធសាស្ត្រនេះ។

រាជរដ្ឋាភិបាល ចាត់ទុកយុទ្ធសាស្ត្រនេះ ជា «**ឯកសាររស់**» ដែលអាចនឹងត្រូវបានកែសម្រួលជាយថាហេតុដើម្បីជានាសង្គតិភាពចំពោះវឌ្ឍនភាពនៃបរិការណ៍ជាក់ស្តែងនៅកម្ពុជា នាពេលខាងមុខ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថា ការអនុវត្តដោយជោគជ័យនូវ «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨**» នឹងរួមចំណែក៖ ១)បង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ និង២)ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈការពង្រឹងសមត្ថភាពក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ លើភាពអាចប៉ាន់ប្រមាណបាននៃកាតព្វកិច្ចបំណុលជាយថាហេតុរបស់រដ្ឋ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកជាស្ថាប័ននាំមុខក្នុងការសម្របសម្រួលលើការអនុវត្ត «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្ន-កម្ម ឆ្នាំ២០២៥-២០២៨**» ដោយត្រូវមានការចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ៕

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១
# សន្ធានុក្រម

# ឧបសម្ព័ន្ធទី១
# សទ្ទានុក្រម

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ១ | Project Adjustment | ការកែសម្រួលគម្រោង | សំដៅដល់ដំណើរការនៃការកែសម្រួលផ្នែកណាមួយនៃគម្រោង ដែលបានអនុម័តរួចហើយ ជាអាទិ៍៖ ការកែសម្រួលតម្លៃ, វិសាលភាព, សកម្មភាព ឬ រយៈពេលនៃការអនុវត្តគម្រោងជាដើម។ |
| ២ | Project Appraisal | ការវាយតម្លៃសំណើគម្រោង | សំដៅដល់ដំណើរការវាយតម្លៃលើទិដ្ឋភាពសំខាន់ៗនៃសំណើគម្រោង ជាអាទិ៍៖ បច្ចេកទេស, តម្លៃ, ហានិភ័យ, ផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គម, ហេតុប៉ះពាល់បរិស្ថាននិងសង្គម, និងថវិកាជាដើម។ |
| ៣ | Feasibility Study | ការសិក្សាសមិទ្ធិលទ្ធភាព | សំដៅដល់ការសិក្សាស៊ីជម្រៅលើសំណើគម្រោង ដោយរួមបញ្ចូលការវិភាគលើទិដ្ឋភាពពាក់ព័ន្ធ រួមមាន៖ បច្ចេកទេស, តម្លៃ, ហានិភ័យ, សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ច្បាប់, ហេតុប៉ះពាល់បរិស្ថាននិងសង្គម, ភាពអាចទ្រទ្រង់បាននៃថវិកា ព្រមទាំងយន្តការនិងសមត្ថភាពស្ថាប័ន សម្រាប់គ្រប់គ្រងនិងតាមដានការអនុវត្តគម្រោង ដោយត្រូវគោរពតាមគោលការណ៍ណែនាំលម្អិត និងនីតិវិធីរៀបចំ និងគ្រប់គ្រងប្រតិបត្តិការជាធរមាន។ |
| ៤ | Turnkey Contract | កិច្ចសន្យាប្រគល់សោរដល់ដៃ | សំដៅដល់កិច្ចសន្យា ដែលសម្បទានិកទទួលបានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ តាមរយៈការធ្វើឯកជនភាវូបនីយកម្ម ដើម្បីទទួលខុសត្រូវក្នុងការចាត់ចែង, រៀបចំ, និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឱ្យបានរួចរាល់សម្រាប់ប្រតិបត្តិការ មុននឹងប្រគល់ជូនភាគីរាជរដ្ឋាភិបាល។ |
| ៥ | Gatekeeping | ទ្វារបាលកិច្ច | សំដៅដល់មុខងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង ការធ្វើអាទិភាវូបនីយកម្ម ការជ្រើសរើស និងថវិកានីយកម្ម ព្រមទាំងការតាមដាននិងត្រួតពិនិត្យលើការអនុវត្តគម្រោង។ |
| ៦ | Public Private Partnership (PPP) | ភាពជាដៃគូរវាងរដ្ឋនិងឯកជន | សំដៅដល់ការព្រមព្រៀងគ្នារវាងភាគីរដ្ឋ និងដៃគូឯកជន ដើម្បីធ្វើការងារស្តារ ជួសជុល ពង្រីក សាងសង់ |

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| | | | ប្រតិបត្តិការ និង/ឬ ថែទាំលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬទ្រព្យសម្បត្តិគម្រោង ឬដើម្បីផ្តល់សេវាសាធារណៈក្នុងអំឡុងពេលកំណត់ណាមួយ។ កិច្ចព្រមព្រៀងនេះ ដៃគូឯកជនត្រូវធ្វើការវិនិយោគ ទទួលបន្ទុកហានិភ័យចំណែក និងទទួលអត្ថប្រយោជន៍ផ្អែកលើសមិទ្ធកម្ម តាម ខ និងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន។ |
| ៧ | Project Concept Note | ឯកសារទស្សនាទានគម្រោង | សំដៅដល់ឯកសារទស្សនាទានបឋម ដែលបញ្ជាក់អំពីសនិទានកម្ម គោលដៅនៃគម្រោង តម្រូវការនិងអាទិភាពនៃគម្រោង ការផ្សារភ្ជាប់ទៅនឹងគោល-នយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយតាមវិស័យ។ |
| ៨ | Optimization | បរមូភាវូបនីយកម្ម | សំដៅដល់ដំណើការធ្វើឱ្យអ្វីមួយមានប្រសិទ្ធភាពខ្ពស់បំផុត ឬ សម្រេចបានលទ្ធផលល្អបំផុត ដោយប្រើ-ប្រាស់ធនធានតិចបំផុត។ |
| ៩ | Retroactive Financing | ហិរញ្ញប្បទានប្រតិសកម្ម | សំដៅដល់ការផ្តល់ហិរញ្ញប្បទាន ឬ ថវិកាសម្រាប់ការចំណាយដែលបានកើតមានរួចហើយ មុនពេលកិច្ចព្រមព្រៀងគម្រោងហិរញ្ញប្បទានដោយដៃគូ-អភិវឌ្ឍន៍ត្រូវបានចូលជាធរមាន ហើយត្រូវមានការឯកភាពជាមុនពីដៃគូអភិវឌ្ឍន៍ និងមានចែងក្នុងកិច្ច-ព្រមព្រៀងហិរញ្ញប្បទាន។ |
| ១០ | Representative of State | ភារីរដ្ឋ | សំដៅដល់បុគ្គល ឬ អង្គភាពដែលត្រូវបានផ្តល់អំណាចឱ្យតំណាងរដ្ឋក្នុងកិច្ចសន្យា ឬ ដំណើរការចុះកិច្ចព្រមព្រៀងតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ |
| ១១ | Logistics | ភស្តុភារកម្ម | គឺជាផ្នែកនៃការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ដែលដោះស្រាយជាមួយនឹងរំហូរទៅមុខ និងបញ្ច្រាសប្រកបដោយប្រសិទ្ធភាពនៃទំនិញ សេវាកម្ម និងព័ត៌មានពាក់ព័ន្ធពីចំណុចដើមរហូតដល់ចំណុចនៃការប្រើប្រាស់ស្របតាមតម្រូវការរបស់អតិថិជន។ |
| ១២ | Secondary Market | ទីផ្សារបន្ទាប់ | សំដៅដល់ទីផ្សារជួញដូរមូលបត្ររដ្ឋ ដែលបានបោះ-ផ្សាយលក់រួចហើយ។ |
| ១៣ | Government Securities | មូលបត្ររដ្ឋ | សំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលបញ្ជាក់ពីការទទួលស្គាល់ពីបំណុល |

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| | | | ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល នៅក្រោមច្បាប់ស្តីពីមូលបត្ររដ្ឋ រួមមាន៖<br>ក- បណ្ណរតនាគារ ដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ។<br>ខ- សញ្ញាបណ្ណរតនាគារដែលមានឥណប្រតិទាន ចាប់ពីមួយឆ្នាំឡើងទៅ។<br>គ- មូលបត្ររដ្ឋផ្សេងៗទៀត។<br>មូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលនូវមូលបត្រដែលបោះផ្សាយដោយសហគ្រាសសាធារណៈ ឬ ការសុំខ្ចីផ្សេងៗរបស់រាជរដ្ឋាភិបាល ដែលមិនស្ថិតក្រោមវិសាលភាពនៃច្បាប់ស្តីពីមូលបត្ររដ្ឋទេ។ |
| ១៤ | Capital Expenditure Credit | ឥណទានចំណាយមូលធន | គឺជាឥណទានវិនិយោគដែលចែកចេញជាឥណទានភ្ជាប់សន្យា និងឥណទានទូទាត់។ |

# ឧបសម្ព័ន្ធទី២
# ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្ត
# យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធ
# គ្រប់គ្រងការវិនិយោគសាធារណៈ
# បច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨

# ឧបសម្ព័ន្ធទី២ ផែនការសកម្មភាពលម្អិត
# សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| ស.គ.១. សិក្សា និងពិនិត្យឡើងវិញលើក្របខ័ណ្ឌគតិយុត្ត | | | | | | | | | | | | | | | | | | |
| ច.ស.១. ពិនិត្យ និងតាមដានការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ | | | | | | | | | | | | | | | | | | |
| **ស.ក.១.** ពិនិត្យនិងតាមដានការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ | អ.គ.ហ. អង្គភាពពាក់ព័ន្ធនៃ ក.សហវ. | របាយការណ៍ពិនិត្យ និងតាមដានការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ | | | | | | | | | | | | | | | | |
| **ស.ស.១.** របាយការណ៍ស្តីពីការពិនិត្យនិងតាមដានការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ | | | | | | X | | | | X | | | | X | | | | X |
| ច.ស.២. រៀបចំ និងកែលម្អក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ ដើម្បីពង្រឹងការអនុវត្ត | | | | | | | | | | | | | | | | | | |

| **វិធាន/ចង្កោមសកម្មភាព/ សកម្មភាព** | **អង្គភាព** | **សូចនាករ សមិទ្ធកម្មគន្លឹះ** | **គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ** | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | **ឆ្នាំ២០២៥** | | | | **ឆ្នាំ២០២៦** | | | | **ឆ្នាំ២០២៧** | | | | **ឆ្នាំ២០២៨** | | | |
| | | | **ត.១** | **ត.២** | **ត.៣** | **ត.៤** | **ត.១** | **ត.២** | **ត.៣** | **ត.៤** | **ត.១** | **ត.២** | **ត.៣** | **ត.៤** | **ត.១** | **ត.២** | **ត.៣** | **ត.៤** |
| **ស.ក.១.** សិក្សា និងរៀបចំអនុក្រឹត្យស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព | អ.ល.សា | អនុក្រឹត្យស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព ត្រូវបានរៀបចំ និងអនុម័ត | | | | | | | | | | | | | | | | |
| **ស.ស.១.** សិក្សាស្រាវជ្រាវលើការរៀបចំអនុក្រឹត្យស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព | អ.ល.សា | សិក្សាស្រាវជ្រាវលើការរៀបចំអនុក្រឹត្យស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយចីរ-ភាព | | | | | X | X | X | | | | | | | | | |
| **ស.ស.២.** រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព | អ.ល.សា | ផែនទីចង្អុលផ្លូវសម្រាប់ការរៀបចំការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព ត្រូវបានអនុម័ត | | | | | | | | X | X | | | | | | | |
| **ស.ស.៣.** ពិគ្រោះយោបល់លើសេចក្តី-ព្រាងអនុក្រឹត្យស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព | អ.ល.សា | សេចក្តីព្រាងអនុ-ក្រឹត្យស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយចីរ- | | | | | | | | | | X | X | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| | | ភាព ត្រូវបានដាក់ប្រជុំពិភាក្សា និងពិគ្រោះយោបល់ | | | | | | | | | | | | | | | | |
| **ស.ស.៤.** បញ្ជូនសេចក្តីព្រាងចុងក្រោយអនុក្រឹត្យស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព ទៅទីស្តីការគណៈរដ្ឋមន្ត្រី | អ.ល.សា ក.ស.ហ.វ. ក្រសួងបរិស្ថាន ទីស្តីការគណៈរដ្ឋមន្ត្រី | សេចក្តីព្រាងចុងក្រោយអនុក្រឹត្យស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព ត្រូវបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី | | | | | | | | | | | | X | | | | |
| **ស.ក.២.** រៀបចំកែសម្រួលប្រកាសស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្ម | អ.ល.សា ក.ស.ហ.វ. | ប្រកាសស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្ម ត្រូវបានកែសម្រួលថ្មី និងចុះហត្ថលេខាដាក់ឱ្យអនុវត្ត | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំសេចក្តីព្រាងការកែសម្រួលថ្មីប្រកាសស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្ម | អ.ល.សា | | X | X | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.២.** ពិគ្រោះយោបល់លើសេចក្តីព្រាងការកែសម្រួលថ្មីប្រកាសស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្ម | អ.ល.សា អគ្គ.ពាក់ព័ន្ធ នៃ ក.ស.ហ.វ. | សេចក្តីព្រាងការកែសម្រួលថ្មីប្រកាសស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្ម ត្រូវបានដាក់ប្រជុំពិភាក្សា | | X | X | | | | | | | | | | | | | |
| **ស.ស.៣.** អនុម័តសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្ម (ថ្មី) | អ.ល.សា ក.ស.ហ.វ. | ប្រកាសស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្ម (ថ្មី) ត្រូវបានចុះហត្ថលេខាដាក់ឱ្យអនុវត្ត | | | | X | | | | | | | | | | | | |
| **ច.ស.៣. សិក្សា រៀបចំ ឬ កែលម្អលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ គោលការណ៍ណែនាំ ឬ នីតិវិធីស្តង់ដាប្រតិបត្តិលម្អិត និងការពង្រឹងយន្តការការងាររៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** សិក្សា និងកែសម្រួលអនុក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួល | ក្រសួងមហាផ្ទៃ គ.ជ.អ.ប ក.ស.ហ.វ. អ.ហ.ក | អនុក្រឹត្យ ត្រូវបានកែសម្រួល | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| បច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈ-កម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក | | | | | | | | | | | | | | | | | | |
| **ស.ស.១.** សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈ-កម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាស្រុក | | | | | | | | | X | X | | | | | | | | |
| **ស.ស.២.** អនុក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈ-កម្មាធិការសម្របសម្រួល បច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សា-ក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាស្រុក | | | | | | | | | | | X | X | | | | | | |
| **ស.ក.២.** សិក្សា និងកែសម្រួលអនុ-ក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការ | ក្រសួងមហាផ្ទៃ គ.ជ.អ.ប | អនុក្រឹត្យ ត្រូវបានកែសម្រួល | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| សម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ | ក.ស.ហវ. អ.ហ.ក | | | | | | | | | | | | | | | | | |
| **ស.ស.១.** សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ | | | | | | | | | X | X | | | | | | | | |
| **ស.ស.២.** អនុក្រឹត្យស្តីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈ-កម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈ-កម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ | | | | | | | | | | | X | X | | | | | | |
| **ស.ក.៣.** រៀបចំសារាចរណែនាំស្តីពីការពង្រឹងគុណភាពការផ្សារភ្ជាប់រវាងកម្មវិធីវិនិយោគ ជាមួយនឹងថវិកានីយ- | អ.ហ.ក. | សារាចរណែនាំស្តីពីការពង្រឹងគុណភាពការផ្សារភ្ជាប់រវាងកម្មវិធី | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| កម្មការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | វិនិយោគជាមួយនឹងថវិកានីយកម្មការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | | | | | | | | | | | | | | | | |
| **ស.ស.១.** សេចក្តីព្រាងសារាចរណែនាំស្តីពីការពង្រឹងគុណភាពការផ្សារភ្ជាប់រវាងកម្មវិធីវិនិយោគ ជាមួយនឹងថវិកានីយកម្មការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | X | | | | | | | | | | | | |
| **ស.ស.២.** សារាចរណែនាំស្តីពីការពង្រឹងគុណភាពការផ្សារភ្ជាប់រវាងកម្មវិធីវិនិយោគជាមួយនឹងថវិកានីយ-កម្មការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | | X | X | | | | | | | | | | |
| **ស.ក.៤.** រៀបចំសារាចរណែនាំស្តីពីការរៀបចំគម្រោងថវិកាសម្រាប់ចំណាយការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | អ.ហ.ក. | សារាចរណែនាំស្តីពីការរៀបចំគម្រោងថវិកាសម្រាប់ចំណាយការជួសជុល និង | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| | | ថៃទាំហេដ្ឋារចនាសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | | | | | | | | | | | | | | | | |
| **ស.ស.១.** សេចក្តីព្រាងសារាចរណែនាំស្តីពីការរៀបចំគម្រោងថវិកាសម្រាប់ចំណាយការជួសជុល និងថៃទាំហេដ្ឋារចនាសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | | | | | | X | X | | | | | | |
| **ស.ស.២.** សារាចរណែនាំស្តីពីការរៀបចំគម្រោងថវិកាសម្រាប់ចំណាយការជួសជុល និងថៃទាំហេដ្ឋារចនា-សម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | | | | | | | | X | X | | | | |
| **ស.ក.៥.** រៀបចំច្បាប់ស្តីពី «ការគ្រប់គ្រងសហគ្រាសសាធារណៈ និងភាគហ៊ុនរបស់រដ្ឋ» | អ.ទ.ច. ក.ស.ហ.វ. | ច្បាប់ស្តីពី «ការគ្រប់គ្រងសហ-គ្រាសសាធារណៈ និងភាគហ៊ុនរបស់រដ្ឋ» | | | | | | | | | | | | | | | | |
| **ស.ស.១.** សេចក្តីព្រាងបឋមដាក់ឆ្លងថ្នាក់ដឹកនាំ ក.ស.ហ.វ. | | | | | | | X | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.២.** សេចក្តីព្រាងបឋមដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | | | | | | X | | | | | | | | | | |
| **ស.ស.៣.** សេចក្តីព្រាងដាក់ឆ្លងទីស្តី-ការគណៈរដ្ឋមន្ត្រី និងដាក់ឆ្លងអង្គ-នីតិបញ្ញត្តិ | | | | | | | | | X | X | | | | | | | | |
| **ស.ក.៦.** រៀបចំយុទ្ធសាស្ត្រស្តីពី «ការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈឆ្នាំ២០២៥-២០៣០» | អ.ទ.ច. ក.ស.ហ.វ. | យុទ្ធសាស្ត្រស្តីពី «ការកែទម្រង់ការគ្រប់គ្រងសហ-គ្រាសសាធារណៈ ឆ្នាំ២០២៥-២០៣០» | | | | | | | | | | | | | | | | |
| **ស.ស.១.** យុទ្ធសាស្ត្រស្តីពី «ការកែទម្រង់ការគ្រប់គ្រងសហគ្រាសសា-ធារណៈ ឆ្នាំ២០២៥-២០៣០» ត្រូវបានដាក់ឱ្យអនុវត្ត | | | | | | X | | | | | | | | | | | | |
| **ស.ក.៧.** រៀបចំឯកសារគាំទ្រការអនុវត្តច្បាប់ (អនុក្រឹត្យចំនួន១) | អ.ទ.ច. ក.ស.ហ.វ. | អនុក្រឹត្យចំនួន១ត្រូវបានរៀបចំ | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំអនុក្រឹត្យកម្រិត អ.ទ.ច. | | | | | | | | | | | X | X | X | X | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.២.** សេចក្តីព្រាងអនុក្រឹត្យ ត្រូវបានដាក់ឆ្លងថ្នាក់ដឹកនាំ នៃ ក.ស.ហ.វ. | | | | | | | | | | | | | X | | | | | |
| **ស.ស.៣.** សេចក្តីព្រាងអនុក្រឹត្យ ត្រូវបានដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអនុម័ត | | | | | | | | | | | | | | X | | | | |
| **ស.ក.៨.** រៀបចំការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ | អ.គ.ហ. | ការធ្វើបច្ចុប្បន្ន-កម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានអនុម័ត | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំសេចក្តីព្រាងបច្ចុប្បន្ន-កម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសា-ធារណៈ | | | X | | | | | | | | | | | | | | | |
| **ស.ស.២.** សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានរៀបចំ | | | | X | X | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.៣.** បច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានអនុម័ត | | | | | | X | | | | | | | | | | | | |
| **ស.ស.៤.** សិក្ខាសាលាផ្សព្វផ្សាយស្តីពីការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានរៀបចំ | | | | | | | | X | | | | | | | | | | |
| **ស.ក.៩.** អនុក្រឹត្យស្តីពីស្លាកសញ្ញាបរិស្ថានបៃតង | ក្រសួងបរិស្ថាន | អនុក្រឹត្យត្រូវបានអនុម័ត | | | | | | | | | | | | | | | | |
| **ស.ស.១.** បញ្ចប់សេចក្តីព្រាង និងពិនិត្យពិភាក្សាផ្ទៃក្នុងនៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង | | | X | | | | | | | | | | | | | | | |
| **ស.ស.២.** ដាក់ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រពិនិត្យសម្រេច | | | | X | | | | | | | | | | | | | | |
| **ស.ស.៣.** ពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋាននានាចំណុះក្រសួងបរិស្ថាន | | | | | X | X | | | | | | | | | | | | |
| **ស.ស.៤.** ពិគ្រោះយោបល់ជាមួយអន្តរក្រសួង និងស្ថាប័នពាក់ព័ន្ធ | | | | | | | X | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.៥.** ដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច | | | | | | | | X | X | | | | | | | | | |
| **ស.ក.១០.** ផែនទីបង្ហាញផ្លូវស្តីពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព | ក្រសួងបរិស្ថាន | ផែនទីបង្ហាញផ្លូវត្រូវបានអនុម័ត | | | | | | | | | | | | | | | | |
| **ស.ស.១.** បញ្ចប់សេចក្តីព្រាង និងពិនិត្យពិភាក្សាផ្ទៃក្នុងនៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង | | | | X | | | | | | | | | | | | | | |
| **ស.ស.២.** ពិភាក្សាជាមួយក្រុមការងារអ្នកច្បាប់ក្រសួងបរិស្ថាន និងបញ្ចប់ការត្រួតពិនិត្យអក្ខរាវិរុទ្ធ ទាំងភាសាខ្មែរ និងអង់គ្លេស | | | | | | X | | | | | | | | | | | | |
| **ស.ស.៣.** ពិភាក្សាជាមួយនាយកដ្ឋានលទ្ធកម្ម និងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | | | | | X | | | | | | | | | | | |
| **ស.ស.៤.** ដាក់ជូនទីស្តីការក្រសួងបរិស្ថាន ដើម្បីស្នើសុំអនុម័តពីថ្នាក់ដឹកនាំក្រសួង | | | | | | | | X | | | | | | | | | | |
| **ស.ស.៥.** ដាក់ជូនទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំអនុម័តពីថ្នាក់ដឹកនាំក្រសួង | | | | | | | | | X | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ក.១១.** ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មអគារបៃតង | ក្រសួងបរិស្ថាន | ប្រកាសត្រូវបានអនុម័ត | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំជាសេចក្តីព្រាង (ប្រជុំឆ្លងផ្ទៃក្នុងក្រសួង អន្តរក្រសួង ក្រុម-ការងារបច្ចេកទេស និងប្រជុំជាមួយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ) | | | X | X | | | | | | | | | | | | | | |
| **ស.ស.២.** រៀបចំជាសេចក្តីព្រាងដើម្បីប្រជុំឆ្លងកម្រិតបច្ចេកទេស និងថ្នាក់ដឹកនាំជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | | | | | X | X | X | | | | | | | | | | | |
| **ស.ស.៣.** ដាក់ជូនថ្នាក់ដឹកនាំក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីសុំការអនុម័ត | | | | | | | | X | | | | | | | | | | |
| **ស.ក.១២.** ប្រកាសស្តីពីការបង្កើតគណៈកម្មការជាតិអគារបៃតង | ក្រសួងបរិស្ថាន | ប្រកាសត្រូវបានអនុម័ត | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំជាសេចក្តីព្រាង (ប្រជុំឆ្លងផ្ទៃក្នុងក្រសួង អន្តរក្រសួង ក្រុម-ការងារបច្ចេកទេស និងប្រជុំជាមួយ | | | X | X | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ) | | | | | | | | | | | | | | | | | | |
| **ស.ស.២.** រៀបចំជាសេចក្តីព្រាងដើម្បីប្រជុំឆ្លងកម្រិតបច្ចេកទេស និងថ្នាក់ដឹកនាំជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | | | | X | X | X | | | | | | | | | | | |
| **ស.ស.៣.** ដាក់ជូនថ្នាក់ដឹកនាំក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីសុំការអនុម័ត | | | | | | | | X | | | | | | | | | | |
| **ស.ក.១៣.** បង្កើតគណៈកម្មការរៀបចំគោលនយោបាយស្តីពីការអភិវឌ្ឍវិស័យដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក ផ្លូវដែក និងឡជីស្ទីកនៅកម្ពុជា | ក្រសួងសាធារ-ណការ និងដឹកជញ្ជូន | ចេញសេចក្តីសម្រេច | X | | | | | | | | | | | | | | | |
| **ស.ក.១៤.** រៀបចំក្រុមការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ និងគោលនយោបាយរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន | ក្រសួងសាធារ-ណការ និងដឹកជញ្ជូន | ចេញសេចក្តីសម្រេច | X | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ស.ក.៧.** រៀបចំគោលការណ៍ណែនាំស្តីពីនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន (Financial Management Manual for PPP Projects – FMM for PPP Projects) | | | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំកិច្ចប្រជុំពិភាក្សាកម្រិតអគ្គនាយកដ្ឋាន លើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី FMM for PPP Projects | | | | | | | X | | | | | | | | | | | |
| **ស.ស.២.** រៀបចំកិច្ចប្រជុំកម្រិតបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សា | | | | | | | | X | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| ទៅលើគោលការណ៍ណែនាំស្តីពី FMM for PPP Projects | | | | | | | | | | | | | | | | | | |
| **ស.ស.៣.** ពិនិត្យ និងកែសម្រួលទៅលើខ្លឹមសារនៃគោលការណ៍ណែនាំស្តីពី FMM for PPP Projects | | | | | | | | | X | | | | | | | | | |
| **ស.ស.៤.** រៀបចំរបាយការណ៍គោរពរាយការណ៍ជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេចក្នុងការដាក់ឱ្យប្រើគោល-ការណ៍ណែនាំស្តីពី FMM for PPP Projects | | | | | | | | | | X | | | | | | | | |
| **ស.គ.៩. រៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ** | | | | | | | | | | | | | | | | | | |
| **ច.ស.១. រៀបចំ និងដាក់អនុវត្តគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** គោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ | ក្រសួងអភិវឌ្ឍន៍ជនបទ | | | | | | | | | | | | | | | | | |
| **ស.ស.១.** សិក្ខាសាលាផ្សព្វផ្សាយជាមួយអង្គភាពថ្នាក់កណ្តាល និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តទាំង ២៥ ត្រូវបានរៀបចំ | | | | | X | | | | | | | | | | | | | |
| **ស.ស.២.** សាកល្បងចុះអនុវត្តផែនការសកម្មភាពចំនួន ២៥ ខេត្តគោលដៅ | | | | | | X | X | X | | | X | | X | | | | | |
| **ច.ស.២. រៀបចំ និងដាក់អនុវត្តគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ** | | | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ក.១.** រៀបចំ និងដាក់ឱ្យអនុវត្ត គោលការណ៍ណែនាំស្តីពីការអនុវត្ត សម្រាប់កិច្ចដំណើរការ និងការថែទាំ ប្រព័ន្ធធារាសាស្ត្រ | ក្រសួង ធនធាន ទឹកនិង ឧតុ-និយម | គោលការណ៍ ណែនាំស្តីពីការ អនុវត្តសម្រាប់ កិច្ចដំណើរការ និងការថែទាំ ប្រព័ន្ធធារាសាស្ត្រ និងឧបសម្ព័ន្ធ ចំនួន ៣ ត្រូវបាន ដាក់ឱ្យអនុវត្ត | | | | | | | | | | | | | | | | |
| **ស.ស.១.** ផ្សព្វផ្សាយ និងអនុវត្តគោល-ការណ៍ណែនាំស្តីពីការអនុវត្តសម្រាប់ កិច្ចដំណើរការ និងការថែទាំប្រព័ន្ធ ធារាសាស្ត្រ និងឧបសម្ព័ន្ធចំនួន ៣ | | | | X | | X | | X | | X | | X | | X | | X | | X |
| **ស.គ.១០. រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ** | | | | | | | | | | | | | | | | | | |
| **ច.ស.១. រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈនៅតាមក្រសួង ស្ថាប័ន** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** រៀបចំប្រព័ន្ធប៉ាណូឡិកា (Dash- board) តាមដានការអនុវត្ត គម្រោងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន | ក្រសួង សាធារ-ណការ និងដឹក ជញ្ជូន | ប្រព័ន្ធប៉ាណូ-ឡិកា (Dash-board) ត្រូវបាន ដាក់ឱ្យអនុវត្ត សាកល្បង | | | | X | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ក.២.** រៀបចំប្រព័ន្ធពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មផែនការសកម្ម-ភាពអាទិភាពវិស័យសាធារណការ និងដឹកជញ្ជូន | ក្រសួងសាធារ-ណការ និងដឹកជញ្ជូន | ប្រកាសដាក់ឱ្យអនុវត្ត និងផ្សព្វ-ផ្សាយ | | | | | | | X | | | | | | | | | |
| **ស.ក.៣.** រៀបចំកម្មវិធីផ្នែកទន់ដើម្បីគ្រប់គ្រងការរៀបចំគម្រោងផែនការប្រចាំឆ្នាំ និងទិន្នន័យសំណង់សាធា-រណការ | ក្រសួងសាធារ-ណការ និងដឹកជញ្ជូន | កម្មវិធីផ្នែកទន់ដើម្បីគ្រប់គ្រងការរៀបចំគម្រោងផែនការប្រចាំឆ្នាំ និងទិន្នន័យសំណង់សាធារ-ណការ ត្រូវបានរៀបចំរួចរាល់ | | | | X | | | | | | | | | | | | |
| **ស.ក.៤.** រៀបចំកម្មវិធីផ្នែកទន់ដើម្បីគ្រប់គ្រងការរៀបចំគម្រោងផែនការប្រចាំឆ្នាំ និងទិន្នន័យសំណង់សាធា-រណការ | ក្រសួងសាធារ-ណការ និងដឹកជញ្ជូន | កម្មវិធីផ្នែកទន់ដើម្បីគ្រប់គ្រងការរៀបចំគម្រោងផែនការប្រចាំឆ្នាំ និងទិន្នន័យសំណង់សាធារ-ណការ ត្រូវបានដាក់ឱ្យប្រើប្រាស់ | | | | | | X | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ក.៥.** រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ (IAMS) | ក្រសួងធនធានទឹកនិងឧតុ-និយម | ប្រព័ន្ធគ្រប់គ្រងហេដ្ឋារចនា-សម្ព័ន្ធប្រព័ន្ធធារា-សាស្ត្រ (IAMS) ត្រូវបានដាក់ឱ្យអនុវត្ត | | | | | | | | | | | | | | | | |
| **ស.ស.១.** ការបង្កើតកម្មវិធី IAMS នឹងសម្រេចបាន ៧៥% រួមមានការពង្រឹងមុខងារលើការបញ្ចូល និងការវិភាគទិន្នន័យ។ | | | X | | | | | | | | | | | | | | | |
| **ស.ស.២.** សិក្ខាសាលាបណ្តុះបណ្តាលការប្រើប្រាស់កម្មវិធី IAMS ជាផ្លូវការជូនមន្ត្រីក្រសួង និងមន្ត្រីមន្ទីរគ្រប់រាជធានី/ខេត្ត។ | | | | X | | | | | | | | | | | | | | |
| **ស.ស.៣.** វគ្គបណ្តុះបណ្តាលកម្រិតមធ្យមសម្រាប់មន្ត្រីមន្ទីរនៃខេត្តចំនួន ១២ ដោយផ្តោតលើការប្រើប្រាស់ IAMS សម្រាប់ការធ្វើផែនការ និងកំណត់អាទិភាព O&M។ | | | | | X | | | | | | | | | | | | | |
| **ស.ស.៤.** បន្តបើកវគ្គបណ្តុះបណ្តាលកម្រិតមធ្យមសម្រាប់មន្ត្រីមន្ទីរនៃ | | | | | | X | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/សកម្មភាព | អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| ខេត្តដែលនៅសល់ចំនួន ១២ ដោយផ្តោតលើការប្រើប្រាស់ IAMS សម្រាប់ការធ្វើផែនការ និងកំណត់អាទិភាព O&M។ | | | | | | | | | | | | | | | | | | |
| **ស.ស.៥.** បើកវគ្គបណ្តុះបណ្តាលកម្រិតខ្ពស់ដល់មន្ត្រីមន្ទីរទាំង ២៥ រាជធានី/ខេត្ត (ចែកចេញជា ៣ វគ្គ) លើការវិភាគទិន្នន័យ ការសម្រេចចិត្ត និងការព្យាករណ៍។ | | | | | | | X | | | | | | | | | | | |
| **ស.ស.៦.** រៀបចំសិក្ខាសាលាបណ្តុះ-បណ្តាលពង្រឹងសមត្ថភាពលើការប្រើប្រាស់ IAMS ឱ្យបានពេញលេញនៅទូទាំងប្រទេស។ | | | | | | | | X | | | | | | | | | | |
| **ស.ស.៧.** ដាក់ឱ្យប្រើប្រាស់ផ្ទាំងប្រតិបត្តិការទិន្នន័យតាមពេលវេលាជាក់ស្តែងសម្រាប់មន្ត្រីក្រសួង និងមន្ត្រីមន្ទីរគ្រប់រាជធានី/ខេត្តអាចត្រួតពិនិត្យទិន្នន័យ និងធ្វើផែនការ។ | | | | | | | | | X | | | | | | | | | |
| **ស.ស.៨.** រៀបចំសិក្ខាសាលាសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីពង្រឹងសមត្ថភាពលើការប្រើប្រាស់កម្មវិធី | | | | | | | | | | X | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/សកម្មភាព | អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| IAMS កម្រិតខ្ពស់ ដោយរួមមានការធ្វើបច្ចុប្បន្នភាពទិន្នន័យដោយស្វ័យ-ប្រវត្តិ និងការវិភាគការព្យាករណ៍។ | | | | | | | | | | | | | | | | | | |
| **ស.ស.៩.** ដាក់ឱ្យប្រើប្រាស់មុខងារព្យាករណ៍ការថែទាំដោយប្រើប្រាស់ IAMS។ | | | | | | | | | | | X | | | | | | | |
| **ស.ស.១០.** ចេញផ្សាយរបាយការណ៍គ្រប់គ្រងថវិការយៈពេលបីឆ្នាំដំបូងដោយប្រើប្រាស់ទិន្នន័យ IAMS ផ្ទាល់ និងបង្ហាញពីសារសំខាន់ទៅលើការធ្វើផែនការប្រព័ន្ធជាវាសាស្ត្រថ្នាក់ជាតិ។ | | | | | | | | | | | | X | | | | | | |
| **ច.ស.២. រៀបចំឯកសារណែនាំ (User Guide) ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** រៀបចំឯកសារណែនាំ (User Guide) ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ | អ.គ.ប. | ឯកសារណែនាំ (User Guide) ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារ-ណៈត្រូវបានរៀបចំ | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.១.** ធ្វើបច្ចុប្បន្នភាពឯកសារណែនាំ (User Guide) ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ | | | | | | | X | | | | | | | | X | | | |
| **ច.ស.៣. រៀបចំសាកល្បងប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** ប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្លូវជនបទ (RRAMS) | ក្រសួងអភិវឌ្ឍន៍ជនបទ | សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងទិន្នន័យផ្លូវជនបទ តាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងអភិវឌ្ឍន៍ជនបទ | | | | | | | | | | | | | | | | |
| **ស.ស.១.** បង្កើតក្រុមការងារគ្រប់គ្រងទិន្នន័យផ្លូវជនបទ តាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងអភិវឌ្ឍន៍ជនបទ (RRMAS) | | | | | X | | | | | | | | | | | | | |
| **ស.ស.២.** ធ្វើបច្ចុប្បន្នភាពក្រុមការងារការគ្រប់គ្រងផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងអភិវឌ្ឍន៍ជនបទ | | | | | | X | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.៣.** សិក្សានិងសម្របសម្រួលនីតិវិធីធ្វើចំណាត់ថ្នាក់ផ្លូវជនបទ និងកែសម្រួលចំណាត់ផ្លូវជនបទ | | | | | | X | | | | | | | | | | | | |
| **ស.ស.៤.** តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពរបស់ដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្លូវជនបទ (RRAMS) | | | | | | X | | | | | | | | | | | | |
| **ស.ស.៥.** គ្រប់គ្រង និងបញ្ចូនទិន្នន័យផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យា (RRAMS) | | | | | | X | | | | | | | | | | | | |
| **ច.ស.៤. កែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈបន្ថែម** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** កែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ | អ.គ.ប. | ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធា-រណៈត្រូវបានកែ-សម្រួលបន្ថែម | | | | | | | | | | | | | | | | |
| **ស.ស.១.** ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈត្រូវបានកែលម្អបន្ថែម | | | | | | X | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/សកម្មភាព | អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.២.** ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈត្រូវបានធ្វើបច្ចុប្បន្នភាព | | | | | | | | | | X | | | | X | | | | X |
| **ស.ក.២.** ពង្រឹង និងពង្រីកវិសាលភាពទិន្នន័យគម្រោងវិនិយោគសាធារណៈសម្រាប់ដាក់បញ្ចូលក្នុងប្រព័ន្ធ PIP_DBMS | អ.គ.ប. | ទិន្នន័យគម្រោងវិនិយោគសាធា-រណៈត្រូវបានពង្រឹង និងពង្រីកវិសាលភាព | | | | | | | | | | | | | | | | |
| **ស.ស.១.** ប្រមូល ពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើសង្គតិភាពទិន្នន័យជាមួយអង្គភាពពាក់ព័ន្ធ | | | | X | X | | | X | X | | | X | X | | | X | X | |
| **ស.គ.១១. រៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង** | | | | | | | | | | | | | | | | | | |
| **ច.ស.១. រៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** គោលការណ៍ណែនាំរួមស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង (Overall PDF Guideline) | អ.គ.ហ.<br>អ.ស.ប.<br>អ.ថ.<br>អ.ហ.ក.<br>អ.រ.ជ.<br>អ.គ.ប. | គោលការណ៍ណែនាំរួមស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងត្រូវបានរៀបចំ | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **សស.១.** សិក្ខាសាលាពិគ្រោះយោបល់ស្តីពីគោលការណ៍ណែនាំរួមស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង (Overall PDF Guideline) | | | | X | | | X | | | | | | | | | | | |
| **សស.២.** គោលការណ៍ណែនាំរួមស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង (Overall PDF Guideline) ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | | | | | | | | | | X | | | | | | | | |
| **សស.៣.** សិក្ខាសាលាផ្សព្វផ្សាយស្តីពីគោលការណ៍រួមស្តីពីយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង ត្រូវបានរៀបចំ | | | | | | | | | | | X | | | | | | | |
| **សគ.១២. រៀបចំ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស** | | | | | | | | | | | | | | | | | | |
| **ចស.១ រៀបចំផែនការសកម្មភាពកសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញការគ្រប់គ្រងវិនិយោគសាធារណៈ** | | | | | | | | | | | | | | | | | | |
| **សក.១.** រៀបចំប្រមូលចងក្រងទិន្នន័យ និងបើកវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាជាតិប្រព័ន្ធធារាសាស្ត្រ និងបច្ចេកវិទ្យាលើវិស័យធនធានទឹក | ក្រសួងធនធានទឹកនិងឧតុ-និយម | ឯកសារស្តង់ដាជាតិប្រព័ន្ធធារា-សាស្ត្រ | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| (GIS គ្រប់គ្រងការសាង់សង់ ការគ្រប់គ្រងថែទាំ .....) | | | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំឯកសារស្តង់ដាជាតិប្រព័ន្ធធារាសាស្ត្រ | | | X | X | X | X | | X | | | | | | | | | | |
| **ស.ស.២.** បញ្ចប់ការរៀបចំឯកសារស្តង់ដាជាតិប្រព័ន្ធធារាសាស្ត្រ | | | | | | | X | | X | | | | | | | | | |
| **ស.ក.២.** សិក្ខាកាមចំនួន ១៨០នាក់បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាជាតិប្រព័ន្ធធារាសាស្ត្រ និងបច្ចេកវិទ្យាលើវិស័យធនធានទឹក | ក្រសួងធនធានទឹកនិងឧតុ-និយម | សិក្ខាកាមចំនួន ១៨០នាក់ បានចូលរួមវគ្គបណ្តុះ-បណ្តាលស្តីពីស្តង់ដាជាតិប្រព័ន្ធធារា-សាស្ត្រ និងប-ច្ចេកវិទ្យាលើវិស័-យធនធានទឹក | | | | | | | | | | | | | | | | |
| **ស.ស.១.** បណ្តុះបណ្តាលមន្ត្រីថ្នាក់-ជាតិ និងថ្នាក់ក្រោមជាតិ | | | X | | | | | | | | | | | | | | | |
| **ស.ស.២.** បណ្តុះបណ្តាលសហគមន៍ខេត្តគោលដៅ ៩០នាក់ | | | | X | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.៣.** បណ្តុះបណ្តាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ខេត្តគោលដៅ ៩០នាក់ | | | | | X | | | | | | | | | | | | | |
| **ស.ស.៤.** រៀបចំលទ្ធផលឯកសារវគ្គបណ្តុះបណ្តាល | | | | | | X | | | | | | | | | | | | |
| **ស.ស.៥.** រៀបចំឯកសារបណ្តុះ-បណ្តាលមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | | | | | | X | | | | X | | | X | | | | |
| **ស.ស.៦.** ផ្សព្វផ្សាយឯកសារស្តង់ដាជាតិប្រព័ន្ធធារាសាស្ត្រដល់មន្ត្រីថ្នាក់ជាតិ និងក្រោមជាតិតាមរយៈបើកវគ្គបណ្តុះបណ្តាល | | | | | | | | X | X | | | X | | | X | X | | |
| **ស.ស.៧.** រៀបចំបូកសរុបលទ្ធផលឯកសារវគ្គបណ្តុះបណ្តាល | | | | | | | | | | X | | | X | | | | | X |
| **ស.ស.៨.** ផ្សព្វផ្សាយឯកសារស្តង់ដាជាតិប្រព័ន្ធធារាសាស្ត្រដល់មន្ត្រីថ្នាក់ជាតិ និងក្រោមជាតិបន្តបើកវគ្គបណ្តុះ-បណ្តាល | | | | | | | | | | | | X | | | | | | |
| **ច.ស.២ រៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសរយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ (Certificate Program) ជូនមន្ត្រីជំនាញ និងថ្នាក់ដឹកនាំទទួលបន្ទុកការងារគ្រប់គ្រងវិនិយោគសាធារណៈ** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** រៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រ | វ.ស.ហ. អគ្គ- | មន្ត្រីគ្រប់គ្រងការងារគម្រោង | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| ផ្សារភ្ជាប់មុខតំណែង (Certificate Program) លើជំនាញគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ជូនមន្ត្រីគ្រប់គ្រងការងារគម្រោងវិនិយោគសាធារណៈ នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | នាយកដ្ឋាន/ អង្គភាពពាក់ព័ន្ធនៃ ក.ស.ហ.វ. | វិនិយោគសាធារណៈ នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន ១០០ នាក់ ទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែងលើជំនាញគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ជូនមន្ត្រីគ្រប់គ្រងការងារគម្រោងវិនិយោគសាធារណៈ នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | X | | | | X | | | | X | | | | X |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ក.២.** រៀបចំទស្សនកិច្ចសិក្សាស្តីពីការអនុវត្តគម្រោងវិនិយោគសាធារណៈបទពិសោធបរទេស ជូនថ្នាក់ដឹកនាំទទួលបន្ទុកគ្រប់គ្រងការងារគម្រោងវិនិយោគសាធារណៈ នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រូបង្គោល | រ.ស.ហ. អគ្គនាយកដ្ឋាន/ អង្គភាពពាក់ព័ន្ធនៃ ក.ស.ហ.វ. ក្រសួងស្ថាប័ន | ថ្នាក់ដឹកនាំទទួលបន្ទុកគ្រប់គ្រងការងារគម្រោងវិនិយោគសាធារណៈ នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រូបង្គោល ចំនួន ៣០ នាក់ បានចូលរួមទស្សនកិច្ចសិក្សាស្តីពីការអនុវត្តគម្រោងវិនិយោគសាធារណៈបទពិសោធបរទេស | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំទស្សនកិច្ចសិក្សាស្តីពីការអនុវត្តគម្រោងវិនិយោគសាធារណៈបទពិសោធបរទេស ជូនថ្នាក់ដឹកនាំទទួលបន្ទុកគ្រប់គ្រងការងារគម្រោងវិនិយោគសាធារណៈនៃក្រសួងស្ថាប័ន | | | | | | | | | | X | | | | X | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រូ-បង្គោល | | | | | | | | | | | | | | | | | | |
| **ស.ក.៣.** រៀបចំធ្វើបច្ចុប្បន្នកម្មកម្មវិធីបណ្តុះបណ្តាល ជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង (Certificate Program) លើជំនាញគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ | វ.ស.ហ. អគ្គ-នាយក-ដ្ឋាន/ អង្គភាពពាក់ព័ន្ធនៃ ក.សហវ. អ.គ.ហ. | កម្មវិធីបណ្តុះ-បណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង (Certificate Program) លើជំនាញគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ត្រូវបានរៀបចំ | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំធ្វើបច្ចុប្បន្នកម្មកម្មវិធីបណ្តុះបណ្តាល ជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង (Certificate Program) លើជំនាញគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ | | កម្មវិធីបណ្តុះ-បណ្តាលកម្រិតទី២ និងទី៣ | | | | | | | X | X | | | | | | | | |
| **ច.ស.៣. រៀបចំវគ្គបណ្តុះបណ្តាលលើជំនាញការគ្រប់គ្រងវិនិយោគសាធារណៈជូនគ្រូបង្គោល** | | | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ក.១.** រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល លើជំនាញគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ | វ.ស.ហ. អគ្គនាយកដ្ឋាន/ អង្គភាពពាក់ព័ន្ធនៃ ក.ស.ហ.វ. | គ្រូបង្គោលចំនួន ១០ នាក់ ទទួលបានការបណ្តុះបណ្តាល លើជំនាញគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ត្រូវបានរៀបចំ | | | | | | | | | | | | | | | | |
| **ស.ស.១.** រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ | | | | | | | | | | X | | | | | | | | |
| **ច.ស.៤. រៀបចំវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាលើជំនាញការគ្រប់គ្រងវិនិយោគសាធារណៈជូនមន្ត្រីជំនាញ និងថ្នាក់ដឹកនាំគ្រប់គ្រងវិនិយោគសាធារណៈ** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** វគ្គបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពពាក់ព័ន្ធការគ្រប់គ្រងការវិនិយោគសាធារណៈ ទាំងក្នុង និងក្រៅប្រទេស | អ.គ.ហ. អគ្គនាយកដ្ឋានពាក់ព័ន្ធនៃ ក.ស.ហ.វ. ក្រសួង ស្ថាប័នពាក់ព័ន្ធ | របាយការណ៍បណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពពាក់ព័ន្ធការគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានរៀបចំ | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| | និងរដ្ឋ-បាល ថ្នាក់ក្រោម ជាតិ | | | | | | | | | | | | | | | | | |
| **ស.ស.១.** វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាស្តីពីការកសាងសមត្ថភាពពាក់ព័ន្ធការគ្រប់គ្រងការវិនិយោគសាធារណៈ នៅក្រៅប្រទេស | | | | | | | X | | X | | X | | X | | X | | X | |
| **ស.ស.២.** វគ្គបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពពាក់ព័ន្ធការគ្រប់គ្រងការវិនិយោគសាធារណៈ នៅក្នុងប្រទេស (តាមការចាំបាច់) | | | | | | | | X | | X | | X | | X | | X | | X |
| **ស.គ.១៣. ត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា** | | | | | | | | | | | | | | | | | | |
| **ច.ស.១. រៀបចំវាយតម្លៃប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា ដោយប្រើវិធីសាស្ត្រការវាយតម្លៃការវិនិយោគសាធារណៈ (PIMA និង C-PIMA)** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** សេចក្តីព្រាងរបាយការណ៍ PIMA & C-PIMA ត្រូវបានធ្វើបច្ចុប្បន្នកម្ម | អ.គ.ហ. | សេចក្តីព្រាងរបាយការណ៍ PIMA & C-PIMA ត្រូវបានរៀបចំធ្វើបច្ចុប្បន្នកម្ម | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.១.** ក្រុមការងារបច្ចេកទេសស្តីពីការរៀបចំរបាយការណ៍ PIMA & C-PIMA ត្រូវបានបង្កើត | | | | | | | | | | | | | | X | | | | |
| **ស.ស.២.** កិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការរៀបចំរបាយការណ៍ PIMA & C-PIMA ត្រូវបានរៀបចំ | | | | | | | | | | | | | | | X | | | |
| **ស.ស.៣.** ចុះប្រមូលធាតុចូលពីអគ្គនាយកដ្ឋាន/អង្គភាពស្ថិតក្រោម ក.ស.ហ.វ., ក្រសួង ស្ថាប័ន, និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំរបាយការណ៍ | | | | | | | | | | | | | | | | X | | |
| **ស.ស.៤.** សេចក្តីព្រាងរបាយការណ៍ត្រូវបានរៀបចំ | | | | | | | | | | | | | | | | | X | |
| **ស.ស.៥.** របាយការណ៍ PIMA & C-PIMA ត្រូវបានបញ្ចប់ | | | | | | | | | | | | | | | | | | X |
| **ច.ស.២. របាយការណ៍តាមដាន និងវាយតម្លៃវឌ្ឍនភាពប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ (PIMSRS)** | | | | | | | | | | | | | | | | | | |
| **ស.ក.១.** របាយការណ៍វឌ្ឍនភាព PIMSRS ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ | អ.គ.ហ. | របាយការណ៍វឌ្ឍនភាព PIMSRS ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ត្រូវបានរៀបចំ | | | | | | | | | | | | | | | | |

| វិធាន/ចង្កោមសកម្មភាព/ សកម្មភាព | អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ្នាំ២០២៥ | | | | ឆ្នាំ២០២៦ | | | | ឆ្នាំ២០២៧ | | | | ឆ្នាំ២០២៨ | | | |
| | | | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ | ត.១ | ត.២ | ត.៣ | ត.៤ |
| **ស.ស.១.** របាយការណ៍វឌ្ឍនភាព PIMSRS ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ | | | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

<u>**សម្គាល់៖**</u>

- ស.គ.៖ សូចនាករគោលបំណង
- ច.ស.៖ ចង្កោមសកម្មភាព
- ស.ក.៖ សកម្មភាព
- ស.ស.៖ សូចនាករសមិទ្ធិកម្មគន្លឹះ

# ឧបសម្ព័ន្ធទី៣
# ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន
# និងធនធានមនុស្សសម្រាប់ការគ្រប់គ្រង
# ការវិនិយោគសាធារណៈ

# មាតិកានុក្រម

**ជំពូកទី១ សេចក្តីផ្តើម**......១១២
**ជំពូកទី២ គោលបំណង គោលដៅ និងវិសាលភាព**......១១៣
២.១. គោលបំណង......១១៣
២.២. គោលដៅ......១១៣
២.៣. វិសាលភាព......១១៣
**ជំពូកទី៣ ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង**......១១៤
៣.១. ចំណុចខ្លាំង......១១៤
៣.២. ចំណុចខ្សោយ......១១៤
៣.៣. កាលានុវត្តភាព......១១៥
៣.៤. ការគំរាមកំហែង......១១៥
**ជំពូកទី៤ ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ឆ្នាំ ២០២៥-២០២៨**......១១៦
៤.១. ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន......១១៦
៤.២. ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស......១១៦
៤.៣. គម្រោងប៉ាន់ស្មានថវិកាចំណាយសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស......១១៧

# ជំពូកទី១
# សេចក្តីផ្តើម

ដោយយល់ច្បាស់ពីសារៈសំខាន់ នៃការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ ក្នុងការរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកន្លងមក រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈដោយភ្ជាប់ជាឧបសម្ព័ន្ធ នៃយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធការគ្រប់គ្រងការវិនិយោគសាធារណៈ ម្តងរួចមកហើយ។

រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ បានដាក់ចេញនូវផែនការគន្លឹះ៣ពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សដូចជា៖ ១)ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២)ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និង៣)ផែនការយុទ្ធសាស្ត្របច្ចុប្បន្នកម្មស្តីពីការកសាងសមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤។ ទន្ទឹមនេះនៅតាមក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួន ក៏មានផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សផ្ទៃក្នុង រៀងៗខ្លួនផងដែរ។

ទន្ទឹមនឹងផែនការដែលបានរៀបរាប់ខាងលើ, ក៏នៅពុំទាន់គ្រប់គ្រាន់ដែលអាចឆ្លើយតបបានទៅនឹងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងឧត្តមានុវត្តន៍ជាអន្តរជាតិនៅឡើយទេ។ ហេតុដូច្នេះ, រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការរៀបចំផែនការពង្រឹងសមត្ថភាពរួមមួយ ដែលមានវិសាលភាពគ្របដណ្តប់លើការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងថវិកាថ្នាក់ជាតិ, ថវិកាថ្នាក់ក្រោមជាតិ, ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈ ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន), និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់-ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ដើម្បីបំពេញបន្ថែមផែនការដែលបានរៀបចំកន្លងមក សំដៅធានានូវភាពគ្រប់ជ្រុងជ្រោយ, ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងវិនិយោគសាធារណៈ។

ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ គឺជាឧបករណ៍ដ៏សំខាន់មួយ និងមិនអាចខ្វះបានសម្រាប់គាំទ្រដល់ការអនុវត្ត «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨**»។ ផែនការនេះ នឹងត្រូវបានប្រើប្រាស់ជាត្រីវិស័យចង្អុលទិសអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ក្នុងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ សំដៅរួមចំណែកដល់ការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។

ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈ ជា «**ឯកសាររស់**» ដែលអាចនឹងត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម តាមការចាំបាច់។

# ជំពូកទី២
# គោលបំណង គោលដៅ និងវិសាលភាព

## ២.១. គោលបំណង

ផែនការនេះ មានគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងពីថវិកាជាតិ ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈ ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន), និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ, ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ, គ្រឹះស្ថានសាធារណៈរដ្ឋបាល, សហគ្រាសសាធារណៈ, និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាព នៃការគ្រប់គ្រងវិនិយោគសាធារណៈ សំដៅរួមចំណែកដល់ការបង្កើនល្បឿន នៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។

## ២.២. គោលដៅ

ផែនការនេះ មានគោលដៅដាក់ចេញនូវផែនការសកម្មភាពរួម ក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ។

## ២.៣. វិសាលភាព

ផែនការនេះ មានវិសាលភាពគ្របដណ្តប់លើការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័នពាក់ព័ន្ធ, និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ជំពូកទី៣
# ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង

## ៣.១. ចំណុចខ្លាំង

ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងការវិនិយោគសាធារណៈកម្ពុជាបច្ចុប្បន្ន រាជរដ្ឋាភិបាលយល់ឃើញថា មានចំណុចខ្លាំងដូចខាងក្រោម៖

- រាជរដ្ឋាភិបាលមានរបៀបវារៈគោលនយោបាយច្បាស់លាស់ ក្នុងការបន្តកសាង និងអភិវឌ្ឍប្រទេសដូចមានបញ្ជាក់ក្នុង «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**» ដែលបានផ្តល់អាទិភាពទី១ លើមនុស្ស
- រាជរដ្ឋាភិបាលមានឆន្ទៈគោលនយោបាយខ្ពស់ក្នុងការបន្តសកម្មភាពអនុវត្តនូវកម្មវិធីកែទម្រង់គន្លឹះៗទាំងប្រាំរួមមាន៖ ១)កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២)កម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ, ៣)កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ៤)កម្មវិធីកែទម្រង់ប្រព័ន្ធច្បាប់, និង៥)កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលក្នុងនោះ ផ្តោតសំខាន់លើការបន្តពង្រឹងគុណភាពស្ថាប័ន និងធនធានមនុស្សនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធផងដែរ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានផែនការយុទ្ធសាស្ត្រស្តីពីការកសាងនិងការអភិវឌ្ឍសមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ដែលកំពុងធ្វើបច្ចុប្បន្នកម្មសម្រាប់អនុវត្តឆ្នាំ២០២៥-២០២៨
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ ទទួលបន្ទុករៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង (Certificate Program) លើជំនាញការគ្រប់គ្រងការវិនិយោគសាធារណៈ ដើម្បីឆ្លើយតបទៅនឹងអនុក្រឹត្យលេខ៤៥ ស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ
- ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាលមានការយកចិត្តទុកដាក់ខ្ពស់ ក្នុងការបំពាក់បំប៉ន់សមត្ថភាពដល់មន្ត្រីពាក់ព័ន្ធជាប់ជាប្រចាំ ជាពិសេស លើការងារគ្រប់គ្រងការវិនិយោគសាធារណៈ តាមរយៈការរៀបចំកម្មវិធីបណ្តុះបណ្តាលក្នុងប្រទេស និងការបញ្ជូនឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស
- មានការជ្រើសរើសមន្ត្រីថ្មី វ័យក្មេង ដែលមានសមត្ថភាព និងឆន្ទៈខ្ពស់បន្ថែម នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធតាមរយៈការប្រឡងប្រកបដោយតម្លាភាព។

## ៣.២. ចំណុចខ្សោយ

ទន្ទឹមនឹងចំណុចខ្លាំងខាងលើ រាជរដ្ឋាភិបាល ក៏បានពិនិត្យឃើញអំពីចំណុចខ្សោយមួយចំនួនផងដែរ ពាក់ព័ន្ធនឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងការគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្ន ដែលមានដូចខាងក្រោម៖

- រចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្ននៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន លើការងារគ្រប់គ្រងការវិនិយោគសាធារណៈ ពុំទាន់បានឆ្លើយតបពេញលេញទៅនឹងបរិការណ៍ជាក់ស្តែងនៃការវិវត្តសេដ្ឋកិច្ចកម្ពុជា និងឧត្តមានុវត្តន៍ជាអន្តរជាតិនៅឡើយ ដែលទាមទារឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះ ត្រូវបន្តយកចិត្តទុកដាក់ការកែលម្អបន្ថែមទៀត
- សមត្ថភាពមន្ត្រីពាក់ព័ន្ធតាមក្រសួង ស្ថាប័នលើការងារគ្រប់គ្រងការវិនិយោគសាធារណៈ នៅតាមដំណាក់កាលនីមួយៗ នៃវដ្តគម្រោង នៅមានកម្រិត បើទោះជាកន្លងមកក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗខិតខំកសាងបាននូវធនធានមនុស្សមួយចំនួនរួចហើយក្តី ក៏ប៉ុន្តែ ទាំងចំនួន និងទាំងសមត្ថភាព នៅពុំទាន់អាចឆ្លើយតបបានទៅនឹងទំហំការងារបច្ចុប្បន្ន ក៏ដូចជាអនាគតនៅឡើយ

- ផលវិបាកក្នុងការរក្សាទុកធនធានមនុស្សដែលមានស្រាប់ ឱ្យនៅបន្តធ្វើការងារ និងទាក់ទាញធនធានមនុស្សថ្មីបន្ថែម ដែលមានសមត្ថភាព និងធន្ទះវិជ្ជាជីវៈខ្ពស់ ឱ្យមកបម្រើការងារ ដោយសារប្រព័ន្ធផ្តល់ការលើកទឹកចិត្តបច្ចុប្បន្ន នៅមិនទាន់មានភាពប្រកួតប្រជែង។

## ៣.៣. ឱកាសនុវត្តភាព

ទន្ទឹមនឹងចំណុចខ្លាំង និងចំណុចខ្សោយខាងលើ, រាជរដ្ឋាភិបាលយល់ឃើញថា មានកាលានុវត្តភាពក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងការវិនិយោគសាធារណៈ ទាំងផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុ ដូចខាងក្រោម៖

- **ផ្នែកបច្ចេកទេស៖** កម្ពុជាមានជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា (ដូចជា៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងធនាគារអភិវឌ្ឍន៍អាស៊ី ជាដើម) តាមរយៈការផ្តល់ជំនាញការអន្តរជាតិ ឬ អ្នកជំនាញបច្ចេកទេស មកធ្វើបទបង្ហាញនៅក្នុងវគ្គបណ្តុះបណ្តាល ឬ សិក្ខាសាលា ដើម្បីផ្តល់ចំណេះដឹង និងបទពិសោធពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។
- **ផ្នែកហិរញ្ញវត្ថុ៖** រាជរដ្ឋាភិបាលអាចប្រើប្រាស់ជំនួយហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀតសម្រាប់ហិរញ្ញប្បទានមន្ត្រីពាក់ព័ន្ធទៅចូលរួមសិក្ខាសាលា, វគ្គបណ្តុះបណ្តាល, ទស្សនកិច្ចសិក្សា, សន្និសីទ, វេទិកា ទាំងក្នុងស្រុក និងក្រៅប្រទេស និងសម្រាប់ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានសមត្ថភាព និងធន្ទះវិជ្ជាជីវៈខ្ពស់។

## ៣.៤. ការគំរាមកំហែង

រាជរដ្ឋាភិបាលយល់ឃើញថា ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈកម្ពុជា អាចនឹងទទួលរងនូវការគំរាមកំហែងមួយចំនួនពីកត្តាខាងក្រៅ ដូចខាងក្រោម៖

- ភាពទាក់ទាញខ្លាំង នៃការងារនៅតាមវិស័យឯកជន និងអង្គការ ស្ថាប័ននានា ដែលអាចជាបញ្ហាប្រឈមដ៏ចម្បងចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ក្នុងការរក្សាទុក និងស្រូបយកនូវធនធានមនុស្សល្អៗឱ្យនៅបន្ត និងមកបម្រើការងារ
- ភាពវិវត្តឥតឈប់ឈរ នៃវិស័យព័ត៌មានវិទ្យា ដែលកម្ពុជាអាចនឹងពិបាកក្នុងការបត់បែនបានភ្លាមៗនូវរបៀបរបបនៃការអនុវត្តការងារ
- ការផ្លាស់ប្តូរគោលនយោបាយជាយថាហេតុរបស់ដៃគូអភិវឌ្ឍន៍ ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់កម្ពុជា
- វិបត្តិនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន
- សភាពការណ៍ប្រែប្រួលផ្នែកនយោបាយ និងបញ្ហាប្រឈមថ្មីៗ ពាក់ព័ន្ធនឹងវិបត្តិសុខភាពសាធារណៈធ្ងន់ធ្ងរ, ជម្លោះភូមិសាស្ត្រនយោបាយសកលកាន់តែស្រួចស្រាល់ ព្រមទាំងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ការគំរាមចំពោះអធិបតេយ្យជាតិ និងបូរណភាពទឹកដី, គ្រោះធម្មជាតិផ្សេងៗ, និងតម្រូវការដោះស្រាយសំណូមពររបស់ប្រជាជនគ្រប់ស្រទាប់។

# ជំពូកទី៤
# ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ឆ្នាំ២០២៥-២០២៨

ក្នុងគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ សំដៅរួមចំណែកទ្រទ្រង់ចីរភាព នៃកំណើនសេដ្ឋកិច្ចរយៈពេលវែង រាជរដ្ឋាភិបាលអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តប្រើប្រាស់ជំនួយពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត ក្នុងការអនុវត្តផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដូចតទៅ៖

## ៤.១. ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន

ដើម្បីអភិវឌ្ឍសមត្ថភាពក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការវិនិយោគសាធារណៈ ឱ្យមានភាពរឹងមាំ និងមានសមត្ថភាពពេញលេញ ក្នុងកម្រិតប្រកួតប្រជែងជាមួយប្រទេសក្នុងតំបន់ និង/ឬ លើសកលលោក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តនូវផែនការសកម្មភាព ដូចខាងក្រោម៖

១)បន្តចាត់វិធានការចាំបាច់នានាក្នុងការរក្សាទុកមន្ត្រីមានសមត្ថភាព និងធន្ធៈវិជ្ជាជីវៈខ្ពស់ដែលមានស្រាប់ តាមរយៈការពិនិត្យឡើងវិញលើប្រព័ន្ធផ្តល់ការលើកទឹកចិត្ត និងសមិទ្ធកម្ម

២)ជ្រើសរើសមន្ត្រីថ្មីដែលមានសមត្ថភាព និងធន្ធៈវិជ្ជាជីវៈខ្ពស់បន្ថែមទៀត ប្រកបដោយតម្លាភាព ឱ្យស្របតាមទំហំការងារជាក់ស្តែង

៣)បន្តអនុវត្តអភិក្រម «**រៀនផង-ធ្វើផង**»។

## ៤.២. ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស

ដើម្បីពង្រឹងសមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងការងារគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តនូវផែនការសកម្មភាព ដូចខាងក្រោម៖

១)បន្តយកចិត្តទុកដាក់កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងការវិនិយោគសាធារណៈ លើមុខជំនាញសំខាន់ៗ ដូចជា៖

- ការរៀបចំឯកសារទស្សនាទានគម្រោង (Project Concept Note)
- ការវាយតម្លៃ និងការធ្វើអាទិភាវូបនីយកម្ម នៃសំណើគម្រោង
- ការរៀបចំសិក្សាសមិទ្ធិលទ្ធភាពនៃសំណើគម្រោង រួមទាំងការសិក្សាលើទិដ្ឋភាពបច្ចេកទេស, សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ច្បាប់, និងសង្គមនិងបរិស្ថាន
- ការពិនិត្យ និងជ្រើសរើសគម្រោង (Project screening/selection)
- ការកំណត់ចរិតលក្ខណៈនៃគម្រោងវិនិយោគសាធារណៈ (Defining project characteristics)
- ការកំណត់សមិទ្ធិផលជាក់លាក់ (Output specification)
- ការធ្វើរចនាសម្ព័ន្ធគម្រោង (Project structuring)
- ការរៀបចំកិច្ចសន្យាគម្រោងវិនិយោគសាធារណៈ (Project contract)
- ការរៀបចំផែនការគ្រប់គ្រងកិច្ចសន្យា (Contract management plan)
- ការរៀបចំផែនការ និងការធ្វើកិច្ចលទ្ធកម្ម (Procurement Plan) ដោយរួមបញ្ចូលទាំងការរៀបចំឯកសារដេញថ្លៃ និងការវាយតម្លៃសំណើដេញថ្លៃផងដែរ
- ការបែងចែកហានិភ័យក្នុងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (Risk allocation)
- ការវិភាគ និងវាយតម្លៃគម្រោងតាមវិធីសាស្ត្រតម្លៃនៃលុយ (Value for Money)

- ការវិភាគគំរូហិរញ្ញវត្ថុ (Financial model for optimization of project life cycle cost)
- ការពិនិត្យ និងតាមដានការអនុវត្តគម្រោងវិនិយោគសាធារណៈ
- ការគ្រប់គ្រងហានិភ័យនៃគម្រោងវិនិយោគសាធារណៈ
- ការគណនាកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liability Calculation)
- វិធីសាស្រ្តវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយរួមបញ្ចូលការប្រែប្រួលអាកាសធាតុ (PIMA និង C-PIMA) របស់ IMF
- និងមុខជំនាញពាក់ព័ន្ធផ្សេងទៀត។

២)បន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពាក់ព័ន្ធ តាមអភិក្រម ដូចខាងក្រោម៖

- ការបណ្តុះបណ្តាលក្នុងស្រុក រួមមាន៖ ១)ការរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង (Certificate Program) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ២)ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញដែលបង្ហាត់បង្ហាញដោយជំនាញការអន្តរជាតិ ឬ មន្ត្រី នៃស្ថាប័នជំនាញអន្តរជាតិនានា, ៣)ការរៀបចំសិក្ខាសាលា ឬ វេទិកា ឬ សន្និសីទ ដោយមានការចូលរួមពីជំណាញការជាតិ, អន្តរជាតិ ឬមន្ត្រីជំនាញនៃក្រសួង ស្ថាប័នពាក់ព័ន្ធ, និង៤)ការសិក្សាតាមប្រព័ន្ធអ៊ីនធឺណែត
- ការបណ្តុះបណ្តាលក្រៅប្រទេស ដែលរួមមាន៖ ១)ការចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ដែលរៀបចំដោយអង្គការ-ស្ថាប័នក្នុងតំបន់ ឬ អន្តរជាតិនានា, ២)ការចូលរួមសិក្ខាសាលា វេទិកា ឬ សន្និសីទក្នុងតំបន់ ឬ អន្តរជាតិលើប្រធានបទជំនាញពាក់ព័ន្ធ, និង៣)ការធ្វើទស្សនកិច្ចសិក្សានៅតាមក្រសួង ស្ថាប័នជំនាញ នៃប្រទេសក្នុងតំបន់ និងប្រទេសជឿនលឿននានាលើសកលលោក។ បន្ថែមលើនេះ, ត្រូវរៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន ដើម្បីជាការចែករំលែកចំណេះដឹងបន្ត ពីមន្ត្រីដែលបានចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ដល់មន្ត្រីពាក់ព័ន្ធផ្សេងទៀត។

## ៤.៣. គម្រោងប៉ាន់ស្មានថវិកាចំណាយសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស

*ឯកតា៖ ពាន់ដុល្លារអាមេរិក*

| ផែនការសកម្មភាព | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | សរុប |
|---|---|---|---|---|---|
| **១. ក្នុងស្រុក** | **១០០** | **១០០** | **១០០** | **១០០** | **៤០០** |
| ក. វគ្គបណ្តុះបណ្តាលជំនាញ | ៥០ | ៥០ | ៥០ | ៥០ | ២០០ |
| ខ. សិក្ខាសាលា | ២៥ | ២៥ | ២៥ | ២៥ | ១០០ |
| គ. វេទិកា | ១០ | ១០ | ១០ | ១០ | ៤០ |
| ឃ. សន្និសីទ | ១០ | ១០ | ១០ | ១០ | ៤០ |
| ង. ការសិក្សាតាមប្រព័ន្ធអ៊ីនធឺណែត | ៥ | ៥ | ៥ | ៥ | ២០ |
| **២. ក្រៅស្រុក** | **៣០០** | **៣០០** | **៣០០** | **៣០០** | **១ ២០០** |
| ក. វគ្គបណ្តុះបណ្តាលជំនាញ | ១០០ | ១០០ | ១០០ | ១០០ | ៤០០ |
| ខ. សិក្ខាសាលា | ៥០ | ៥០ | ៥០ | ៥០ | ២០០ |
| គ. វេទិកា | ២៥ | ២៥ | ២៥ | ២៥ | ១០០ |
| ឃ. សន្និសីទអន្តរជាតិ | ២៥ | ២៥ | ២៥ | ២៥ | ១០០ |
| ង. ទស្សនកិច្ចសិក្សា | ១០០ | ១០០ | ១០០ | ១០០ | ៤០០ |
| **សរុប (១+២)៖** | **៤០០** | **៤០០** | **៤០០** | **៤០០** | **១ ២០០** |

# សមាសភាព
# ក្រុមការងារបច្ចេកទេស
# សម្រាប់រៀបចំយុទ្ធសាស្ត្រ
# ស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រង
# ការវិនិយោគសាធារណៈ
# បច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨

**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨** ត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈបច្ចុប្បន្នកម្ម ឆ្នាំ២០២៥-២០២៨ ក្រោមការដឹកនាំផ្ទាល់ដោយ ឯកឧត្តម **ម៉ែន ធីរុទ្ធ** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដែលមានសមាសភាពសំខាន់ៗចូលរួម ដូចខាងក្រោម៖

- ឯកឧត្តម **ឈួន សំរីទ្ធិ** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមការងារនៃអគ្គនាយកដ្ឋានថវិកា
- ក្រុមការងារនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្រុមការងារនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
- ក្រុមការងារនៃអគ្គនាយកដ្ឋានគោលនយោបាយ
- ក្រុមការងារនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល
- ក្រុមការងារនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន
- ក្រុមការងារនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមការងារនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- ក្រុមការងារនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ក្រុមការងារនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ
- លោក **ហៀង សូយ៉ារ៉ូ** មន្ត្រីជំនាញជាន់ខ្ពស់ នៃ **អ.គ.ហ.**
- លោក **លឹម សុខហេង** មន្ត្រីជំនាញជាន់ខ្ពស់ នៃ **អ.គ.ហ.**
- លោក **ស៊ុន ហៀង** មន្ត្រីជំនាញ នៃ **អ.គ.ហ.**
- កញ្ញា **ថន ខេងវិច្ឆិការ៉ានី** មន្ត្រីជំនាញ នៃ **អ.គ.ហ.**
- លោក **ជា សុវ័ណ្ណា** ជំនួយការមន្ត្រីជំនាញ នៃ **អ.គ.ហ.**។

ក្រុមការងារបច្ចេកទេសនេះ មានមន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញទទួលបន្ទុកសម្របសម្រួលរៀបចំ ដូចខាងក្រោម៖

- លោក **ហៀង សូយ៉ារ៉ូ** មន្ត្រីជំនាញជាន់ខ្ពស់ នៃ **អ.គ.ហ.**
- លោក **ស៊ុន ហៀង** មន្ត្រីជំនាញ នៃ **អ.គ.ហ.**៕

## អគ្គលេខាធិការដ្ឋាន
## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ


ទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ,
រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

(+៨៥៥) ៨៥ ៧៧៧ ៩២៤

www.pfm.gov.kh

gsc@pfm.gov.kh

www.facebook.com/gscpfm